គង់ សុខហេង

# សំណួរ-ចម្លើយ

## ស្របតាមមេរៀន

# អក្សរសាស្ត្រខ្មែរ

១១

មាន :

- ចម្លើយគ្រប់មេរៀន
- វេយ្យាករណ៍
- បំណិន
- ការស្តាប់



ស្របតាមកម្មវិធីសិក្សាថ្មី

# សំណួរ-ចម្លើយ

# អក្សរសាស្ត្រខ្មែរ

## ថ្នាក់ទី ១១

មាន : - ចម្លើយគ្រប់មេរៀន

- វេយ្យាករណ៍

- បំណិន

- ការស្តាប់

រៀបរៀងលើកទី១

២០១០

កែសម្រួលជាថ្មី

២០១២

សម្រាប់ជាជំនួយដល់ប្អូនៗ!

**ស្របតាមកម្មវិធីថ្មីរបស់ក្រសួងអប់រំយុវជននិងកីឡា**

# អារម្ភកថា

សួស្ដីប្អូនៗសិស្សានុសិស្សថ្នាក់ទី១១ជាទីស្រឡាញ់! សៀវភៅកំណែភាសាខ្មែរថ្នាក់ទី១១ថ្មីនេះ ខ្ញុំរៀបចំឡើងដើម្បីបំពេញសេចក្ដីត្រូវការ និងជួយសម្រួលដល់ការសិក្សារបស់ប្អូនៗ ។

ចំពោះរាល់ការឆ្លើយសំណួរ ក៏ដូចជាការបកស្រាយទៅលើខ្លឹមសារនៅក្នុងមេរៀននីមួយៗ ប្រាកដជានៅមានចំណុចខ្វះខាតជាច្រើនដែលពុំទាន់អស់សេចក្ដី ដូច្នេះសូមប្អូនៗយកទៅអានដោយការពិចារណាបន្ថែមទៀត ទើបការសិក្សារបស់ប្អូនៗទទួលបានជោគជ័យ ។

ចូរប្អូនចងចាំថា សៀវភៅ គឺសម្រាប់អាន និងសិក្សាស្រាវជ្រាវ មិនមែនសម្រាប់បើកចម្លងនៅពេលប្រឡងទេ!

កែសម្រួលជាថ្មី

ថ្ងៃទី២៣ ខែ តុលា ២០១២

គ.ស.ហ

មេរៀនទី ១

# ផ្ចត់គំនិត

## ការវិវត្តនៃអក្សរសិល្ប៍ខ្មែរ

### សំណួរ

១. តើអត្ថបទនេះបានបង្ហាញពីអ្វី ?

២. តាមរយៈអត្ថបទនេះ គេអាចចែកអក្សរសិល្ប៍ខ្មែរជាប៉ុន្មានសម័យកាលធំៗ ?

៣. តើអក្សរសិល្ប៍សម័យកណ្តាលមានលក្ខណៈដូចម្តេចខ្លះ? តើមានអ្នកនិពន្ធ និងស្នាដៃអ្វីខ្លះ ?

៤. បើផ្អែកតាមចំណងជើងនៃស្នាដៃក្នុងអត្ថបទខាងលើនេះ តើខ្លឹមសារណាមួយដែលអ្នកគិតថាបានផ្សារភ្ជាប់ទៅនឹងផ្ចត់គំនិតខ្មែរក្នុងការគោរពពាក្យសត្យ ? ហេតុអ្វី ?

៥. ចូរអ្នកបង្ហាញឡើងវិញពីមូលហេតុដែលនាំឱ្យអ្នកនិពន្ធយើងមានគំនិតក្នុងការព្យាយាមនិពន្ធស្នាដៃគ្រប់ប្រភេទសម្រាប់កូនចៅជំនាន់ក្រោយ ។

### ចម្លើយ

១. អត្ថបទនេះបានបង្ហាញពីការវិវត្តនៃអក្សរសិល្ប៍ខ្មែរតាមសម័យកាលនីមួយៗ ។

២. តាមរយៈអត្ថបទនេះ គេអាចចែកអក្សរសិល្ប៍ខ្មែរជាបីសម័យកាលធំៗ គឺសម័យបុរាណ សម័យកណ្ដាល និងសម័យទំនើប ។
៣. អក្សរសិល្ប៍សម័យកណ្ដាលមានសភាពអាប់អួរដោយសារបច្ចាមិត្តមករាតត្បាតបណ្ដាលឱ្យមានចម្បាំង ។ លុះមកដល់ស.វ.១៧ ស្នាដៃអក្សរសិល្ប៍ក៏ចាប់ផ្ដើមងើបឡើងវិញ ។

អ្នកនិពន្ធ និងស្នាដៃអក្សរសិល្ប៍ក្នុងសម័យកណ្ដាលមាន៖

១. អ្នកចាំង : ល្បើកអង្គរវត្ត . គ.ស.១៦០៩ ( ១៦២០)

២. ព្រះរាជសម្ភារ

- ច្បាប់ព្រះរាជសម្ភារ. គ.ស.១៦២២
- សរសើរហេមន្តមាស. គ.ស.១៦២៩
- ហិនលក្ខណ៍សល. គ.ស.១៦៣០
- កាព្យនិរាស. គ.ស.១៦៦០

៣. ជ័យនន្ទ : សិលាចារឹកអក្សរខ្មែរមុនគេ. គ.ស.១៧០១

៤. ឧកញ៉ាកោសាធិបតីកៅ :ក្រុងសុភមិត្រ. គ.ស.១៧៩៨

៥. ឧកញ៉ាព្រះឃ្លាំងនង

- ច្បាប់សុភាសិត. គ.ស.១៧៩០
- លោកនេយ្យជាតក. គ.ស.១៧៩៤
- បុណ្ណសារសិរសា. គ.ស.១៧៩៧
- ភោគកុលកុមារ. គ.ស.១៨០៤

៦. ឧកញ៉ាវេហារសន្ធរម៉ុក

-រឿងទេវន្ទ

-ល្បើកថចក

-រឿងទុំទាវ (មុនទុំទាវរបស់ភិក្ខុសោម)

៧. វិសេសផ្លូង

-ល្បើកអក

-ល្បើកដុចនិងត្រី

-ល្បើកជូជក

៨. ព្រះអង្គឌួង

-រឿងចម្ប៉ាថោង, គ.ស.១៨១០

-រឿងកាកី, គ.ស.១៨១៥

-ច្បាប់ស្រី, គ.ស.១៨៣៧

-នឹងរឿងមហាវេស្សន្តរ (ពាក្យរាយ)

៤. បើផ្អែកតាមចំណងជើងនៃស្នាដៃក្នុងអត្ថបទខាងលើនេះ ខ្លឹមសារដែលខ្ញុំគិតថាបានផ្សារភ្ជាប់ទៅនឹងផ្នត់គំនិតខ្មែរក្នុងការគោរពពាក្យសត្យ គឺការគោរពសាសនា (ព្រាហ្មណ៍សាសនា និងពុទ្ធ-សាសនា) ព្រោះសាសនាទាំងនេះអប់រំមនុស្សឱ្យធ្វើអំពើល្អគ្រប់បែបយ៉ាង។ ក្នុងពេលនោះគេសង្កេតឃើញមានស្នាដៃអក្សរ-សិល្ប៍សាមញ្ញកើតឡើងដូចជា រឿងព្រេង រឿងនិទានខ្លីៗ ដែលនាំឱ្យអ្នកស្រុកចូលចិត្តស្តាប់និងអានពាក្យពេចន៍ងាយយល់ ដូចជា៖ កំណាព្យល្បើកអង្គរ ច្បាប់ព្រះរាជសម្ភារ សិលាចារឹកជ័យ

នន្ទ រឿងក្រុងសុភមិត្រ....។

៥. មូលហេតុដែលនាំឱ្យអ្នកនិពន្ធយើងមានគំនិតក្នុងការព្យាយាមនិពន្ធស្នាដៃគ្រប់ប្រភេទសម្រាប់កូនចៅជំនាន់ក្រោយ ដើម្បី៖

- រក្សាឯកសារប្រវត្តិសាស្ត្រនៃការកកើតប្រវត្តិហេតុការណ៍ក្នុងសម័យកាលតាំងពីបុរាណកាលមក ។
- រក្សាវប្បធម៌ដែលជាកេរដំណែលបុព្វបុរសយើងដែលធ្លាប់មានកន្លងមក ។
- បញ្ជាក់ថា ខ្មែរជាជាតិសាសន៍មួយដែលមានវប្បធម៌ប្រពៃណីរបស់ខ្លួនយ៉ាងពិតប្រាកដ ។
- មានមោទនភាពនិងមានគំនិតអភិរក្សមរតកវប្បធម៌ជាតិ ។

❖❖❖❖❖

# កំលាយដោយផ្នត់ដើម

*១- គេអាចបង្កើតពាក្យតាមវិធីកំលាយដោយផ្នត់ដើមដែលស្ថិតនៅខាងដើមពាក្យឫស ។ ផ្នត់ដើមមានទម្រង់ ៤ យ៉ាងគឺ៖ "ព-" "ពស-" "ពពស-" និង "ពសព-" ។*

១. ទម្រង់ "ព-" : កើតមកពីព្យញ្ជនៈទោលតែមួយប៉ុណ្ណោះ ហើយមានផ្នត់ [ក-] [ច-] [ផ-] [ត-] [ទ-] [ប-] [ម-] [ស-]

២. ទម្រង់ "ពស-" : ប្រើសម្រាបបង្កើតពាក្យពីរព្យាង្គ ហើយមានផ្នត់ [ក-] [ច-] [ត-] [ប-] [ស-]

៣. ទម្រង់ "ពពស-" : ប្រើសម្រាប់បង្កើតពាក្យក្លាយពីរព្យាង្គ ហើយមានផ្នត់ [ក្រ-] [គ្រ-] [ត្រ-] [ទ្រ-] [ប្រ-] [ព្រ-] [ស្រ-]

៤. ទម្រង់ "ពសព-" : ប្រើសម្រាប់បង្កើតពាក្យក្លាយពីរព្យាង្គ ហើយមានផ្នត់ [ក់ង-] [ច់ង-] [ប់ង-] [ស់ង-] [អ់ង-] [ក់ន-] [ក់ណ-] [ក់ម-] [ប់ន-] [ប់ណ-] [ប ញ-] [ព់ន-] [ព់ង-] [ប់ម-] [ស់ម-] [រ់ម-] [ល់ម-] [ក់ញ-]...

**លំហាត់**

១. ចូរប្រើវិធីកំលាយពាក្យដោយប្រើផ្នត់ដើមឱ្យបានត្រឹមត្រូវដើម្បីបង្កើតពាក្យ៖

ក. តាមទម្រង់ "ព-"

ពាក្យឫស : ងក់ ដួល ញ៉ុក ភាស់ រោង វាង ។ល

ខ. តាមទម្រង់ "ពស-"

ពាក្យឫស : កិត ខឹក ឃួស ជិក ទាក់ ពុះ ពួក ប៉ាច់ ។

គ. តាមទម្រង់ "ពពស-"

ពាក្យឫស : ចាប់ ពោត់ ហត់ វី វៀច ឈឹង សាយ ចាក់ ខាំ វែង ។

ឃ. តាមទម្រង់ "ពសព-"

ពាក្យឫស : កុញ ចាស់ ដាច ធាត់ លង លាក់ បុយ ដើរ ទាស់ ។

២. ចូរអ្នករកពាក្យឫសខាងក្រោមនេះដោយប្រាប់ពីទម្រង់ ៖

ក. ច្រាស ឆ្ងួល ផ្រុល ឈ្ងោក ធ្លុង ជ្រមុជ ស្ពក ប្រវែង ។

ខ. ចូរស្រង់ពាក្យក្លាយក្នុងសម្រង់អត្ថបទខាងក្រោមនេះ ដោយបញ្ជាក់ពីទម្រង់ផង ។

[...] សម័យបច្ចុប្បន្ន ( ចាប់ពីគ.ស.១៩៨៣ រហូតមក) ពេលបានរំដោះរួចផុតពីរបបខ្មៅងងឹត អ្នកនិពន្ធបានធូរស្រាលក្នុងចិត្តគំនិត ដោយបានទទួលសេរីភាពក្នុងការកសាងអក្សរសិល្ប៍ថ្មីៗរបស់ខ្លួន ។

អក្សរសិល្ប៍ខ្មែរក៏បានឈានដើរទៅកាន់ការលូតលាស់ថ្មីមួយដែលមានលក្ខណៈ និងនិន្នាការជាតិនិយម សង្គមនិយម ប្រជាធិបតេយ្យ និងប្រជាប្រិយ ។ គ្រប់ប្រភេទនៃអក្សរសិល្ប៍ក៏បានកើតឡើង គឺប្រលោមលោក កំណាព្យ រឿងល្ខោន សៀវភៅបច្ចេកទេស សៀវភៅសិក្សាអប់រំ សៀវភៅទាក់ទងនឹងគំនិតទស្សនវិជ្ជា ។ [...]

ចម្លើយ

១. រកផ្នត់

ក. តាមទម្រង់ "ព_"

[ក-] + ងក់ > ក្ងក់

[ប-] + ដួល > ផ្ដួល

[ប-] + ញ៉ុក > ផ្ញុក

[ក-] + ទាស់ > ខ្ទាស់

[ជ-] + រោង > ជ្រោង

[គ-] + វាង > ឃ្វាង

[ច-] + បង > ច្បង

ខ. តាមទម្រង់ "ពស_"

[ក-] + កិត > កកិត

[ក-] + ខឹក > កខឹក

[គ-] + ឃូស > គឃូស

[ជ-] + ជីក > ជជីក

[ទ-] + ទាក់ > ទទាក់

[ព-] + ពុះ > ពពុះ

[ព-] + ពួក > ពពួក

[ប៉-] + ប៉ាច់ > ប៉ប៉ាច់

គ. តាមទម្រង់ "ពពស."

[ក្រ-] + ចាប់ > ក្រចាប់

[ក្រ-] + ពាត់ > ក្រពាត់

[គ្រ-] + វី > គ្រវី

[ក្រ-] + វៀច > ក្រវៀច

[ត្រ-] + ឈើង > ត្រឈើង

[ត្រ-] + សាយ > ត្រសាយ

[ប្រ-] + ចាក់ > ប្រចាក់

[ប្រ-] + ខាំ > ប្រខាំ

[ប្រ-] + ដែង > ប្រដែង

ឃ. តាមទម្រង់ "ពសព."

[សង-] + កុញ > សង្កុញ

[កញ-] + ចាស់ > កញ្ចាស់

[កណ-] + ដាច > កណ្ដាច

[កន-] + ធាត់ > កន្ធាត់

[ក់ ន-] + លង > កន្លង

[ក់ ន-] + លាក់ > កន្លាក់

[ប់ ង-] + ហុយ > បង្ហុយ

[ប់ ណ-] + ដើរ > បណ្ដើរ

[ជ់ ម-] + ទាស់ > ជំទាស់

២. រកពាក្យឫស

ក. ច្រាស < រាស , ទម្រង់ "ព-"

ឆ្នូល < មូល , ទម្រង់ "ព-"

ជ្រុល < រុល , ទម្រង់ "ព-"

ឈ្ងោក < ងោក , ទម្រង់ "ព-"

ឆ្លុង < លុង , ទម្រង់ "ព-"

ជ្រមុជ < មុជ , ទម្រង់ "ពពស-"

ស្ដក < កក , ទម្រង់ "ព-"

ប្រវែង < វែង , ទម្រង់ "ពពស-"

ខ. ស្រង់ពាក្យក្លាយពីក្នុងអត្ថបទ៖

កសាង < សាង , ទម្រង់ "ពស-"

ប្រលោម < លោម , ទម្រង់ "ពពស-"

## ការវិភាគតួអង្គ

១- *ការវិភាគតួអង្គ គឺជាការសិក្សាវិភាគឱ្យឃើញពីអាកប្បកិរិយា ចរិតលក្ខណៈ សកម្មភាពរបស់តួអង្គនៅក្នុងរឿងតាមរយៈលក្ខណៈសម្បត្តិពីរយ៉ាង គឺគុណសម្បត្តិ និងគុណវិបត្តិ ។*

**ចម្លើយលំហាត់** (លំហាត់ទំព័រទី១៤)

វិភាគតួអង្គសុវណ្ណ និងនាងតន់

១. សុវណ្ណ

ក) គុណសម្បត្តិ

-មានគំនិតទទួលខុសត្រូវ

-មានសប្បុរសធម៌ ចេះជួយអ្នកដទៃ (នាងតន់...)

ខ) គុណវិបត្តិ

-ពុំមានសមត្ថភាពរកប្រាក់បង់ពន្ធ

-ទទួលនាងតន់ជាភរិយា ដោយមិនបានរៀបការតាមប្រពៃណី

២. នាងតន់

ក) គុណសម្បត្តិ

-ចេះសន្សំប្រាក់មិនហ៊ានចាយវាយផ្ដេសផ្ដាស

-បានជួយសង្គ្រោះសុវណ្ណ ដោយផ្ដល់ជាប្រាក់កាសក្នុង

ការបង់កាត និងបីបាច់កូនសុវណ្ណដូចកូនបង្កើត ។

ខ) គុណវិបត្តិ

-បាត់បង់លក្ខណៈជាស្ត្រី រត់ឡើងផ្ទះប្រុសទាំងយប់ ដោយមិនទាន់រៀបការ ។



## ភ្នំនាងកង្រី

**សំណួរ**

១. តើរឿងនេះគេចាត់ទុកជាអក្សរសិល្ប៍ប្រភេទណា ? ចូររកអំណះអំណាងបញ្ជាក់ ។

២. ហេតុដូចម្ដេចបានជានាងទាំង១១ ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ? ឯនាងទី១២ត្រូវគេឆ្កៀលភ្នែកតែម្ខាង ? តាមគំនិតអ្នកតើឥទ្ធិពលនៃទស្សនៈនេះកើតមកពីណា?

៣. តើផ្នត់គំនិតណាមួយក្នុងអត្ថបទដែលនៅតែជាឧត្តមគតិដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ ? ហេតុអ្វី ?

៤. តើរឿងនេះ បានបង្ហាញពីផ្នត់គំនិតខ្មែរយ៉ាងណាខ្លះ ?

៥. ហេតុដូចម្ដេចបានជាពុទ្ធិសែន បានរៀបការជាមួយនាងកង្រី?

តើអ្នកនិពន្ធមានទស្សនៈដូចម្ដេច ទើបមិនឱ្យពុទ្ធិសែនបានរួមរស់ជាមួយនាងកង្រីជាគូរៀងទៅអនាគត?

៦. បើតាមទស្សនៈរបស់អ្នក តើការបញ្ចប់រឿងដោយឱ្យពុទ្ធិសែន និងនាងកង្រីមិនបានរួមរស់ជាមួយស្វាមីភរិយាលុះអនាគតបែបនេះសមស្របឬទេ? ហេតុអ្វី?

៧. ចូរសិក្សាពីកាលអាកាសនៃរឿង។

៨. ចូរអ្នកស្រង់ពាក្យក្លាយឱ្យបានបួនពាក្យពីក្នុងអត្ថបទអំណានរឿង "ភ្នំនាងកង្រី" ដោយបង្ហាញពាក្យឫស និងប្រាប់ពីទម្រង់ផង។

ចម្លើយ

១. រឿងនេះគេចាត់ទុកជាអក្សរសិល្ប៍ប្រជាប្រិយ ព្រោះរឿងនេះ៖
   - គ្មានអ្នកនិពន្ធ និងកាលកំណត់តែង
   - ជារឿងដែលគេនិយាយតៗគ្នាពីមាត់មួយទៅមួយ
   - បង្ហាញពីប្រវត្តិកកើតភ្នំនាងកង្រី

២. បានជានាងទាំង១១ ត្រូវគេឆ្កៀលភ្នែកទាំងសងខាង ព្រោះកាលពីជាតិមុននាងទាំង១១ឆ្កៀលភ្នែកត្រីទាំងសងខាង។ ឯនាងទី១២ត្រូវគេឆ្កៀលភ្នែកតែម្ខាង ព្រោះកាលពីជាតិមុន នាងទី១២ឆ្កៀលភ្នែកត្រីតែម្ខាង។

តាមគំនិតខ្ញុំ ឥទ្ធិពលនៃទស្សនៈនេះកើតមកពីបញ្ហាកម្ម-ផលក្នុងព្រះពុទ្ធសាសនា (កម្មផលក្នុងពុទ្ធសាសនាមានបីយ៉ាងគឺ កម្មក្នុងអតីតជាតិឱ្យផលបច្ចុប្បន្នជាតិ កម្មបច្ចុប្បន្នជាតិហុចផលបច្ចុប្បន្នជាតិ កម្មបច្ចុប្បន្នជាតិហុចផលទៅអនាគតជាតិ)។

៣. ផ្ដត់គំនិតក្នុងអត្ថបទ ដែលនៅតែជាឧត្ដមគតិដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយគឺ៖

- ការប្រកាន់អំពើល្អ វៀរចាកអំពើអាក្រក់
- ការទទួលផលនៃអំពើបាប ដោយការប្រមាថជីវិតគេ ការប្រព្រឹត្ដឈ្នានីស ព្យាបាទគេ
- ការដឹងគុណចំពោះមាតាបិតា ។

៤. ផ្ដត់គំនិតខ្មែរក្នុងរឿងនេះគឺ៖

- ជំនឿអរូបី : ជឿលើការបន់ស្រន់ចំពោះវត្ថុសក្ដិសិទ្ធិ ។
- ជំនឿកម្មផល : ធ្វើអំពើអ្វីបានទទួលផលហ្នឹង ។
- ប្រពៃណី : ការរៀបការត្រូវធ្វើនៅផ្ទះខាងស្រី ។
- ភាពកតញ្ញូ : កូនត្រូវដឹងគុណ និងតបគុណចំពោះមាតាបិតា និងគ្រូឧបជ្ឈាយាចារ្យ ។
- ភក្ដីភាព : ស្ដ្រីខ្មែរតែងរក្សានូវភក្ដីភាព ភាពស្មោះត្រង់ចំពោះស្វាមីជានិច្ច ។

៥. បានជាពុទ្ធិសែនបានរៀបការជាមួយនាងកង្រី ព្រោះមហាឫសីបានក្លែងសំបុត្រយក្សសន្ធមារដែលផ្ញើទៅឱ្យនាងកង្រីថា "បើពុទ្ធិសែនទៅដល់ពេលយប់ឱ្យរៀបការទាំងយប់ ដល់ថ្ងៃរៀបការទាំងថ្ងៃ" ។

បានជាអ្នកនិពន្ធមិនឱ្យពុទ្ធិសែនបានរួមរស់ជាមួយនាងកង្រីជាគូរៀងទៅអនាគត ព្រោះអ្នកនិពន្ធចង់ឱ្យពុទ្ធិសែនបំពេញកាតព្វកិច្ច ជាកូនកតញ្ញូចំពោះអ្នកមានគុណ យ៉ាងក្នុងខណៈ

នោះម្ដាយនិងម្ដាយធំរបស់ពុទ្ធិសែនកំពុងតែមានទុក្ខជាទម្ងន់ ដូច្នេះនេះកាតព្វកិច្ចដែលកូនប្រុសត្រូវបំពេញ ។

៦. បើតាមទស្សនៈរបស់ខ្ញុំ ការបញ្ចប់រឿងដោយឱ្យពុទ្ធិសែន និងនាងកង្រីមិនបានរួមរស់ជាមួយស្វាមីភរិយាលុះអនាគតបែបនេះជាការសមស្រប ព្រោះស្នេហារវាងពុទ្ធិសែននិងនាងកង្រី មិនមែនកើតឡើងពីទឹកចិត្តភក្ដីភាពរបស់អ្នកទាំងពីរទេ គឺកើតឡើងដោយការក្លែងបន្លំរបស់មហាឫសីតែប៉ុណ្ណោះ ម្យ៉ាងទៀតកូនត្រូវតែបំពេញកាតព្វកិច្ចក្នុងនាមជាកូនកតញ្ញូចំពោះអ្នកមានគុណ ជាពិសេសក្នុងគ្រាដែលអ្នកមានគុណកំពុងមានបញ្ហាលំបាក ។

៧. កាលអាកាសនៃរឿង ៖

+កាល : នៅពេលទៅបន់ស្រន់ នៅពេលបំបរបង់កូន នៅពេលយកនាងទាំង១២ឱ្យទៅនៅបម្រើនាងកង្រី ពេលយកនាងកង្រីទៅខ្វេះភ្នែក...។

+អាកាស : នគរយក្ខសន្ធមារ នគរព្រះបាទរថសិទ្ធិ ក្នុងព្រៃជ្រៅក្នុងរណ្ដៅដែលទុកនាងទាំង១២...។

៨. ស្រង់ពាក្យក្លាយឱ្យបានបួនពាក្យពីក្នុងអត្ថបទអំណានរឿង :

- ក្លាយ < លាយ + [ក-] ទម្រង់ "ព-"
- បង្អត់ < អត់ + [បង-] ទម្រង់ "ពសព-"
- ម្ខាង < ខាង + [ម-] ទម្រង់ "ព-"
- ក្សាន្ត < សាន្ត +[ក-] ទម្រង់ "ព-"



# រឿងព្រះពាន់

## អត្ថបទ

កាលពីអតីតកាលកន្លងយូរអង្វែងណាស់ហើយនោះ មានត្រកូលមួយមិនប្រាកដថាឈ្មោះអ្វី បានរស់នៅក្នុងទីនោះ។ កាលអំណើះឥតអំពីប្តីទៅ ប្រពន្ធបានទៅរួមរស់ជាមួយកូនប្រុសម្នាក់ រកស៊ីចិញ្ចឹមជីវិតដោយការធ្វើស្រែជារបរប្រចាំគ្រួសារ។ រៀងរាល់ព្រឹកម្តាយតែងតែឱ្យកូនប្រុសទៅភ្ជួរស្រែ លុះដល់ថ្ងៃបន្តិចទើបម្តាយទូលបាយសម្លទៅឱ្យកូនឯស្រែនោះជាខាងក្រោយ។

ថ្ងៃមួយដោយម្តាយជាប់រវល់ក្នុងកិច្ចការផ្ទះជាច្រើនផង ដោយអាងថាកូនប្រុសប្រហែលជាមិនទាន់ឃ្លានបាយណាស់ណាផង ក៏បង្អែរបង្អង់ឱ្យយឺតបន្តិចជាងរាល់ថ្ងៃ។ ចំណែកកូនប្រុសដែលទៅភ្ជួររាស់ឯស្រែនោះឃ្លានបាយណាស់ ទន្ទឹងមើលផ្លូវម្តាយស្ទើរក្រហមភ្នែក មិនឃើញម្តាយយកបាយទៅឱ្យសោះ ក៏បានពោលពាក្យប្រមាថមើលងាយជាច្រើនដោយពាក្យពុំសមរម្យ។ ម្តាយ កាលដែលបានរួចរវល់អស់ហើយក៏រៀបចំដួសបាយដាក់ក្នុងត្រឡោក ហើយញាត់ឱ្យណែន ដោយគិតថាកាលណាកូនគាត់ស៊ីបាយរួចហើយ យកត្រឡោកនេះដងទឹកផឹកតែម្តង ជាការងាយស្រួលជាងដាក់បាយនឹងយកមកវិញ។

កូនកម្លោះគាត់ដែលកំពុងឃ្លានបាយខ្លាំង កាលបើឃើញម្តាយទូលបាយតែបន្តិចដាក់ក្នុងត្រឡោកយកទៅឱ្យខ្លួនដូច្នោះ នឹកខឹង

ណាស់ ដោយស្មានថាខ្លួនស៊ីបាយមិនឆ្អែត ក៏និយាយពាក្យទ្រគោះទាំងជ្រុលហួសដល់វាយដំម្ដាយលុះត្រាម្ដាយសន្លប់បាត់ស្មារតីក្នុងពេលនោះ។ លុះដល់ស៊ីបាយក្នុងត្រឡោកនោះទៅ វាស៊ីមិនអស់ ទើបដឹងថាខ្លួនធ្វើនេះខុស ហើយងាកមកសុំខមាលទោសម្ដាយវិញ។ ម្ដាយឆ្លើយថា ម្ដាយគ្មានទោសឱ្យកូនទេ គឺជាទោសរបស់វដ្ដៈទេ បើកូនចង់បានរួចកម្មពៀរនេះ ត្រូវកូនកសាងព្រះពុទ្ធរូប១ពាន់ នៅលើផ្ទាំងថ្មដាមួយយ៉ាងធំ កាលណាបើព្រះពុទ្ធរូបទាំងនេះរបេះរលុបរលាយបាត់កាលណា ពេលនោះទើបកូនរួចអំពីកម្មពៀរនេះ។ ម្ដាយផ្ដាំរួចស្រេចហើយក៏ធ្វើមរណកាលទៅកាន់បរលោកទៅ។

កូនប្រុសនេះក៏បានធ្វើតាមបណ្ដាំម្ដាយ ដោយយកថ្មមួយធំមករចនាជាព្រះពុទ្ធរូបជុំវិញជាជាន់ៗជាច្រើនរយអង្គ ហើយតម្កល់ទុកក្នុងកន្លែងនេះរហូតមកដល់សព្វថ្ងៃ។ អ្នកស្រុកជិតខាងបានសន្មតហៅកន្លែងនេះថា "ព្រះពាន់" រហូតមកដល់សព្វថ្ងៃនេះ។

ជារៀងរាល់ឆ្នាំអ្នកស្រុកជិតខាងគេតែងនាំគ្នាទៅធ្វើបុណ្យទានផ្សេងៗនៅកន្លែងនេះពុំដែលខាន។

**សំណួរ**

១. តើរឿងនេះ ចាត់ទុកជាអក្សរសិល្ប៍ប្រភេទអ្វី? ចូររកអំណះអំណាងបញ្ជាក់។

២. តើអំពើរបស់កូនប្រុសដែលបានប្រព្រឹត្តចំពោះម្ដាយនោះជាអំពើយ៉ាងដូចម្ដេច? ហេតុអ្វី?

៣. តើម្ដាយរបស់កូនប្រុសនោះមានឥរិយាបថយ៉ាងដូចម្ដេចចំពោះអំពើរបស់កូនប្រុសគាត់?
៤. ហេតុដូចម្ដេចបានជាកូនប្រុសនោះសុំខមាលទោសចំពោះម្ដាយវិញ? តើការសុំខមាលទោសនេះគេធ្វើនៅពេលណាខ្លះ? ចំពោះមុខអ្វីដែរ?
៥. តើចំណុចណាខ្លះដែលបញ្ជាក់ពីផ្នត់គំនិត?
៦. តើរឿងនេះបានបង្ហាញពីលក្ខណៈគជៈរបស់រឿងយ៉ាងណាខ្លះ?
៧. ចូរសិក្សាពីកាលអាកាសនៃរឿង ។

ចម្លើយ

១. រឿងនេះ ចាត់ទុកជាអក្សរសិល្ប៍ប្រជាប្រិយ ព្រោះជារឿងដែលចាស់តំណាលតៗគ្នា គ្មានអ្នកនិពន្ធពិតប្រាកដ ហើយរឿងនេះនិយាយពីជំនឿរបស់ជនជាតិខ្មែរតាំងពីបុរាណកាលមក ។
២. អំពើរបស់កូនប្រុសដែលបានប្រព្រឹត្តចំពោះម្ដាយនោះជាអំពើអកតញ្ញូ សាហាវយង់ឃ្នងជាទីបំផុត ព្រោះម្ដាយជាអ្នកមានគុណ ជាអ្នកបង្កើតកូនដោយលំបាកវេទនា ។ អំពើនេះកើតចេញមកពីទោសៈ ដោយពុំអាចទប់ស្កាត់នូវសេចក្ដីស្រេកឃ្លានបាន ។
៣. ឥរិយាបថរបស់ម្ដាយក្រោយពីកូនវាយឱ្យសន្លប់ហើយ គឺគាត់មិនខឹងកូនប្រុសគាត់ទេ ព្រោះគាត់ថានេះជាទោសនៃវដ្ដៈ ថែមទាំងបានណែនាំឱ្យកូនគាត់កសាងព្រះពុទ្ធរូប១ពាន់នៅលើផ្ទាំងថ្មជាមួយយ៉ាងធំ ដើម្បីរំដោះកម្មពៀរ ។
៤. បានជាកូនប្រុសនោះសុំខមាលទោសចំពោះម្ដាយវិញ ព្រោះ៖

- ដឹងកំហុសខ្លួន ក្រោយពីស៊ីបាយក្នុងត្រឡោកមិនអស់ ។
- មានវិប្បដិសារៈចំពោះទង្វើរបស់ខ្លួន
- ចង់រំដោះកម្មពៀរដែលខ្លួនបានប្រព្រឹត្តចំពោះម្ដាយ ។

ការសុំខមាលទោសនេះគេធ្វើនៅពេលដែលគេបានប្រព្រឹត្តអំពើអ្វីមួយខុសឆ្គងទៅលើនរណាម្នាក់ ឬអ្វីមួយ ។ គេសុំខមាលទោសនៅចំពោះមុខបុគ្គលដែលគេបានធ្វើខុស. ចំពោះមុខវត្ថុសក្ការៈ ឬវត្ថុសក្ដិសិទ្ធិនានា មានព្រះពុទ្ធរូបជាដើម ។

៥. ចំណុចដែលបញ្ជាក់ពីផ្នត់គំនិត៖
- ព្រហ្មវិហារធម៌របស់ម្ដាយចំពោះកូន
- ការចេះភ្ញាក់រលឹកចំពោះកំហុសរបស់ខ្លួន
- ការគោរពចំពោះវត្ថុសក្ដិសិទ្ធិ
- ការគោរពពុទ្ធសាសនា
- ការជឿលើកម្មពៀរ

៦. លក្ខណៈគតិៈរបស់រឿង៖
- ការប្រកបរបរធ្វើស្រែចំការ
- ការប្រើអំពើហិង្សាក្នុងគ្រួសារ
- ការគោរពជំនឿពុទ្ធសាសនា
- មោហៈជាមូលហេតុនៃទោសៈ
- ទោសៈធ្វើមនុស្សបាត់បង់គុណធម៌
- អ្នកប្រព្រឹត្តទោសកំហុសត្រូវមានកម្មពៀរ

៧. កាលអាកាសនៃរឿង៖

+កាល : ថ្ងៃមួយ ពេលភ្ជួរដី...
+អាកាស : នៅផ្ទះ នៅស្រែ នៅលើថ្មដា...



## បញ្ចេញមតិវាយតម្លៃតួអង្គក្នុងរឿង

**សំណួរ**

១. តើមតិទីមួយវាយតម្លៃដូចម្ដេចចំពោះមូលហេតុនៃការស្លាប់របស់នាងកង្រី?

២. តើមតិទី២វាយតម្លៃដូចម្ដេចដែរ?

៣. តើគំនិតណាខ្លះជាគំនិតដែលឯកភាពគ្នាភាគច្រើន? ហើយគំនិតនោះ ពួកគេបានឱ្យតម្លៃទៅលើអ្វីជាធំ? ហេតុអ្វី?

៤. តើការវិភាគទាំងនោះ គេបានឈរលើកត្ដាអ្វីខ្លះ? តើកត្ដាទាំងនោះសមស្របដែរឬទេ? ព្រោះអ្វី?

**ចម្លើយ**

១. មតិទីមួយវាយតម្លៃចំពោះមូលហេតុនៃការស្លាប់របស់នាងកង្រីថា បណ្ដាលមកពីពុទ្ធិសែនបោះបង់ចោលនាង ទើបបណ្ដាលឱ្យនាងឈឺចិត្តរហូតដល់ស្លាប់។

២. មតិទី២វាយតម្លៃថាការស្លាប់របស់នាងកង្រីបណ្តាលមកពីយក្សសន្ធមារជាម្តាយនាងកង្រី ដែលបានធ្វើបាបម្តាយ និងម្តាយធំរបស់ពុទ្ធិសែន ជាហេតុបណ្តាលឱ្យពុទ្ធិសែនត្រូវជ្រើសរើសអ្នកមានគុណដើម្បីបំពេញកាតព្វកិច្ចជាកូនកតញ្ញូ។

៣. គំនិតដែលឯកភាពគ្នាភាគច្រើនគឺមតិទី២ ព្រោះក្នុងស្ថានភាពនោះពុទ្ធិសែនត្រូវតែជ្រើសរើសយកម្តាយ ឯនាងកង្រីពុំលំបាកវេទនាដូចម្តាយខ្លួននោះទេ។ គំនិតនោះ ពួកគេបានឱ្យតម្លៃទៅលើភាពកតញ្ញូជាធំ ព្រោះក្នុងនាមជាកូនត្រូវមានភាពកតញ្ញូចំ-ពោះអ្នកមានគុណដែលខំបង្កើត និងចិញ្ចឹមបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំ។

៤. ការវិភាគទាំងនោះ គេបានឈរលើកត្តាផ្នត់គំនិតខ្មែរ និងស្ថានភាពជាក់ស្តែង៖

- ការពិចារណាប្រកបទៅដោយមនសិការ ដោយការដឹងគុណ(កតញ្ញូ)
- ការទទួលខុសត្រូវចំពោះជោគវាសនានគរ (កំចាត់សន្ធមារដើម្បីភាពសុខសាន្តរបស់នគរ)
- លក្ខណៈប្រាកដនិយម (មាតាកំពុងមានទុក្ខ កង្រីមិនមានការលំបាកខ្លាំង)

កត្តាទាំងនោះពិតជាសមស្រប ព្រោះជាដំណោះស្រាយប្រកបដោយការពិចារណានិងតាមកាលៈទេសៈ។

## លំហាត់

ចូរអ្នកធ្វើការបញ្ចេញមតិវាយតម្លៃតួអង្គ "ព្រះបាទរថសិទ្ធ និង មហាឫសី" ក្នុងរឿងភ្នំនាងកង្រី ដែលអ្នកបានសិក្សារួចមកហើយ ។

១. ព្រះបាទរថសិទ្ធ

តាមរយៈសកម្មភាពរបស់តួអង្គបញ្ជាក់ថា ព្រះអង្គជាមនុស្សមានទឹកចិត្តមេត្តាចំពោះអ្នកកំសត់ទុរគត ប៉ុន្តែព្រះអង្គក៏ជាមនុស្សល្មោភកាមតណ្ហាស្រើបស្រាល និងស្នេហា ហើយជាមនុស្សខ្វះការទទួលខុសត្រូវ ខ្វះភក្តីភាព ចិត្តស្រាល ខ្វះការត្រិះរិះពិចារណា ឆាប់ជឿលើសម្ដីញុះញង់របស់អ្នកដទៃរហូតធ្វើឱ្យប្រពន្ធទាំង១២នាក់រងទុក្ខយ៉ាងវេទនា។ លុះដឹងការពិតហើយ ព្រះអង្គក៏ផ្ដល់ឱកាសឱ្យពុទ្ធិសែនឡើងស្នងរាជ្យជំនួសព្រះអង្គ ។

២. មហាឫសី

តាមរយៈសកម្មភាពរបស់មហាឫសីបញ្ជាក់ថា មហាឫសីគឺជាមនុស្សវាងវៃមានចំណេះដឹងយល់ ដឹងគ្រប់ហេតុការណ៍ មានចិត្តសប្បុរស ជួយសង្គ្រោះជីវិតឫទ្ធិសែនឱ្យរួចពីសេចក្ដីស្លាប់ ដើម្បីបានបំពេញតួនាទីជាកូនកតញ្ញូ។

មេរៀនទី ២

# ចំនៀមចម្លាប់



## នំមិនធំជាងនាឡិ

### សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងណា? អ្នកនិពន្ធឈ្មោះអ្វី? និពន្ធនៅឆ្នាំណា?

២. តើក្នុងអត្ថបទគេចែកជាប៉ុន្មានគំនិតសំខាន់?

៣. ចូរពន្យល់ឃ្លា "កូនគោកៀចកាច និងនំមិនធំជាងនាឡិ" ។

៤. តើអត្ថបទនេះឆ្លុះបញ្ចាំងឱ្យឃើញពីទស្សនៈរៀបចំទុកដាក់កូនចៅរបស់ខ្មែរយើងនៅសម័យមុនយ៉ាងដូចម្ដេចខ្លះ?

៥. ចូរបង្ហាញកាព្យរូបារម្មណ៍ដែលប្រើក្នុងកំណាព្យនេះ?

៦. ចូរអ្នកបកស្រាយគំនិតសំខាន់បង្កប់ក្នុងវគ្គខាងក្រោម :

ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី<br>
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ ។

### ចម្លើយ

១. -អត្ថបទនេះដកស្រង់ចេញពីរឿងទុំទាវ

-អ្នកនិពន្ធឈ្មោះភិក្ខុសោម (ងួន សោម)

-និពន្ធនៅឆ្នាំ១៩១៥

២. ក្នុងអត្ថបទគេចែកជាបីគំនិតសំខាន់ គឺ ៖

-គំនិតសំខាន់ទី១ ចាប់ពីវគ្គទី១ ដល់វគ្គទី១១ និយាយពីអរជូន និងភរិយាជំនុំគ្នារឿងស្តីដណ្តឹងនាងទាវឱ្យម៉ឺនងួន ។

-គំនិតសំខាន់ទី២ ចាប់ពីវគ្គ១២ ដល់វគ្គទី២៧ និយាយពីអរជូន និងភរិយាបញ្ជូនគ្រឿងបណ្ណាការទៅស្តីដណ្តឹងនាងទាវ ។

-គំនិតសំខាន់ទី៣ ចាប់ពីវគ្គ២៨ ដល់ វគ្គទី៣៧ និយាយពីម្តាយទាវបង្ខំទាវឱ្យព្រមរៀបការជាមួយម៉ឺនងួន ។

៣. ពន្យល់ឃ្លា "កូនគោកាចក្បៀច និងនំមិនធំជាងនាឡិ"

- "កូនគោកាចក្បៀច"

+ន័យចំ : មានន័យថា កូនគោដែលពិបាកដឹក ក្រាញទន្ទៀល ។

+ន័យធៀប : មានន័យថាកូនដែលពិបាកអប់រំណែនាំ មិនស្តាប់ដំបូន្មានឪពុកម្តាយ ។

- **"នំមិនធំជាងនាឡិ"**

+ន័យចំ : មានន័យថា "នាឡិ" ជារង្វាល់សម្រាប់វាល់ ឬដាក់វត្ថុផ្សេងៗ ។ ដូចនេះនំត្រូវតូចជាងរង្វាល់នោះ ។

+ន័យធៀប : មានន័យថា "នាឡិ" សំដៅលើឪពុកម្តាយ ។ ឯ "នំ" សំដៅលើ "កូន" ។ ដូចនេះកូនត្រូវស្តាប់បង្គាប់ឪពុកម្តាយ មិនត្រូវធ្វើអ្វីៗតាមអំពើចិត្តរបស់ខ្លួនទេ ។

៤. អត្ថបទនេះឆ្លុះបញ្ចាំងឱ្យឃើញពីទស្សនៈរៀបចំទុកដាក់ទុកដាក់កូនចៅរបស់ខ្មែរយើងនៅសម័យមុនគឺឪពុកម្តាយជាអ្នករៀបចំទុកដាក់ឱ្យ ចំណែកកូនគ្មានសិទ្ធិតវ៉ា ឬយកប្តីតាមចិត្ត

របស់ខ្លួនបានឡើយ (នំមិនធំជាងនាឡិ) ។

៥. រូបារម្មណ៍ដែលប្រើក្នុងកំណាព្យនេះគឺ ៖

-សោតរូបារម្មណ៍: កវីប្រើវិធីរណ្ដំព្យញ្ជនៈឱ្យចាប់ចិត្តដូចជា : លីលាលយលង់ដានដងផ្លូវ ត្រូវត្រង់មាគ៌ាឃ្មាតខ្ចួល ខ្ទាញ់...។

-ឧបមានរូបារម្មណ៍: ...វេលាក្រោយនោះចំពោះជា ម្ដាយទាវម្ចីម្នាដូចអរណាស់...។

-ចក្ខុរូបារម្មណ៍ : ក្រឡេកក្រលៀងឆ្វៀងពីអាយ ច្បាស់ជានាងម្ដាយទាវនិមល...។

-វេទនារូបារម្មណ៍ : កវីរៀបរាប់ពីកំហឹងរបស់ម្ដាយទាវ : ...មិនដែលសោះឡើយទាវអើយន៎ ប្រឡើសបើសធំម្ដេចជាងនាឡិ កូនគោកាចកៀចដោយព្រៃវាល រោលរាលឈឺខ្លួនជូនដល់ស្លាប់ ។

-និមិត្តរូបារម្មណ៍ : (ក្នុងវគ្គវេទនារូបារម្មណ៍ខាងលើ) នំ ជាតំណាងឱ្យកូន ចំណែកនាឡិ ជាតំណាងឱ្យម្ដាយឪពុក ។

៦. បកស្រាយគំនិតសំខាន់បង្កប់ក្នុងវគ្គខាងក្រោម :

ថាបើម៉ែព្រមល្មមនឹងគេ កូនម៉ែទំនេរមានប្រុសស្រី
លើកឱ្យគេទៅទោះពីរបី តាមម៉ែមេត្រីឱ្យថ្វីខ្ញុំ ។

-អត្ថន័យក្នុងវគ្គនេះបង្ហាញថាទាវប្រកែកតវ៉ានឹងម្ដាយមិនព្រមតាមម្ដាយដែលលើកខ្លួនឱ្យទៅម៉ឺនងួនទេ ហើយថែមទាំងឆ្លើយបញ្ឈឺឱ្យម្ដាយថា មានកូនប្រុសស្រីពីរបីក្រៅពីនាងលើកឱ្យ

គេទៅ ចំណែកនាង១មិនព្រមជាដាច់ខាត ។

## កំណាព្យបទទ្វេមាត្រ

*ខ– កំណាព្យបទទ្វេមាត្រ គឺជាបទដែលកវីប្រើកាព្យមាត្រ២ មួយជាកាព្យមាត្របទមូលដ្ឋាន ហើយបន្ថែមកាព្យមាត្រថ្មីមួយទៀត លើបទមូលដ្ឋានទាំងអស់នោះ ។*

១. បទគោព័ទ្ធស្ទឹងពាក្យ៧



## ២. បទអក្សរល្បួនពាក្យ៧



## ៣. បទសត្វកាងស្លាប



៤. បទឆត្របីជាន់ ពាក្យ៨



លំហាត់

១. ចូរអ្នកតែងកំណាព្យបទទ្វេមាត្រដូចខាងក្រោមនេះ ដោយបទនីមួយៗឱ្យបានពីរវគ្គ :

-បទអក្សរល្បួនពាក្យ៧

-បទសត្វកាងស្លាប

-បទឆត្របីជាន់

២. ចូរអ្នកស្រាវជ្រាវរកកំណាព្យបទទ្វេមាត្រផ្សេងៗ ឱ្យបាន៦បទ ដោយបង្ហាញពីកាព្យមាត្រនៃបទទាំងនោះនូវ :

-ចំណាប់ចួន.

-ផ្ទួន

-រណ្តំ

ចម្លើយ

១. (សិស្សតែងខ្លួនឯង)

២. ស្រាវជ្រាវរកកំណាព្យបទទ្វេមាត្រ :

បទពាក្យ៧ (ពាក្យ៧)

កម្ពុជាតូចពិតសម្បត្តិមាន មានគ្រប់ធនធានសំបូរផល

ផលរ៉ែព្រៃព្រឹក្សទឹកសម្បូរតែផ្តល់ ផ្តល់សត្វរស់ក្នុងព្រៃឈើ ។

បទពាក្យ៨ (ពាក្យ៨)

ជនជាតិខ្មែរគួរតែចាំឱ្យច្បាស់ ច្បាស់ជាមិនវិបល្លាសវប្បធម៌ថេរ

ថេរវប្បធម៌ជាតិជាតិនៅកេរ កេរពូជខ្មែរក៏ថេររុងរឿងថ្លា ។

បទអក្សរលូនពាក្យ៧

រឿងរៀមរីងរៃងរិះរៀងរាល់ ទោរទន់ទុក្ខទ័លទៀតទៀងទាត់

សុបសៅស៊ើបសួរសង្សារសត្វ កែវកាត់កាមក្ដុចកែកើ្វកាយ ។

បទអក្សរសង្វាស

បើដើរទៅប្រាប់គេនឹងដឹង តាមស្នាមដំណើងនឹងមករក

បាត់ស្វាត់ប្រយ័ត្នក្រែងមកជ្រក សុខទុក្ខគេភ្នករកវាយមាយ ។

បទកន្ត្រៃបលោតឈើគោក

ប្រុសកែប្រែកាយប្រាយកាច់ ស្រីខ្ជូបស្រុបខ្ជាចស្រេចខ្លួន

ផ្ដេកចិត្តផ្ចិតចូលផ្ដលច្ចូន ពៀរខ្លួនពួនខ្ជប់ពប់ខ្ចាំង ។

បទផ្កាឈូករីកពាក្យ៨

រស់នៅត្រូវរស់ក្នុងផ្លូវចម្រើន រស់នៅត្រូវបង្កើនសាមគ្គីជាតិ
រស់នៅត្រូវតស៊ូមិនរវាត រស់នៅដើម្បីជាតិទើបថ្លៃថ្លា ។

## កំលាយដោយផ្នត់ដែក

ខ–៖ *ផ្នត់ដែក គឺជាផ្នត់កំលាយដែលជ្រែកនៅកណ្ដាលពាក្យឫស ដើម្បីបង្កើតពាក្យក្លាយ ។* ផ្នត់ដើមមានទម្រង់បួនយ៉ាងគឺ ៖ *"-ព-" "-សព-" "-ស/ព-" និង "-សព/ព-" ។*

១. ទម្រង់ "_ព_" : មានផ្នត់ [-ន-] [-ប-] [-ម-]

២. ទម្រង់ "_សព_" : មានផ្នត់ [-អ់ង-] [-អ៊់ង-] [-អ់ន-] [-អ៊់ន-] [-អ់ម-] [-អ៊់ម-] [-អ់ញ-]

៣. ទម្រង់ "_ស/ព_" : មានផ្នត់ [-អ៊/ន-] [-អ៊/ប-] [-អ៊ោ/ប-]

៤. ទម្រង់ "_សព/ព_": មានផ្នត់ [-អ់ម/ន-] [-អ៊់ម/ន-]

**លំហាត់**

១. ចូរអ្នករកពាក្យក្លាយដែលកើតឡើងពីពាក្យឫសខាងក្រោមនេះ ដោយបង្ហាញទម្រង់ផង : លង រាប រាំង លាយ ត្រាយ គិត

សោក។

២. ចូរអ្នកស្វែងរកពាក្យឫសនៃពាក្យក្លាយខាងក្រោម ដោយប្រាប់ពីទម្រង់ផង :

ក) ចំណែក ល្បែង រនាស់ ស្នូម ជំរាប សម្ល ខ្នើត កំទេច របើស

ខ) [...]

ឧកញ៉ាអរជូនមាំមួនពេក ធម្មតាក្រោមមេឃទាបជាងភ្នំ
មានឫទ្ធិអំណាចឥតជំនុំ កាប់ចាក់វាយដំពុំប្រណី។
គួរហើយខ្ញុំសុំជំរាបញាតិ ទៅសំពះបាទលោកប្រុសស្រី
ថាបើលោកចង់ចងមេត្រី គប្បីចាំខ្ញុំលបសួរកូន។
នាងអ្នកស្ដាប់ជាក់ចាំរាល់ថ្ងៃ រួចលើកភស្តុភាជាជំនូន
ប្រគល់ម្ដាយទាវស្រេចអង្គឱន លំទោនលើកប្រណិប័តន៍លា។ [...]

**ចម្លើយ**

១. រកពាក្យក្លាយដែលកើតឡើងពីពាក្យឫស : លង រាប រាំង លាយ ត្រាយ គិត សោក។

-លង > ល្បង ផ្នត់ (-ប-) ទម្រង់ "-ព-"

-រាប > រនាប ផ្នត់ (-អ៊/ន-) ទម្រង់ "-ស/ព-"

-រាំង > រនាំង ផ្នត់ (-អ៊/ន-) ទម្រង់ "-ស/ព-"

-លាយ > ល្បាយ ផ្នត់ (-ប-) ទម្រង់ "-ព-"

-ត្រាយ > តម្រាយ ផ្នត់ (-អ ម-) ទម្រង់ "-សព-"

-គិត > គំនិត ផ្នត់ (-អ៊ ម/ន-) ទម្រង់ "-សព/ព-"

-សោក > សំណោក ផ្នត់(-អ ម/ណ-) ទម្រង់ "-សព/ព-"

២. រកពាក្យឫសនៃពាក្យក្លាយខាងក្រោម :

ក) ចំណែក ល្បែង រនាស់ ស្មូម ជំរាប សម្ល ខ្មើត កំទេច របើស

-ចំណែក < ចែក ផ្នត់ (-អំ ម/ន-) ទម្រង់ "-សព/ព-"

-ល្បែង < លេង ផ្នត់ (-ប-) ទម្រង់ "-ព-"

-រនាស់ < រាស់ ផ្នត់ (-អ៊/ន-) ទម្រង់ "-ស/ព-"

-ស្មូម < សូម ផ្នត់ (-ម-) ទម្រង់ "-ព-"

-ជំរាប < ជ្រាប ផ្នត់ (-អ៊ំ ម/ន-) ទម្រង់ "-សព/ព-"

-សម្ល < ស្ល ផ្នត់ (-អំ ម-) ទម្រង់ "-សព-"

-ខ្មើត < កើត ផ្នត់ (-ន-) ទម្រង់ "-ព-"

-កំទេច < ខ្ទេច ផ្នត់ (-អំ ម-) ទម្រង់ "-សព-"

-របើស < រើស ផ្នត់ (-អ៊/ប-) ទម្រង់ "-ស/ព-"

ខ) ពាក្យក្លាយក្នុងអត្ថបទខាងលើ

-អំណាច < អាច ផ្នត់ (-អំ ម/ន-) ទម្រង់ "-សព/ព-"

-ជំនុំ < ជុំ ផ្នត់ (-អ៊ំ ម/ន-) ទម្រង់ "-សព/ព-"

-ជំរាប < ជ្រាប ផ្នត់ (-អ៊ំ ម/ន-) ទម្រង់ "-សព/ព-"

-ជំនូន < ជូន ផ្នត់ (-អ៊ំ ម/ន-) ទម្រង់ "-សព/ព-"



# ប្រពៃណីនៅពេលកើត

សំណួរ

១. តើប្រពៃណីនៅពេលកើតចែកជាប៉ុន្មានដំណាក់កាល?

២. តើស្ត្រីដែលមានផ្ទៃពោះត្រូវប្រកាន់ត្រណមដូចម្តេចខ្លះមុនពេលកើត?

៣. តើគេធ្វើអ្វីខ្លះនៅពេលកើត?

៤. តាមរយៈអត្ថបទអំណាននេះ ចូរប្រាប់ពិធីមួយចំនួនដែលខ្មែរយើងតែងតែប្រារព្ធឡើងនៅដំណាក់ក្រោយពេលកើត។

៥. តាមការសង្កេតរបស់អ្នក តើពិធីទាំងប៉ុន្មានក្រោយពេលកើត តើមានពិធីណាខ្លះដែលបាត់បង់ ហើយពិធីណាខ្លះដែលខ្មែរយើងបន្តប្រតិបត្តិរហូតដល់បច្ចុប្បន្ន?

៦. ការសម្រាលកូន (កើត) តាមបែបបុរាណ និងសម័យបច្ចុប្បន្ន តើមួយណាមានសុវត្ថិភាពជាង? ហេតុអ្វី?

ចម្លើយ

១. ប្រពៃណីនៅពេលកើតចែកជាបីដំណាក់កាល គឺមុនពេលកើត ពេលកើត និងក្រោយពេលកើត។

២. មុនពេលកើត ស្ត្រីដែលមានផ្ទៃពោះត្រូវប្រកាន់ត្រណមដូចតទៅ

-មិនត្រូវបរិភោគអាហារមានរសហឹរនាំឱ្យក្រហល់ក្រ-

ហាយដល់កូនក្នុងផ្ទៃ

-មិនត្រូវស្លៀកពាក់តឹងពេកនាំឱ្យចង្អៀតចង្អល់ដល់កូនក្នុងផ្ទៃ

-មិនត្រូវឈោងយករបស់ដែលនៅខ្ពស់ផុតពីដៃនាំឱ្យរបូតទងសុកពីមាត់កូន

-មិនត្រូវបរិភោគបបរនាំឱ្យកូនកើតមកមិនស្អាត( មិនជ្រះ)

-បើមានសរ្សៃគ្រាស ឬចន្ទគ្រាសត្រូវយកកំបោរមកលាបលើផ្ទៃដើម្បីជួយសង្កត់ទារកនៅក្នុងផ្ទៃកុំឱ្យមានការភ្ញាក់ផ្អើលនឹងមហិទ្ធិឫទ្ធិរាហូ បើមិនបានធ្វើបែបនេះទេ កូនកើតមកទៅជាល្ងិល្ងើមិនគ្រប់ដប់ ( អ្នកខ្លះហៅថាកូនគ្រាសកន្លង)

-មិនត្រូវដេកថ្ងៃ ងូតទឹកយប់នាំឱ្យកូនថ្លោសពិបាកកើត

-មិនត្រូវអង្គុយនៅមាត់ទ្វារ ឬមាត់ជណ្តើរខ្លាចកូនកើតមិនរួច

-មិនត្រូវដេកដំអក់ ត្រូវរហ័សរហួនក្រោកមុនប្តី ទើបឱ្យកូនកើតបានស្រួល

-លើសពីនេះត្រូវរកថ្នាំជាជំនួយឱ្យសម្រាលកូនបានរហ័សទុកស្ងោរផឹកនៅពេលជិតគ្រប់ខែ។

៣. នៅពេលកើត គេរៀបចំពិធីបន់ស្រន់វត្ថុសក្តិសិទ្ធិ ឬអ្នកដូន អ្នកតា សុំឱ្យការឆ្លងទន្លេប្រព្រឹត្តទៅដោយសុខសប្បាយ កុំបីជួបនឹងគ្រោះថ្នាក់ ឬឧបសគ្គណាមួយឡើយ។ ឯបុរសជាប្តី ឬជាឪពុក ឬជាបងប្អូនត្រូវរត់ទៅតាមឆ្មបដែលនៅក្នុងភូមិជិតឬឆ្ងាយឱ្យមកជួយសម្រាល។

៤. ពិធីមួយចំនួនដែលខ្មែរយើងតែងតែប្រារព្ធឡើងនៅដំណាក់កាលក្រោយពេលកើត៖

-ស្ត្រីឆ្លងទន្លេចត្រូវដេកអាំងភ្លើងចំនួន៣ថ្ងៃ ឬមួយអាទិត្យ

-អញ្ជើញអាចារ្យសូត្រមន្តព័ទ្ធអំបោះនៅជុំវិញ។ គេអាចគូសខ្មៅងនៅលើសសរដោយកំបោរឬបិទខ្មៅងដោយក្រមួនសុទ្ធក៏បាន។

-គេយកកាំបិត កន្ត្រៃទៅដាក់លើក្បាលដំណេកកូនខ្ចី

មិនឱ្យអ្នកអាំងភ្លើងក្រោកពីដំណេក និយាយឆ្លើយឆ្លងជាមួយភ្ញៀវឬញាតិមិត្តដែលមកសាកសួរសុខទុក្ខនោះទេ ប៉ុន្តែគេអាចនិយាយជាមួយអ្នកថែភ្លើងបាន។

-ពិធីទម្លាក់ជើងក្រាន

-ពិធីជូនរង្វាន់ និងសុំខមាលទោសឆ្មប

-ពិធីបើកភ្នែក

-ពិធីកាត់សក់ព្រៃ

-ពិធីហៅព្រលឹង ឬជញ្ជាត់ព្រលឹង

-បន្ទាប់មកគេត្រូវយកស្រូវពន្លៃបិទត្រង់បង្កើយរបស់ទារក ហើយផ្លាស់ប្តូរវារាល់ថ្ងៃ។ ការបិទពន្លៃនេះមានរយៈពេលរហូតដល់៧-៨ខែ។

-ទីបញ្ចប់ឆ្មបដែលជាអ្នកដឹកនាំពិធីក៏បានអុជទៀនធូបដោតលើតង្វាយផ្សេងៗ ហើយអញ្ជើញអស់ដូនតាឱ្យមកទទួលតង្វាយនេះ និងប្រសិទ្ធពរដល់កូនចៅ។ ឪពុកម្តាយ

បងប្អូន មិត្តភក្តិចូលមកម្តងម្នាក់ៗទៅប្រោះព្រំឱ្យពរជ័យដល់ទារកនិងចងដៃទារកតាមធនធានដែលខ្លួនមាន ។

៥. តាមការសង្កេតរបស់ខ្ញុំ ពិធីទាំងនេះគេពុំសូវអនុវត្តក្នុងពេលបច្ចុប្បន្ននេះទេ នៅសល់តែស្រុកស្រែចម្ការខ្លះដែលនៅរក្សាជំនឿទំនៀមទម្លាប់នេះនៅឡើយ ។

- ពិធីដែលស្ទើរតែបាត់បង់មាន៖ ពិធីអាំងភ្លើង ពិធីទម្លាក់ជើងក្រាន ពិធីកប់សុក ពិធីបើកភ្នែក ពិធីជូនរង្វាន់សុំខមាលទោសឆ្មប ពិធីកាត់សក់ព្រៃ ។
- ពិធីដែលខ្មែរយើងនិយមហើយនៅតែបន្តប្រតិបត្តិរហូតដល់បច្ចុប្បន្ននេះមាន៖ ពិធីបង្កក់កូន ពិធីហៅព្រលឹង ការយកកាំបិត កន្ត្រៃដាក់លើក្បាលដំណេកទារក ។ល ។

៦. កាលសម្រាលកូនបែបសម័យបច្ចុប្បន្ន មានសុវត្ថិភាពជាងការសម្រាលកូនតាមបែបបុរាណ ព្រោះការសម្រាលកូនតាមបែបបច្ចុប្បន្ន ឬតាមបែបវេជ្ជសាស្ត្រមានគ្រូពេទ្យដែលមានជំនាញច្បាស់លាស់ និងមានឧបករណ៍គ្រប់គ្រាន់ ។ ចំណែកឆ្មបបុរាណពុំបានរៀនសូត្រជំនាញខាងវិជ្ជាឆ្មបទេ គឺគ្រាន់តែចេះដឹងតៗគ្នាតាមរបៀបអ្នកស្រុកប៉ុណ្ណោះ ។

 

# ជំនឿ

## អត្ថបទ

កាលពីយូរលង់កន្លងមក មនុស្សលោកតែងជួបប្រទះបាតុ-ភូតធម្មជាតិផ្សេងៗដែលខ្លួនពុំអាចជំនះបាន ។ ដោយមានការភ័យខ្លាច ចំពោះអសន្តិសុខ មនុស្សចេះតែមានសេចក្ដីសង្ស័យយ៉ាងនេះយ៉ាងនោះ ។ ពួកគេតែងសង្ស័យថា មានកម្លាំងក្រៅខ្លួនដ៏ខ្លាំងក្លាអាចធ្វើឱ្យមនុស្សបានសេចក្ដីសុខ និងអាចធ្វើឱ្យមនុស្សមហន្តរាយ ។ ពួកគេចាប់ផ្ដើមមានជំនឿលើកម្លាំងទាំងនោះ ហើយសន្មតឈ្មោះនិងបង្កើតជារូបរាងផ្សេងៗតាមសមត្ថភាពរបស់ពួកគេ ។ កម្លាំងក្រៅខ្លួនទាំងនោះក្លាយជាជាពឹងទីរលឹក ។ ដើម្បីបានសេចក្ដីសុខសប្បាយពួកគេតែងធ្វើអំពើល្អនិងធ្វើពិធីបូជា បន់ស្រន់ អង្វរតាមរបៀបផ្សេងៗ ។ ខ្មែរយើងមានជំនឿច្រើនដូចជា ជំនឿលើព្រលឹងឪពុកម្ដាយ ។

ម្ដាយឪពុកមានគុណធ្ងន់មកលើកូន ទុកដូចជាព្រះនៅក្នុងផ្ទះ កូនត្រូវដឹងគុណនិងសងគុណគាត់ ។ ក្រោយមរណកាលទៅ ព្រលឹងលោកតែងតែនៅជួយថែរក្សាកូនចៅតទៅទៀត ។ កូនៗចូលចិត្តសុំធ្មេញម្ដាយឪពុកមកស្រោបមាសឬឆ្លាក់រូបព្រះពាក់នៅក ដើម្បីនឹកឃើញគុណលោកជាប្រចាំ ។ ការរំលឹកឃើញគុណរបស់ម្ដាយឪពុក នាំឱ្យព្រលឹងគាត់តាមជួយឱ្យបានសេចក្ដីសុខជានិច្ច ។ រាល់ថ្ងៃសីល កូនៗតែងដុតធូប ទៀន ថ្វាយផ្លែឈើនិងផ្កា ។ រៀងរាល់ឆ្នាំ កូនចៅតែងនាំ

គ្នាទៅសែនព្រេន និងបង្សុកូលនៅតាមផ្នូរឬចេតិយម្ដាយឪពុកដើម្បីរំលឹកគុណលោក សុំសេចក្ដីសុខ និងឧទ្ទិសកុសលទៅជូនលោក ។ ពេលណាមានទុក្ខលំបាក កូនចៅតែងបន់ស្រន់រកជំនួយពីលោកមុនគេបង្អស់ ។

## សំណួរ

១. ក្នុងអត្ថបទនេះបង្ហាញពីប្រភពជំនឿយ៉ាងដូចម្ដេច?

២. ចូរបង្ហាញពីការប្រតិបត្តិជំនឿរបស់ខ្មែរយើងទៅលើព្រលឹងរបស់ម្ដាយឪពុក ។

៣. ចូរអ្នករៀបរាប់ពីជំនឿផ្សេងៗរបស់ខ្មែរយើង ។

៤. ក្នុងចំណោមជំនឿទាំងឡាយរបស់ខ្មែរ តើអ្នកគោរពនិងប្រតិបត្តិជំនឿណាខ្លះ? ព្រោះអ្វី?

៥. ចូរអ្នកបញ្ចេញមតិផ្ទាល់ខ្លួន តើការងប់ងល់នឹងជំនឿផ្សេងៗដោយមិនបានគិតពិចារណា នាំឱ្យមានគុណវិបត្តិឬទេ? ហេតុអ្វី?

## ចម្លើយ

១. ក្នុងអត្ថបទនេះបានបង្ហាញពីប្រភពជំនឿដោយសារមនុស្សជួបប្រទះនឹងបាតុភូតធម្មជាតិ ហើយពុំអាចជំនះលើបាតុភូតទាំងនោះបាន ក៏សង្ស័យ និងមានការភ័យខ្លាចមហន្តរាយ អស់ជំនឿលើសមត្ថភាពខ្លួនឯង ក៏ចាប់យកការបន់ស្រន់ អង្វរករ...ដើម្បីសុំសេចក្ដីសុខ ។

២. ការប្រតិបត្តិជំនឿរបស់ខ្មែរយើងទៅលើព្រលឹងរបស់ម្ដាយឪពុកៈ
ខ្មែរមានជំនឿថា ទោះបីជាឪពុកម្ដាយស្លាប់ទៅហើយ ក៏

នៅតែជឿលើព្រលឹងរបស់ពួកគាត់ ហើយបន់ស្រន់សុំសេចក្ដីសុខចម្រើនពីគាត់ផងដែរ។ ជំនឿនេះព្រោះខ្មែរយល់ថា ឪពុកម្ដាយជាអ្នកមានគុណ ជាព្រះនៅក្នុងផ្ទះ គាត់តែងតែនៅថែរក្សាកូនចៅជានិច្ច។ នៅរៀងរាល់ថ្ងៃសីល កូនៗតែតែងដុតទៀនធូប សែនផ្លែឈើ នំចំណី ម្ហូបអាហារតាមធនធាន ជាការរំលឹកគុណដល់ព្រលឹងវិញ្ញាណក្ខន្ធឪពុកម្ដាយ ព្រមទាំងមានការធ្វើបុណ្យឧទ្ទិសកុសលជូនលោកទៀតផង។

៣. ជំនឿផ្សេងៗរបស់ខ្មែរ៖

- ជំនឿលើព្រលឹងឪពុកម្ដាយ
- ជំនឿលើព្រលឹងមេបា
- ជំនឿលើគ្រូអាចារ្យ គ្រូបាធ្យាយ
- ជំនឿលើអ្នកតា
- ជំនឿលើបារមី វត្ថុសក្ដិសិទ្ធិ
- ជំនឿលើមន្តអាគម
- ជំនឿលើគ្រូទាយ
- ជំនឿលើសត្វ
- ជំនឿលើត្រណមផ្សេងៗ
- ជំនឿលើកន្សែងយ័ន្ត
- .........................

៤. *(សិស្សឆ្លើយតាមគំនិតរៀងៗខ្លួន)*

៥. ការងប់ងល់នឹងជំនឿផ្សេងៗដោយមិនបានគិតពិចារណា នាំឱ្យមានគុណវិបត្តិជាច្រើនដូចជា៖

- ងាយចាញ់បោកគេ
- ងាយធ្លាក់ក្នុងការអូសទាញរបស់គេ
- បាត់បង់ទ្រព្យសម្បត្តិ កិត្តិយស អាយុជីវិត.......។



## ការបញ្ចេញមតិ

*១– ការបញ្ចេញមតិ គឺជាការបង្ហាញពីការយល់ឃើញ គំនិត យោបល់*

*១– ការបញ្ចេញមតិ គឺជាការបង្ហាញពីការយល់ឃើញ គំនិត យោបល់ ទស្សនៈ ដើម្បីគាំទ្រ ឬជំទាស់ទៅលើមតិ យោបល់ គំនិត ទស្សនៈ សកម្មភាព ឬទង្វើផ្សេងៗ ហើយឈានទៅដល់ការវិនិច្ឆ័យ និងវាយតម្លៃ ។*

**សំណួរ**

១. តាមមតិខាងលើ តើជំនឿមានអ្វីខ្លះ ?

២. តាមមតិខាងលើ តើការងប់ងល់នឹងជំនឿអ្វីមួយ ដោយមិនបានពិចារណាឱ្យបានច្បាស់លាស់ ផ្តល់ឱកាសដូចម្តេចខ្លះដល់ជនខិលខូច ?

៣. តើអ្នកខ្លះយកជំនឿលើការយល់សប្តិទៅប្រព្រឹត្តអំពើអ្វីខ្លះ ?

៤. តើជនខិលខូចឆ្លៀតឱកាសនោះធ្វើអ្វីខ្លះ ?

៥. តើចុងបញ្ចប់នៃមតិនេះផ្តល់ការអប់រំដូចម្តេចខ្លះ ?

**ចម្លើយ**

១. តាមមតិខាងលើ ជំនឿមានច្រើនយ៉ាងដូចជា : ការជឿទៅលើមនោគមវិជ្ជា នយោបាយ ជំនឿអរូបីផ្សេងៗ ដែលមាន [illegible] ជំនឿលើអ្នកតា ខ្មោច ព្រាយ បិសាច វត្ថុស័ក្តិសិទ្ធិ មន្តអាគម-គាថា ជឿលើការយល់សប្តិ ។ល។

២. តាមមតិខាងលើការងប់ងល់នឹងជំនឿអ្វីមួយដោយមិនបានពិចារ-ណា ឱ្យបានច្បាស់លាស់ ផ្តល់ឱកាសដល់ជនខិលខូចមួយចំនួនតូចឆ្លៀតកេងបន្លំបោកប្រាស់អ្នកទាំងនោះដើម្បីផលប្រយោជន៍របស់ពួកគេ ។

៣. អ្នកខ្លះយកជំនឿលើការយល់សប្តិទៅប្រព្រឹត្តអំពើផ្សេងៗដូចជាល្បែងភ្នាល ចាក់ឆ្នោត ឬប្រព្រឹត្តអំពើអបាយមុខផ្សេងៗខុសច្បាប់ដែលនាំឱ្យខ្លួនឯង គ្រួសារ និងសង្គមជួបនឹងមហន្តរាយ ។

៤. ជនខិលខូចឆ្លៀតឱកាសនោះធ្វើជាមធ្យោបាយដើម្បីរកប្រយោជន៍ ឬលាភសក្ការៈ ឬបិទបាំងអំពើអាក្រក់របស់ខ្លួន ។

៥. ចុងបញ្ចប់នៃមតិនេះផ្តល់ការអប់រំឱ្យចេះពិចារណា ស្វែងយល់ឱ្យច្បាស់លាស់ជាមុនសិន មុននឹងជឿលើអ្វីមួយ ឬនរណាម្នាក់ ។

មេរៀនទី ៣

# សេចក្ដីក្លាហាន



## យប់មួយនៅភូមិក្រាំងលាវ

សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងអ្វី? នរណាជាអ្នកនិពន្ធ? តាក់តែងនៅឆ្នាំណា?

២. តើអ្នកភូមិក្រាំងលាវប្រកបមុខរបរអ្វី? បណ្ដារាស្ត្រភូមិនេះនិយមធ្វើអ្វីខ្លះក្រោយពីរដូវច្រូតកាត់រួច?

៣. តើជួននិងនៅ ជាអ្នកស្រុកភូមិណា? ពួកគាត់មកលេងជាមួយនឹងអ្នកភូមិក្រាំងលាវក្នុងបំណងអ្វី?

៤. តើដំណើររឿងនៃអត្ថបទដកស្រង់នោះបានប្រព្រឹត្តទៅនៅកន្លែងណា?

៥. ចូរសិក្សាមូលន័យ និងមូលបញ្ហានៃអត្ថបទខាងលើនេះ។

៦. ចូរបង្ហាញតម្លៃអប់រំតាមរយៈអត្ថបទខាងលើនេះ។

៧. តើគម្រោងសម្លាប់លោករ៉េស៊ីដង់បារដេសរបស់អ្នកក្លាហានជួន នៅ និងអ្នកភូមិក្រាំងលាវអាចនឹងទទួលជោគជ័យឬទេ? ព្រោះអ្វី?

៨. ចូរវិភាគតួអង្គជួន នៅ និងលោករ៉េស៊ីដង់បារដេស។

**ចម្លើយ**

១. -អត្ថបទនេះដកស្រង់ចេញពីរឿងភូមិតិច្ឆាន
-អ្នកនិពន្ធដោយ លោកឱក គាម និង លោកឡើក អំ
- តាក់តែងនៅឆ្នាំ១៩៦៤-៦៥
២. អ្នកភូមិក្រាំងលាវប្រកបមុខរបរធ្វើស្រែ និងឡើងត្នោត។ ក្រោយពីរដូវច្រូតកាត់រួច បណ្ដារាស្ត្រភូមិនេះនិយមលេងល្បែងប្រជាប្រិយដូចជា អង្គញ់ ឈូង លោតអន្ទាក់ ចាប់កូនមាន់ និងវិជ្ជាគុនចំបាប់ ។ល។
៣. ជួននិងនៅ ជាអ្នកស្រុកភូមិព្រៃខ្មែរ។ ពួកគាត់មកលេងជាមួយនឹងអ្នកភូមិក្រាំងលាវក្នុងបំណងប្រាប់ពីគម្រោងការណ៍សម្លាប់បារាំងដេស និងឱ្យពួកគេចូលរួមជាមួយចលនារបស់ខ្លួន។
៤. ដំណើររឿងនៃអត្ថបទដកស្រង់នោះបានប្រព្រឹត្តទៅនៅទីវាលមួយក្នុងភូមិផ្លូវគោ ឃុំក្រាំងលាវ។
៥. +មូលន័យក្នុងអត្ថបទនេះគឺគម្រោងការណ៍សម្លាប់បារាំងដេសរបស់ជួន និងនៅ។
+មូលបញ្ហានៃអត្ថបទខាងលើនេះគឺ៖
-បារាំងដំឡើងពន្ធកាន់តែខ្ពស់ ហើយប្រើអំណាចធ្វើបាបរាស្ត្រខ្មែរ
-ជួន និងនៅអត់ទ្រាំនឹងសកម្មភាពរបស់បារាំងលែងបាន
-ជួន និងនៅជួបជាមួយក្រុមអ្នកក្លាហានទាំង២០រូប ដើម្បីរិះរកវិធីកម្ចាត់បារាំង
-សកម្មភាពរបស់ក្រុមអ្នកតស៊ូសម្លាប់បារាំងដេស

៦. តម្លៃអប់រំតាមរយៈអត្ថបទខាងលើនេះ៖

-បណ្តុះស្មារតីកូនខ្មែរឱ្យមានចិត្តក្លាហាន

-បណ្តុះស្មារតីសាមគ្គីភាពផ្ទៃក្នុង

-ស្រឡាញ់ជាតិមាតុភូមិ ហ៊ានក្រោកឈរប្រឆាំងចំពោះជនបរទេសឈ្លានពានទឹកដីខ្មែរ

-សុខចិត្តស្លាប់ខ្លួន កុំឱ្យជាតិស្លាប់

៧. គម្រោងសម្លាប់លោករ៉េស៊ីដង់បារាំងរបស់អ្នកក្លាហានដួន នៅ និងអ្នកភូមិក្រាំងលាវអាចនឹងទទួលជោគជ័យ ព្រោះពួកគេមានកំហឹងពុះកញ្ជ្រោលនឹងអំពើជិះជាន់របស់បារាំងដែលជាហេតុធ្វើឱ្យពួកគេមានគំនិតស្របគ្នា មានសាមគ្គីភាព មានការប្តេជ្ញាចិត្ត មានគ្រោងការណ៍ច្បាស់លាស់ និងមានគំនិតសុទិដ្ឋិនិយម ។

៨. វិភាគតួអង្គដួន នៅ និងលោករ៉េស៊ីដង់បារាំង ។

\+ **ដួន និង នៅ**

**ក) គុណសម្បត្តិ**

-ជាអ្នកក្លាហានព្រៃខ្មែរមិនខ្លាចស្លាប់

-មានកំហឹងឈឺចាប់ចំពោះបារាំងដែលធ្វើបាបប្រជារាស្ត្រខ្មែរ

-ជាអ្នកបំផុសគំនិត លើកគម្រោងការណ៍សម្លាប់បារាំង

-ជាអ្នកជាតិនិយម ស្រឡាញ់សេរីភាព

**ក-គុណវិបត្តិ**

-អ្នកទាំងពីរចូលចិត្តផឹកស្រា យកគ្រឿងស្រវឹងមកធ្វើជាប្រី មុខ ដែលផ្ទុយពីសីលធម៌ពុទ្ធសាសនា

-មានចរិតជាអ្នកលេងកាប់ចាក់

**+ រ៉េស៊ីដង់ចារ ជេស**

**ខ) គុណវិបត្តិ**

-មានចរិតកាចសាហាវ ឃោរឃៅ ផ្តាច់ការ អមនុស្សធម៌ គ្មានត្រាប្រណីដល់រាស្ត្រខ្មែរបន្តិចឡើយ។

-ដំឡើងពន្ធដារ កេងប្រវ័ញ្ចញើសឈាមរបស់កម្មករ

## ការបន្លឺសំឡេង

**លំហាត់**

**១. តើភាសាបន្លឺត្រូវពឹងផ្អែកលើអ្វី?**

២. ដូចម្តេចដែលហៅថាលក្ខណៈបន្លឺ? តើលក្ខណៈបន្លឺមានអ្វីខ្លះ?

៣. តាមលក្ខណៈខ្យល់ តើសូរសំឡេងចែកជាប៉ុន្មាន?

៤. តើព្យញ្ជនៈ ក ខ ជ ឈ ញ យ រ ហ ស្ថិតក្នុងសូរពួកណាខ្លះ?

៥. តើការសិក្សាមូលភេទ "អ-អ៊" ដើម្បីអ្វី?

ចម្លើយ

១. ភាសាបន្លឺត្រូវពឹងផ្អែកលើការរៀបចំប្រដាប់សំឡេង លើចលនាខ្យល់ និងលើភាពឮ ។

២. ដែលហៅថាលក្ខណៈបន្លឺ គឺសំដៅយករបៀបរៀបចំ និងចលនានៃប្រដាប់សំឡេង ។ លក្ខណៈបន្លឺមាន ប្រដាប់បន្លឺ និងទីបន្លឺ ។

៣. តាមលក្ខណៈខ្យល់ សូរសំឡេងចែកជា :

-សូរមានខ្យល់ និងគ្មានខ្យល់

-សូរស្ទះខ្យល់

-សូរខ្យល់ច្រមុះ

-សូរខ្យល់បង្ករត្រដុស

-សូរខ្យល់វែង និងខ្យល់ខ្លី

៤. ព្យញ្ជនៈ "ក ខ ជ ឈ ញ យ រ ហ" ស្ថិតក្នុងសូរឮតាមភាពញ័រនៃខ្សែសំឡេង ។

៥. ការសិក្សាមូលភេទ "អ-អ៊" ដើម្បីស្វែងយល់ពីទំនាក់ទំនងរវាងស្រៈនិងព្យញ្ជនៈក្នុងការសរសេរនិងក្នុងវិធីអានសំណេរភាសាខ្មែរ ។



# ទឹកចិត្តពោធិកំបោរ

សំណួរ

១. តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់ថា ពោធិកំបោរជាអ្នកក្លាហាន ហ៊ានលះបង់ដើម្បីប្រទេសជាតិ?

២. តើចំណុចត្រង់ណាខ្លះដែលបញ្ជាក់គំនិតស្នេហាជាតិរបស់តួអង្គពោធិកំបោរ?

៣. តើអត្ថបទនេះមានតួអង្គណាខ្លះ? នរណាជាតួអង្គឯក? តួអង្គរង?

៤. ចូរបង្ហាញកាលអាកាសរបស់អត្ថបទ។

៥. ចូរអ្នកវិភាគតួអង្គពោធិកំបោរ។

៦. ចូរបង្ហាញតម្លៃអប់រំតាមរយៈអត្ថបទនេះ។

ចម្លើយ

១. ចំណុចដែលបញ្ជាក់ថា ពោធិកំបោរជាអ្នកក្លាហាន ហ៊ានលះបង់ដើម្បីប្រទេសជាតិ ត្រង់គាត់សុខចិត្តស្លាប់ខ្លួន មិនព្រមលក់ក្បាលចុះចូលជាមួយបរទេសឈ្លានពានទឹកដីខ្មែរដាច់ខាត ដូចត្រង់សំដីគាត់និយាយថា "យើងជាខ្មែរចាំបាច់ត្រូវការពារទឹកដីខ្មែរឱ្យគង់-វង្សរហូតទៅ...។" "...ខ្ញុំមិនចង់បានបុណ្យសក្តិក្រៅពីចង់បានឯករាជ្យជូនមាតុភូមិ និងប្រជាជនខ្មែរនោះទេ ទោះបីជាមួយជំហានស្លាប់ក៏ខ្ញុំនៅតែស៊ូប្រឆាំងជាមួយបារាំងដាច់ខាត"។

២. ចំណុចដែលបញ្ជាក់គំនិតស្នេហាជាតិរបស់តួអង្គពោធិកំបោរគឺ

ត្រង់ចំណុចដែលពោធិកំបោរសញ្ជឹងគិតដល់វាសនាប្រទេសជាតិថា "ឱ! មាតុភូមិខ្មែរដែលឱ្យតម្លៃដល់រូបអញមក មិនគួរបើនឹងសសៀវទៅរកបាយនភាពដោយសារតែជាតិសាសន៍ដទៃជាអាព្យាបាលអីចឹងសោះ"។... "យើងជាខ្មែរចាំបាច់ត្រូវការពារទឹកដីឱ្យគង់វង្សរៀងរហូតទៅ។"...

៣. អត្ថបទនេះមានតួអង្គ : ពោធិកំបោរ មេក្រុមឆន ក្រុមការសៅ រួមទាំងគូកនទាំងសងខាង។ តួឯកគឺពោធិកំបោរ។ តួអង្គរង គឺមេក្រុមឆន ក្រុមការសៅ...។

៤. កាលអាកាសរបស់អត្ថបទ :

+កាល : រំពេចនោះ ខណៈនោះ ថ្ងៃនេះ មួយរំពេចនោះ ពេលនោះ...

+អាកាស : ភូមិសុរិល ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តកំពង់ស្វាយ

៥. វិភាគតួអង្គពោធិកំបោរ៖

+គុណសម្បត្តិ

-ជាជនស្នេហាជាតិ

-ជាវីរជនអង់អាចក្លាហាន

-ជាមេដឹកនាំដ៏ល្អ

-ចេះរៀបចំផែនការកម្ចាត់ពួកឈ្លានពាន ដើម្បីរំដោះទឹកដី...

+គុណវិបត្តិ

- ឆាប់ជឿទុកចិត្តមនុស្សអាក្រក់ មិនចេះពិនិត្យអំពីប្រវត្តិមនុស្សឱ្យច្បាស់មុននឹងទទួលឱ្យធ្វើការជាមួយ។

៦. តម្លៃអប់រំតាមរយៈអត្ថបទនេះ គឺអប់រំកូនខ្មែរឱ្យ ៖

-ស្រឡាញ់ជាតិមាតុភូមិ

-ហ៊ានពលិកម្មដើម្បីជាតិ

-ប្រឆាំងចំពោះជនឈ្លានពានទឹកដីខ្មែរ

-ស្អប់ខ្មើមពួកជិះជាន់ និងពួកលក់ខ្លួនឱ្យបរទេស

-ចេះសាមគ្គីគ្នាជាធ្លង់មួយ

-មុននឹងសេពគប់នរណាម្នាក់ត្រូវស្គាល់ប្រវត្តិបុគ្គលនោះឱ្យច្បាស់លាស់ ។

# ១ រឿងអ្នកតាឃ្លាំងមឿង

**អត្ថបទ**

[...] ជ័យអស្តារ្យ លុះបានទទួលស្បៀងបន្ថែមអំពីព្រះចៅក៏បន្តដំណើរទៅទៀត។ ចំនួន៩ថ្ងៃក្រោយមក ក៏បានដល់ស្រុកបាត់-ដំបងដែលជាដីខ្មែរ។ មានអ្នកស្រុកជិតឆ្ងាយគ្រប់តំបន់រត់មកចុះចូលថ្វាយខ្លួនជាពលសេនា ព្រមទាំងសេនាចាស់ម្នាក់ធ្លាប់បម្រើវរបិតាឈ្មោះមឿងនិងកូនប្រុស៤នាក់បានចូលមកថ្វាយខ្លួនដែរក៏មានមនុស្សច្រើនល្មមតទល់នឹងព្រះចៅសៀមបាន។

[...] បីខែក្រោយមកទើបជ័យអស្តារ្យប្រកាសខ្លួនឱ្យអ្នកស្រុកដឹងច្បាស់ថា ខ្លួនហ្នឹងហើយជាព្រះរាជបុត្ររបស់ព្រះចន្ទរាជាគង់នៅបន្ទាយលង្វែក ឥឡូវនេះវិលមកគ្រងរាជ្យស្នងព្រះបិតា។ រឿងនេះមិនបាត់ស្ងាត់ ជ្រាបដល់ព្រះចៅសៀម ទ្រង់ព្រះពិរោធយ៉ាងខ្លាំងពន់ពេក នឹកតូចព្រះទ័យក្រៃលែង ទ្រង់ប្រជុំពួកសេនាយោធាប្រាប់ថាជ័យអស្តារ្យប្រើឧបាយកលបោកបញ្ឆោតយកព្រះខ័នសីក ព្រមទាំងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណរត់ទៅស្រុកខ្មែរ ហេតុនេះត្រូវលើកទ័ពតាមទៅដណ្តើមយកមកវិញឱ្យបាន ហើយចាប់ជ័យអស្តារ្យសម្លាប់ឱ្យផុតពូជព្រះចន្ទរាជា ព្រមទាំងពួករាជការទាំងប៉ុន្មានកុំឱ្យសល់។

ជ័យអស្តារ្យបានដឹងដំណឹងថាព្រះចៅសៀមលើកទ័ពមកតាមដូចនោះ ទ្រង់ជំនុំនឹងសេនាបតី៖ ឥឡូវពលសេនាយើង និងគ្រឿង

អាវុធយុទ្ធភ័ណ្ឌរបស់យើងពុំបរិបូរ តើអ្នករាល់គ្នាគិតរកឧបាយកលបែបណាឱ្យមានជ័យជំនះពេលនេះ? សេនាទាំងអស់ មិនមានអ្នកណាមួយហ៊ានឆ្លើយទទួលធានាអះអាងសោះ មានតែសេនាមឿងឆ្លើយធានាអះអាងហ៊ានតទល់នឹងទ័ពសៀម ដោយឧបាយកលមួយដ៏ចម្លែក គឺហ៊ានប្តូរជីវិត ដើម្បីនឹងទៅកេណ្ឌពលខ្មោច ធ្វើជាទ័ពច្បាំងនឹងពលសៀម។ ទើបលោកបង្គាប់ឱ្យជីករណ្តៅទំហំ៤ម៉ែត្រ៤ជ្រុង ជម្រៅ៤ម៉ែត្រ រួចឱ្យដាំគ្រឿងសស្ត្រាវុធក្នុងរណ្តៅនោះ ដើម្បីនឹងលោតទៅឱ្យដង់ស្លាប់ក្នុងរណ្តៅ។ តែនៅពេលមុននឹងលោតសម្លាប់ខ្លួននោះ សេនាមឿងបង្គាប់ឱ្យពួកពលទាំងអស់មកស្តាប់ពាក្យឱវាទលោក។ លោកប្រកាសៈ "សូមឱ្យអស់លោកខំប្រឹងយកចិត្តទុកដាក់ក្នុងរឿងពេលនេះដើម្បីរំដោះផែនដីខ្មែរ ឱ្យរួចផុតអំពីកណ្តាប់ដៃនៃបច្ចាមិត្រ។ ចំណែកខ្ញុំ ខ្ញុំធានាខាងកងទ័ពខ្មោច សូមអស់លោកសង្ឃឹមចុះ។ បើខ្ញុំស្លាប់ទៅបាន៧ថ្ងៃ ពួសួរសន្ទឹកហោកញ្ជ្រៀវបីដូចជាសម្លេងផ្គរលាន់យើងមានជ័យហើយ"។ លុះផ្តាំរួចក៏លោតចុះក្នុងរណ្តៅព្រិប ប្រពន្ធឃើញប្តីលោតដូចនោះ ក៏លោតទៅជាមួយនឹងប្តី ព្រមទាំងកូនប្រុសពីរនាក់ស្លាប់ជាមួយគ្នា។ ដល់ថ្ងៃជាគម្រប់៧ ក៏លាន់ពួសួរសន្ទឹកដូចកាលផ្តាំមែន។

ទ័ពសៀមចូលដល់បាត់ដំបង ឆ្លងចូលដល់អូរមួយ (សព្វថ្ងៃហៅថាអូរស្វាយដូនកែវ) ជួបគ្នានឹងទ័ពជ័យអស្ចារ្យ។ ទ័ពខ្មោចចេញទៅមុនសម្តែងឫទ្ធិ ធ្វើឱ្យពលសៀមវិលមុខ ចុកពោះ ចុះក្អួតដួលខ្លួនឯលស្រួស១។ ទ័ពព្រះជ័យអស្ចារ្យចូលទៅកាប់សម្លាប់អស់។

ពួកកងទ័ពសៀមទប់ទល់មិនបាន ថយទៅដល់បាត់ដំបង ផ្ញើសារទៅក្រាបទូលព្រះចៅតាមដំណើរសព្វគ្រប់។ ព្រះចៅទ្រង់ជ្រាបឱ្យទ័ពថយត្រឡប់ទៅស្រុកសៀមវិញ។

ចំណែកពួកកងទ័ពព្រះជ័យអស្ចារ្យនាំគ្នាត្រឡប់មកកាន់បន្ទាយវិញ (សព្វថ្ងៃគេហៅថាបន្ទាយជ័យ)។ ចាប់ដើមពីពេលនោះមក ព្រះជ័យអស្ចារ្យបានទទួលរាជាភិសេកសោយរាជ្យ និងទទួលនាមថាព្រះជ័យចេស្តាព្រះចៅក្រុងកម្ពុជាធិបតីគង់នៅបន្ទាយជ័យ។ លុះព្រះអង្គបានឡើងសោយរាជ្យសម្បត្តិសុខសាន្តហើយ ទ្រង់នឹកឃើញដល់គុណូបការៈសេនាមឿង ដែលស៊ូប្ដូរជីវិតចំពោះព្រះអង្គ និងចំពោះទឹកដីខ្មែរ ទ្រង់ក៏ចាត់ឱ្យធ្វើបុណ្យឧទ្ទិសផលដល់ដួងវិញ្ញាណក្ខន្ធរបស់សេនាមឿងយ៉ាងឧឡារិកអស្ចារ្យ ជាប់ជាទំនៀមដរាបដល់មកសព្វថ្ងៃនេះ ហៅថាធ្វើបុណ្យឡើងអ្នកតាឃ្លាំងមឿងទៅវិញ។

**សំណួរ**

១. តើមានអព្ភូតហេតុអ្វីខ្លះកើតឡើងក្រោយពេលមរណភាពរបស់សេនាមឿង?

២. ចូររកកាលអាកាសក្នុងរឿងខាងលើ។

៣. ចូរបង្ហាញលក្ខណៈតថៈនៃអត្ថបទសម្រង់នេះ។

៤. តើអត្ថបទសម្រង់នេះបាននិយាយគំនិតសំខាន់អ្វីខ្លះ?

៥. ចូរវិភាគតួអង្គ "សេនាមឿង"។

៦. តាមរយៈអត្ថបទស្ដាប់នេះ តើអ្នកបានទទួលបទពិសោធអ្វីខ្លះអំពីតួអង្គសំខាន់?

**ចម្លើយ**

១. ក្រោយពេលមរណភាពរបស់សេនាមឿងបាន៧ថ្ងៃ មានអព្ភូតហេតុអស្ចារ្យកើតឡើងគឺ គេឮសូរសន្ធឹកហ៊ោកញ្ជ្រៀវបីដូចជាសំឡេងផ្គរលាន់ជាសំឡេងរបស់ទ័ពខ្មោចដែលសេនាមឿងទៅកេណ្ឌយកមកច្បាំង ។

២. កាលអាកាសក្នុងរឿង

+កាល : ចំនួន៥ថ្ងៃក្រោយមក ដល់ថ្ងៃជាគម្រប់៧ បីខែក្រោយមក...។

+អាកាស : ស្រុកបាត់ដំបង បន្ទាយលង្វែក អូរស្វាយដូនកែវ...។

៣. លក្ខណៈតថៈនៃអត្ថបទសម្រង់នេះគឺ៖

- ឈ្មោះអ្នកតាឃ្លាំងមឿងមាននៅខេត្តពោធិ៍សាត់
- ចម្បាំងរវាងខ្មែរ-សៀម នៅសម័យលង្វែក ក្នុងរជ្ជកាលព្រះបាទចន្ទរាជារហូតដល់ស្ដេចជ័យចេស្ដា(ជ័យអស្ចារ្យ)

៤. គំនិតសំខាន់ក្នុងអត្ថបទសម្រង់នេះគឺការលះបង់ជីវិតរបស់សេនាមឿងដើម្បីបុព្វហេតុជាតិមាតុភូមិ ។

៥. វិភាគតួអង្គ "សេនាមឿង"

+គុណសម្បត្តិ

-ជាវីរជនស្នេហាជាតិ

-មានភាពអង់អាចក្លាហាន

-ហ៊ានបូជាជីវិតដើម្បីជាតិ

-ជួយពង្រឹងជំហរ-កម្លាំងចិត្តកងទ័ពឱ្យក្លាហាន

៦. បទពិសោធតាមរយៈអត្ថបទដកស្រង់ ៖

- *មានគំនិតស្នេហាជាតិ*
- *ចេះប្រើប្រាជ្ញាដោះស្រាយបញ្ហា ។ល ។*

  (សិស្សបន្ថែម)



## សង្ខេបអត្ថបទ

***១– សង្ខេបអត្ថបទ គឺជាការនិយាយ ឬកត់ត្រាចំណុចសំខាន់ៗ ដែលមាននៅក្នុងអត្ថបទដកស្រង់ ឬអត្ថបទរឿងឱ្យខ្លីមានន័យគ្រប់គ្រាន់ ។***

សំណួរៈ ចូរអ្នកនិយាយសង្ខេប :

- អត្ថបទដកស្រង់ "ទឹកចិត្តពោធិកំបោរ"

នៅពេលដែលពោធិកំបោរកំពុងអង្គុយសញ្ជប់សញ្ជឹងគិតពីវាសនាប្រទេសជាតិ ស្រាប់តែលេចមុខដើងការពិសេសមកប្រាប់ដំណឹងពីស្ថានភាពកងទ័ពបារាំង ដែលកំពុងដើរបញ្ចុះបញ្ចូលប្រជារាស្ត្រខ្មែរឱ្យចូលដៃជាមួយវា ។

ពោធិកំបោរក៏បញ្ជាឱ្យដើងការពិសេសកោះហៅមេក្រុមមេកងចូលរោងជំនុំដើម្បីពិភាក្សាពីគម្រោងការណ៍ ដើម្បីទប់ទល់ជាមួយកងទ័ពបារាំង ។

ចំណែកក្រុមការសៅ និងគួកនដែលចុះចូលជាមួយបារាំងក៏ក្លែងខ្លួនធ្វើជាចុះចូលជាមួយពោធិកំបោរ រួចរកឱកាសសម្លាប់ពោធិ

កំបោរ និងរាយការណ៍ឱ្យបារាំងមកកម្ចាត់បក្សពួករបស់ពោធិកំបោរ ។

- អត្ថបទដកស្រង់ "ភ្នំនាងកង្រី"

កាលពីព្រេងនាយ មានសេដ្ឋីពីរនាក់ប្ដីប្រពន្ធឥតមានកូនម្នាក់សោះ ក៏ទៅបួងសួងសុំកូន ។ គាត់ក៏បានកូនសុទ្ធតែស្រីដល់ទៅ ១២នាក់ ធ្វើឱ្យគាត់ធ្លាក់ខ្លួនក្រ ក៏យកកូនទៅបំបះបង់ចោល ។

នាងទាំង១២ក៏វង្វេងផ្លូវទៅដល់នគរយក្ខសន្ធមារ ។ លុះដឹងថាជានគរយក្ខ ក៏លួចរត់ចេញទៅដល់នគរព្រះបាទរថសិទ្ធ ។ ព្រះបាទរថសិទ្ធក៏យកនាងទាំង១២ធ្វើជាមហេសី ។

ថ្លែងពីយក្ខសន្ធមារ លុះដឹងថានាងទាំង១២ក្លាយជាមហេសីស្ដេចរថសិទ្ធ ក៏តាមទៅព្យាបាទ ដោយក្លែងជាស្រីស្អាតម្នាក់ដើម្បីបានជាមហេសីព្រះបាទរថសិទ្ធដែរ ។ សន្ធមារក៏ប្រើល្បិចកម្ចាត់នាង១២ចេញពីនគរ ហើយឱ្យគេឆ្កៀលភ្នែកទាំងគូរបស់ពួកនាង លើកលែងតែនាងទី១២ទេដែលត្រូវគេឆ្កៀលភ្នែកតែម្ខាង ។

ក្រោយមកនាងទី១២កើតបានកូនប្រុសម្នាក់ឈ្មោះពុទ្ធិសែន ហើយជាក្មេងមានប្រាជ្ញាវាងវៃ ។ សន្ធមារក៏ធ្វើល្បិចប្រើពុទ្ធិសែនទៅឱ្យនាងកង្រីជាកូនស្រីសម្លាប់ចោល ។ ដោយមានអន្តរាគមន៍ពីតាបសឬសី ពុទ្ធិសែនក៏បានរៀបការជាមួយនាងកង្រី ហើយក៏បានលួចយកកែវភ្នែកម្ដាយ និងម្ដាយធំ ព្រមទាំងថ្នាំ រត់ទៅព្យាបាលម្ដាយ និងម្ដាយធំជាសះស្បើយ ។ ចំណែកនាងកង្រីក៏យំសោករហូតស្លាប់កណ្ដាលព្រៃ ឯយក្ខសន្ធមារក៏ត្រូវសម្លាប់ ។ ពុទ្ធិសែនក៏ឡើងសោយរាជ្យជាសុខសាន្ត ។

# ការលេះបង់

## ឈុត និង ឆាក

ក. ឈុត : គឺជាសាច់រឿងដែលគេរៀបចំឡើងមានច្រើនឆាក។ ឈុតមានការផ្លាស់ប្តូរនៅពេលមានការផ្លាស់ប្តូរស្ថានភាពធំៗរបស់រឿង។

ខ. ឆាក : មានន័យពីរយ៉ាង ៖

+ន័យទី១ : ឆាកគឺជាកន្លែងសម្រាប់សំដែងរឿង។

+ន័យទី២ : ឆាកគឺជាសាច់រឿងដែលជាផ្នែកតូចមួយនៃឈុត ។

# ក្ដៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ

សំណួរ

១. តាមរយៈតួអង្គស្ដេចសំរែ ចូរអ្នក ៖

-បង្ហាញពីតួនាទី

-សកម្មភាព

-ចរិតលក្ខណៈ

២. តើការធ្វើសង្គ្រាមរវាងតេជោមាស ជាមួយស្ដេចសំរែ អ្នកណាឈ្នះ? ឈ្នះដោយសារអ្វី?

៣. តើរឿងនេះមានតួអង្គប៉ុន្មាន? អ្នកណាខ្លះ? ហើយតួអង្គណាជាតួអង្គឯក តួអង្គរង? តើតួអង្គនីមួយៗមានតួនាទីជាអ្វី?

៤. តើជំទាវស្រែនជាមនុស្សយ៉ាងដូចម្ដេច? លោកជំទាវជួយស្វាមីដូចម្ដេចខ្លះ? ហើយអ្នកយល់យ៉ាងណាចំពោះបេសកកម្មជំទាវស្រែន?

៥. តើអត្ថបទនេះជាប្រភេទអ្វី? ហើយប្រភេទនៃអត្ថបទនេះមានរចនាបទខុសពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទានយ៉ាងដូចម្ដេច?

៦. តើអត្ថបទល្ខោនដកស្រង់នេះមានប៉ុន្មានឆាក? តើការប្ដូរឆាកកើតឡើងនៅពេលណា?

៧. តាមរយៈសកម្មភាពជំទាវស្រែន តើបានបង្ហាញពីតួនាទីរបស់ខ្មែរ

ក្នុងការអភិវឌ្ឍសង្គមយ៉ាងណាខ្លះ?

៨. ចូរសិក្សាអំពី :

-កាលអាកាសនៃរឿង

-និមិត្តរូបវិធី

-ឧបមានវិធី

៩. តើ "ក្តៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ" ដែលជាចំណងជើងអត្ថបទអំណាននេះមានន័យដូចម្តេច? ចូររកអំណះអំណាងបញ្ជាក់ ។

## ចម្លើយ

១. តួអង្គស្តេចសំរែ:

-តួនាទី : តាំងនាមថា ជាស្តេចសំរែរាជាធិរាជ

-សកម្មភាព : មេបះបោរប្រឆាំងនឹងស្តេចជ័យចេស្តា ដើម្បីឡើងសោយរាជ្យ ។

-ចរិតលក្ខណៈ : ល្មោភអំណាច ល្មោភនឹងកាមតណ្ហា

២. ការធ្វើសង្គ្រាមរវាងតេជោមាសជាមួយស្តេចសំរែ គឺជ័យជំនះបានទៅលើតេជោមាស ។ ជ័យជំនះនេះបានដោយសារការជួយអន្តរាគមន៍ ពីជំទាវស្រែនជាភរិយា ។

៣. រឿងនេះមានតួអង្គច្រើននាក់ ( សូមមើលក្នុងតារាងខាងក្រោម ។

- តួអង្គឯក គឺ តេជោយ៉ត

- តួអង្គរង គឺ តេជោមាស ជំទាវស្រែន ស្តេចសំរែ និងតួអង្គដទៃទៀត ។

| តួអង្គ | មុខងារ |
| --- | --- |
| ១-តេជោមាស | -ជាស្វាមីជំទាវស្រែន មានងារជាតេជោ-បរមរាជ ត្រួតខេត្តកំពង់ស្វាយ ។ |
| ២-តេជោយ៉ត | -ជាសិស្សតេជោមាស មានងារជាតេជោ ត្រួតខេត្តកំពង់ស្វាយពេលដែលតេជោមាសស្លាប់ទៅ ។ |
| ៣-ជំទាវស្រែន | -ជាភរិយាតេជោមាស និងតេជោយ៉ត ជាស្ត្រីដែលមានល្បិចឆ្នើម អាចចាប់ស្តេចសំរែក្បត់ជាតិយកទៅកាត់ទោស ។ |
| ៤-ព្រះចៅជ័យចេស្តា | -ព្រះមហាក្សត្រខ្មែរសោយរាជ្យនៅឧដុង្គមានជ័យ ។ |
| ៥-អ្នកម្នាងនូ | -បងស្រីម៉ឺនចៃចុងរ៉ាក់ និងជាអ្នកម្នាងរបស់ព្រះចៅចេស្តា ។ |
| ៦-ស្តេចសំរែ | -មេបះបោរប្រឆាំងនឹងស្តេចដើម្បីឡើងសោយរាជ្យ ។ |
| ៧-ឧកញ៉ាពិភា | -មន្ត្រីជំនិតរបស់ស្តេចសំរែ ។ |
| ៨-ឧកញ៉ាព្រហ្មស្រីទ្វារប្រាសាទជប់ | -បម្រើការងារជាមួយតេជោមាស និងតេជោយ៉ត និងជាឪពុកនាងម៉ែ ។ |
| ៩-នាងម៉ែ | -បុត្រីឧកញ៉ាព្រហ្មស្រីទ្វារប្រាសាទជប់ និងជាអ្នកតាមស្រឡាញ់តេជោយ៉ត តែមិនបានសម្រេច ក្លាយទៅជាប្អូនធម៌របស់តេជោ-យ៉តទៅវិញ ។ |

| | |
|---|---|
| ១០-នាយឈិត | -ល្បើយសឹកសៀម និងជាមេបះបោរប្រឆាំងព្រះរាជាខ្មែរ ។ |
| ១១-ម៉ឺនថៃចុងរ៉ាក់<br>១២-និងមានតួអង្គរំលឹកជាច្រើនទៀត ។ | -ប្អូនអ្នកម្នាងនូ ប្រឆាំងតេជោយ៉ត ហើយត្រូវតេជោយ៉តចាប់ទៅសម្លាប់ចោល ។ |

៤. ជំទាវស្រែនជាស្ត្រីម្នាក់ដែលមានបញ្ញាវាងវៃក្នុងការរកមធ្យោបាយកំចាត់ស្តេចសំរែ ។

-លោកជំទាវបានជួយស្វាមីតាមវិធីបញ្ឆោតស្តេចសំរែតាមរយៈការលែងលះគ្នារវាងលោកជំទាវនិងតេជោមាស ។

ចំពោះបេសកម្មរបស់ជំទាវស្រែន គឺជាបេសកម្មមួយ ពោរពេញទៅដោយការលះបង់កិត្តិយសចំពោះគ្រួសារខ្លួននិងខ្លួនឯងដែលគួរឱ្យគោរពជាទីបំផុត។ ទង្វើនេះ បង្ហាញពីតួនាទីដ៏សំខាន់របស់ភរិយាចំពោះស្វាមីក្នុងការសម្រេចកិច្ចការធំៗសមដូចសុភាសិតមួយថា "សំណាងយោងដី ស្រីយោងប្រុស" ។

៥. អត្ថបទនេះជាប្រភេទអត្ថបទល្ខោនបាសាក់។ ប្រភេទនៃអត្ថបទនោះមានរចនាបទខុសពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទាន ត្រង់ ៖

-អត្ថបទចែកជាឈុតនិងឆាក

-នៅខាងដើមរឿងមានបញ្ជីរាយនាមតួអង្គនិងខាងាន: ឬ

ប្រភពកំណើតរបស់តួអង្គ

-តួអង្គ : បង្ហាញឈ្មោះ ឬជីវប្រវត្តិខ្លួនដោយផ្ទាល់ ។

-ការសំដែង : ប្រព្រឹត្តទៅមានតួក តួរង តួឯកប្រុសស្រី ជាមនុស្ស យក្ស ទេវៈ សត្វជាដើម ។ តួអង្គទាំងនោះត្រូវច្រៀងបទផ្សេងៗស្របតាមស្ថានភាពបរិយាកាសនៃរឿង ដោយមានភ្លេងប្រគុំកំដរជាមួយផង។ ការរំកិលសាច់រឿងពីឆាកមួយទៅឆាកមួយប្រព្រឹត្តទៅដោយសន្ទឹកស្គរ និងឡោ ។

-សាច់ភ្លេង : ល្ខោនបាសាក់ សាច់ភ្លេងដែលនៅរក្សាពណ៌សម្បុរចិនមានចំនួន២២បទ ខ្មែរបង្កើតបាន២៨បទ ដោយយកបទមហោរីបន្ថែមតាមទម្រង់បាសាក់៨៩បទ បទភ្លេងបារាំងមានចំនួន១៦បទ។

-ពាក្យពេចន៍ : តួអង្គអាចប្រើពាក្យច្នន ពាក្យកាព្យ កំរងកែវ ឬពាក្យរាយ ។ ក្រៅពីនេះ គេបានប្រើរាជសព្ទ និងសង្ឃសព្ទដែរ ។

៦. អត្ថបទល្ខោនដកស្រង់នេះមានបីឆាក គឺឆាកទី៥ ឆាកទី៦ និងឆាកទី៧។

- ការប្តូរឆាកពីឆាកទី៥ទៅឆាកទី៦ កើតនៅពេលបញ្ចប់ការសន្ទនារបស់តួអង្គពីរ គឺស្តេចសម្រែ និងឧកញ៉ាពិភាអំពីការទៅទាក់ល្បួងលោមបញ្ចុះបញ្ចូលជំទាវស្រែន ដើម្បីយកមកធ្វើជាមហេសីរបស់ស្តេចសម្រែ ហើយលេចចេញតួអង្គថ្មី គឺជំទាវស្រែននិងខ្ញុំបម្រើស្រីប្រុសក្នុងការសំដែង

សកម្មភាពថ្មី។

- ការប្តូរឆាកពីឆាកទី៦ទៅឆាកទី៧ កើតនៅពេលបញ្ចប់ការសន្ទនារបស់តួអង្គពីរ គឺជំទាវស្រែននិងឧកញ៉ាពិភា អំពីការយាងស្តេចសម្រែឱ្យមកចូលរួមក្នុងពិធីមង្គលការកូនរបស់ជំទាវស្រែនប្តូរទៅសដែងសកម្មភាពថ្មី គឺសកម្មភាពក្នុងពិធីមង្គលការដែលមានតួអង្គជំទាវស្រែន ឧកញ៉ាពិភា ខ្ញុំបម្រើស្រីប្រុស ស្តេចសម្រែ កងទ័ពតេជោមាស និងយ៉ត។

៧. តាមរយៈសកម្មភាពជំទាវស្រែន បានបង្ហាញពីតួនាទីដ៏សំខាន់របស់ស្ត្រីខ្មែរក្នុងការអភិវឌ្ឍសង្គមដូចជា៖

-ស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ

-គ្រប់ការងារទាំងអស់ បើមានស្ត្រីចូលរួមប្រាកដជាទទួលបានជោគជ័យ

-មានស្ត្រីមានការអភិវឌ្ឍ

-ស្ត្រីជាកម្លាំងចលករក្នុងការរួមចំណែកកសាង និងការពារជាតិ

៨. សិក្សាអំពី៖

**-កាលអាកាសនៃរឿង**

+កាល : រឿងរ៉ាវទាំងអស់ប្រព្រឹត្តទៅក្នុងរជ្ជកាលស្តេចជ័យចេស្តា (គ.ស.១៥៧៥-១៥៩៣)។

+អាកាស : បន្ទាយគរ, មាត់ទន្លេ, សួនផ្កាក្បែរមាត់ទន្លេ,

ផ្ទះជំទាវស្រែន (ផ្សារកំពង់ហាវ) រាជធានីឧដុង្គ កំពង់ស្វាយ...។

**-និមិត្តរូបវិធី** : ការយកតួអង្គជំទាវស្រែនជាតំណាងស្ត្រីខ្មែរ ដែលជួយស្វាមីតាំងពីកិច្ចការក្នុងផ្ទះ រហូតដល់កិច្ចការសង្គម ដូចសុភាសិតខ្មែរចែងថា "សំណាបយោងដី ស្រីយោងប្រុស" (ជំទាវស្រែនជួយកំចាត់ស្ដេចសម្រែ) ។

**-ឧបមានវិធី** : អ្នកនិពន្ធធ្វើការប្រៀបធៀបរូបសម្ផស្សជំទាវស្រែនទៅនឹងទេពកញ្ញា ដូចស្ដេចសម្រែនិយាយ "លើសពីនេះទៀត ឮថានាងស្អាតដូចទេពអប្សរអ៊ីចឹង ហ៊ឺ...ហ៊ឺ..."។

៩. "ក្ដៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ" ដែលជាចំណងជើងអត្ថបទអំណាននេះ គឺសំដៅទៅលើអំពើរបស់ជំទាវស្រែន ក្នុងសកម្មភាពការពារជាតិ ដែលជាយុទ្ធវិធីដ៏សាមញ្ញទន់ភ្លន់ ដើម្បីក្រសោបចាប់ស្ដេចសំរែ និងបក្សពួក។ ចរិតលក្ខណៈរបស់ស្ត្រី ទោះបីពុំសូវមានកម្លាំងកាយរឹងមាំដូចបុរសក៏ពិតមែន ប៉ុន្តែនាងក៏មានលទ្ធភាពយកចរិតធម្មជាតិរបស់នាងមកប្រើជាអាវុធក្នុងការបំបាក់ស្មារតីរបស់សត្រូវឱ្យចាញ់កលរបស់នាង ។

អំណះអំណាងបញ្ជាក់ : ជំទាវស្រែនបានលះបង់កិត្តិយសផ្ទាល់ខ្លួន ដើម្បីផលប្រយោជន៍ជាតិជាធំ ។ ខិតខំសំដែងឆាកល្ខោនមួយយ៉ាងប៉ិនប្រសប់ បង្កើតស្ថានភាពផ្សេងៗ ប្រឌិតដូចជារឿងពិត ។



## សូរស្រៈ

*១— សូរស្រៈ គឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេង បន្លឺឡើងដោយគ្មានទំនប់ ប្រកបដោយភាពច្បាស់លាស់ ។*

ស្រៈអាចចែកតាម បរិញ្ញកអ-អ៊ បរិញ្ញកវែង-ខ្លី និង បរិញ្ញកទោល-ផ្សំ ។

លំហាត់

១. ចូរស្រង់ពាក្យពីក្នុងប្រអប់ខាងក្រោម ដាក់ទៅក្នុងតារាងក្រុមពាក្យសូរស្រៈពួកអ ក្រុមពាក្យសូរស្រៈពួកអ៊ និងក្រុមពាក្យសូរស្រៈពួកអៈ-អ៊ៈ ឱ្យបានត្រឹមត្រូវ ។

| |
|---|
| របៀន សប្បាយ ជឿនលឿន រលួស ទាហាន តារា ស្ពាន កៀន ស៊ី ដំណោក កញ្ជ្រឹង តឿ រណារ ឆ្នាំង ពាង បង្គួរ មៀន ជញ្ជ្រឹង ចាប៉ី ហ៊ឹង ស្ងួរ គ្រួ ញញួរ ជឿ សសរ ទុក្ខ វិជ្ជា សរសើរ ។ |

២. ចូររកពាក្យដែលមានសូរស្រៈពួក អ សូរស្រៈពួក អ៊ និងសូរស្រៈពួកអ-អ៊ ក្នុងមួយក្រុមឱ្យបាន១០ពាក្យ

៣. ចូរអ្នករៀបពាក្យក្នុងប្រអប់ខាងក្រោមនេះដាក់ទៅតាមក្រុមសូរស្រៈវែង ឬសូរស្រៈខ្លី។

| |
|---|
| អន្ទិត ទាត់ ញញឹម ប្រគល់ ក្រមា របាំង រឹង សរសេរ លំបាក ហាត់ ដាក់ ឡើង រលួយ មោះមុត ដេក រនាំង ត្រកួន សំណាញ់ កសាង បណ្ដោយ ស្រវឹង លិច ឪទិន ខ្ទីង សំបក បាល់ កង់ សារាយ ទុន |

៤. ចូរស្រង់ពាក្យសូរស្រៈវែង និងសូរស្រៈខ្លីឱ្យបាន១០ពាក្យក្នុងមួយក្រុមពីក្នុងអត្ថបទអំណានទី១។

៥. ចូររកពាក្យដែលមានស្រៈទោល និងស្រៈផ្សំក្នុងមួយក្រុមឱ្យបាន ១០ពាក្យ។

**ចម្លើយ**

១. ស្រង់ពាក្យដាក់ទៅក្នុងតារាងតាមក្រុម ៖

| សូរស្រៈពួកអ | សូរស្រៈពួកអ៊ | សូរស្រៈពួកអ-អ៊ |
|---|---|---|
| តារា ដំណោក<br>ឆ្នាំង ចាប៉ី<br>សសរ សរសើរ<br>រណារ | ទាហាន ស្ពាន<br>ស៊ី ពាង ហ៊ឹង<br>ជញ្ជាំង ទុក្ខ<br>វិជ្ជា | រលួស ញញួរ<br>របៀន ក្បៀង<br>ជឿនលឿន<br>គឿ បង្គួរ<br>មៀន សួរ ជឿ |

២. រកពាក្យដែលមានស្រៈពួក អ ស្រៈពួក អ៊ និងស្រៈពួកអ-អ៊ ក្នុងមួយក្រុមឱ្យបាន១០ពាក្យ :

-ស្រៈពួកអ : សីហា កញ្ញា ចិន្តា ចំប៉ី តាខេ បង្កើត ប្រយោជន៍ សំដី លោន បណ្ដើរ...។

-ស្រៈពួកអ៊ : គ្នា ស៊ី ធ្វើ គុហា ទាហាន ល្អុត ទាំង រុយ មូស លេង យំ នំ ញី ...

-ស្រៈពួកអ-អ៊ : តឿ រៀន រលឿ មៀន របៀន លឿន រួញ ទួល រឿង ទួញ បង្រៀន ...។

៣. រៀបពាក្យក្នុងប្រអប់ដាក់ទៅតាមក្រុមស្រៈវែង ឬស្រៈខ្លី

| ស្រៈវែង | ស្រៈខ្លី |
| --- | --- |
| ក្រមា សរសេរ លំបាក ឡើង រលួយ ដេក ត្រកួន កសាង បណ្ដោយ ខ្ទឹង សំបក សារាយ | អន្ទិត ទាត់ ញញឹម ប្រគល់ របាំង រឹង ហាត់ ដាក់ មោះមុត រនាំង សំណាញ់ ស្រវឹង លិច ឪទិន បាល់ កង់ ទុន |

៤. ស្រង់ពាក្យស្រៈវែង និងស្រៈខ្លីឱ្យបាន១០ពាក្យក្នុងមួយក្រុមពីក្នុងអត្ថបទអំណានទី១ (ក្ដៅស៊ីរាក់ត្រជាក់ស៊ីជ្រៅ) :

**-ស្រៈវែង : សូម ក្រាប ថ្វាយ ចូល មាន ទូល ការ ករុណា តេជោមាស ឧកញ៉ា មែន...។**

-ស្ទូរស្រៈខ្លី : បង្គំ ទ្រង់ ក្រាស់ សំខាន់ ណាស់ របស់ ស្រលាញ់ កាន់ កាប់ ស្មោះ... ។

៥. រកពាក្យដែលមានស្រៈទោល និងស្រៈផ្សំក្នុងមួយក្រុមឱ្យបាន ១០ពាក្យ :

-ស្រៈទោល : គ [kɔ:] បាន [ba:n] ដេក [de:k] ហូរ [ho:] គ្រែ [krɛ:] គឺ [kɯ:] ស្លូ [slɒ:] ត្រា [tra:] ជុច [cuc] លេង [le:ŋ] ឈឺ [chɯ:] យើង [yɤ:ŋ] ...

-ស្រៈផ្សំ : ដី [dɛi] ដើរ [daə:] ល្បែង[lbaɛ:ŋ] ទៅ [təu] រៀន [ri:en] លឿន [lɯ:ən] ឡើង [laə:ŋ]



# រឿង ចៅកែចិត្តចោរ

សំណួរ

១. តើពូហាំមានតួនាទីជាអ្វី? ហើយបានធ្វើសកម្មភាពអ្វីខ្លះ?

២. ហេតុអ្វីបានជាពូហាំបើកឡានបុកឡានអុងប៉ាងហុងលី?

៣. ហេតុអ្វីបានពូហាំមានទំនាស់ជាមួយចៅកៃ?

៤. តើរឿងនេះមានតួអង្គណាខ្លះ? ចូរប្រាប់តួអង្គឯក និងតួអង្គរង?

៥. ចូរវិភាគតួអង្គពូហាំ និងចៅកៃ ។

៦. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី? ហើយប្រភេទនៃអត្ថបទនេះមានរចនាបថខុសគ្នាពីប្រភេទអត្ថបទរឿងប្រលោមលោក ឬរឿងនិទានយ៉ាងដូចម្តេច?

៧. តើអត្ថបទដកស្រង់នេះមានប៉ុន្មានឆាក? តើការប្តូរឆាកកើតឡើងពេលណា?

៨. តើអត្ថបទដកស្រង់នេះមានរចនាបថយ៉ាងដូចម្តេចខ្លះ?

៩. ចូរសិក្សាអំពីកាលអាកាសនៃរឿង ។

១០. ចូរបង្ហាញឱ្យឃើញថាអំពើរបស់តួអង្គចៅកៃ តួអង្គហាំ ជាអំពើខុសឆ្គងនឹងផ្លូវ :

-ពុទ្ធច[illegible] និងរកអំណះអំណាង ។

-អាណាចក្រ និងរកអំណះអំណាង ។

-សីលធម និងរកអំណះអំណាង ។

១១. ចូរពន្យល់សំដីរបស់តួអង្គ :

-ហាំ "កុំរវាងទឹកប្រាក់ ហើយមើលងាយមនុស្ស" ។

-ថៅកែ "កុំរវាងទឹកចិត្តមនុស្សធម៌ ហើយមើលងាយកម្លាំងប្រាក់" ។

## ចម្លើយ

១. តួអង្គពូហាំៈ

- តួនាទី : ជាអ្នកបើកឡានឱ្យថៅកែ ។
- សកម្មភាព

\+ មកផ្ទះថៅកែដើម្បីទារលុយពីថៅកែចំនួន១ម៉ឺនរៀល ជាលុយដែលថៅកែផ្តល់ឱ្យបើកឡានបុកឡានរបស់ថៅកែហុងលី ធ្វើឱ្យស្លាប់មនុស្សអស់៣នាក់ ។

\+ ឈ្លោះទាស់ទែងជាមួយថៅកែ ព្រោះថៅកែមិនព្រមឱ្យលុយគាត់ ។

២. បានជាពូហាំបើកឡានបុកឡានអ៊ុងប៉ាងហុងលី ព្រោះធ្វើតាមបញ្ជារបស់ថៅកែដើម្បីបានលុយ១ម៉ឺនរៀលយកទៅផ្គត់ផ្គង់គ្រួសារ ។

៣. បានពូហាំមានទំនាស់ជាមួយថៅកែ ព្រោះថៅកែមិនឱ្យលុយមួយម៉ឺនរៀលតាមការសន្យា ។

៤. រឿងនេះមានតួអង្គដូចជា : ហាំ ថៅកែ ផានីត ទ្រី សុខ មាន គង់ នាងយ៉ាន និងក្រុមនគរបាល ។

+តួអង្គឯក : ហាំ

+តួអង្គរង : ថៅកែ ទ្រី សុខ មាន គង់ ផានីត...

៥. វិភាគតួអង្គពូហាំ និងថៅកែ៖

+ហាំ

**ក-គុណសម្បត្តិ**

-ជាមនុស្សម៉ឺងម៉ាត់គោរពសច្ចធម៌

-ស្រឡាញ់គ្រួសារ ប្រពន្ធ កូន ម្ដាយ

-ជាកូនកតញ្ញូ

-មានទំនួលខុសត្រូវលើគ្រួសារ

-រិះរកគ្រប់មធ្យោបាយដើម្បីផ្គត់ផ្គង់គ្រួសារ

-មិនចុះញ៉ូមនឹងការគំរាមកំហែង

-ស្រឡាញ់យុត្តិធម៌

**ខ-គុណវិបត្តិ**

-ដើម្បីជីវភាពផ្ទាល់ខ្លួនហ៊ានប្រព្រឹត្តអំពើទុច្ចរិត

-ជាមនុស្សគិតខ្លី យកប្រាក់ជាធំ

-ប្រព្រឹត្តបទល្មើសផ្ទុយពីច្បាប់សង្គម

-បន្សល់នូវភាពឈឺចាប់ដល់គ្រួសារ

+ថៅកែ

**ក-គុណសម្បត្តិ**

-ជួយឱ្យផានិតនិងកម្មករដទៃទៀតមានការងារធ្វើ

-ជួយសាងសង់សាលារៀន ទិញឆ្នោតវត្ត ជួយសមាគម សង់សាលាបាលី...

-បានជួយផ្តល់លុយកាក់ខ្លះៗឱ្យគ្រួសារបាំ

**៥ -គុណវិបត្តិ**

-ជាថៅកែចិត្តចោរ

-មានគំនិតបំផ្លាញឈ្មានីសអ្នករកស៊ីដូចគ្នា

-ជាមនុស្សអាក្រក់ អាងទីកលុយ យកលុយទិញក្បាលអ្នកក្រ

-កេងប្រវ័ញ្ចញើសឈាមកម្មករ

-ជាមនុស្សគ្មានសតិសម្បជញ្ញៈ

-ជាមនុស្សមិនគោរពពាក្យសច្ចៈ

-ប្រមាថយុត្តិធម៌ យកលុយបិទមាត់គេយករួចខ្លួន

៦. អត្ថបទនេះជាប្រភេទអត្ថបទល្ខោននិយាយ ហើយប្រភេទនៃអត្ថបទនេះ មានរចនាបថខុសគ្នាពីប្រភេទអត្ថបទរឿងប្រលោមលោក ឬ រឿងនិទានត្រង់៖

-អត្ថបទចែកជាឈុតនិងឆាក

-មានរាយឈ្មោះនិងមុខងារតួអង្គនៅខាងដើម

-តួអង្គនិយាយឆ្លើយឆ្លងគ្នាដោយផ្ទាល់

-អ្នកនិពន្ធប្រាប់ពីសកម្មភាពរបស់តួអង្គដែលត្រូវសំដែងដាក់ក្នុងវង់ក្រចក ។

៧. អត្ថបទដកស្រង់នេះមាន២ឆាក គឺឆាកទី២ និងទី៣ ។ ការប្តូរឆាកពីឆាកទី២ ទៅឆាកទី៣ កើតឡើងនៅពេលដែលប្តូរព្រឹត្តិការណ៍ជម្លោះរវាងតួអង្គពីរគឺថៅកែនិងពូបាំ មកបង្ហាញព្រឹត្តិការណ៍ដែល

មានតួអង្គថ្មីទៀត គឺនាយឃាតនិត សុខ មាន ទ្រី គង់ ជជែកគ្នាអំពីឈ្មោះរបស់ថៅកែនិងតួឃាត ។

៨. អត្ថបទដកស្រង់នេះមានរចនាបថជាបែបល្ខោននិយាយ ។ *(សូមមើលត្រង់ចម្លើយទី៦)*

៩. កាលរកាសនៃរឿង : ដំណើររឿងប្រព្រឹត្តទៅនៅកន្លែងធ្វើការរបស់ថៅកែចិត្តចោរ ប្រហែលម្ភៃ(ម៉ោងរាត្រី)ទះធំ ។

១០. បង្ហាញអំពើខុសឆ្គងរបស់តួអង្គថៅកែ តួអង្គឃាត ទាក់ទងនឹងផ្លូវពុទ្ធចក្រ អាណាចក្រ និងសីលធម៌

-ពុទ្ធចក្រ : អំពើរបស់អ្នកទាំងពីរកើតចេញពីលោភៈដោយចេតនា ព្រោះ៖

+ ថៅកែ : ប្រើឃាំឱ្យបុកគេ ដើម្បីផ្តួលរំលំដៃគូរកស៊ីដូចគ្នា

+ ឃាំ : ធ្វើតាមបញ្ជាទុច្ចរិតដើម្បីប្រាក់ ។

សរុបអ្នកទាំងពីរប្រព្រឹត្តខុសក្នុងទោសបាណាតិបាត(បៀតបៀនជីវិតអ្នកដទៃ) និងមុសាវាទ (ភូតកុហក) ។

-អាណាចក្រ : អ្នកទាំងពីររួមគ្នាប្រព្រឹត្តអំពើទុច្ចរិត៖

+ ថៅកែ : រៀបចំផែនការ

+ អនុវត្តផែនការ

សរុបមកអ្នកទាំងពីរត្រូវមានទោសពីបទបៀតបៀនជីវិតមនុស្សដោយចេតនា ។

-**សីលធម៌** : ត្រូវរង្គទាំងពីរបាត់បង់មនសិការ វិចារណញ្ញាណ សម្បជញ្ញៈ និងស្មារតីមនុស្សធម៌។ យកជីវិតមនុស្សមកលេង សើច។

១១. ពន្យល់ស័ដីរបស់ត្លុកអង្គ

-ហាំ "កុំអាងទឹកប្រាក់ **ហើយមើលងាយមនុស្ស**" មានន័យថា កុំអាងមានមាសប្រាក់ទ្រព្យសម្បត្តិអាចធ្វើអ្វីៗបានតាមចិត្តនោះ ព្រោះមាសប្រាក់ពុំអាចទិញឧត្តមគតិមនុស្សបានគ្រប់ពេល និង គ្រប់គ្នានោះឡើយ។ អ្នកខ្លះសុខចិត្តរស់នៅក្នុងភាពក្រលំបាក តែថ្លៃថ្នូរ ដោយពុំព្រមស្ថិតក្នុងអំណាចនៃទឹកប្រាក់។

-ចៅកែ "**កុំអាងទឹកចិត្តមនុស្សធម៌ ហើយមើលងាយកម្លាំង ប្រាក់**" មានន័យថា ចិត្តសប្បុរស ឬមនុស្សធម៌ពុំអាចឈ្នះ កម្លាំងទឹកប្រាក់បានទេ ពោលគឺមានប្រាក់គឺមានអ្វីៗទាំងអស់។ មនុស្សធ្វើអ្វីៗគ្រប់យ៉ាងសុទ្ធតែត្រូវការប្រាក់។

# រឿងតេជោយ៉ត

សំណួរ

១. តើតេជោយ៉តមានតួនាទីជាអ្វី? ហើយបានធ្វើសកម្មភាពអ្វីខ្លះ?

២. តើម៉ឺនចៃចុងរ៉ាក់មានតួនាទីជាអ្វី? ហើយបានធ្វើសកម្មភាពអ្វីខ្លះ?

៣. ហេតុអ្វីបានជាតេជោយ៉តសម្លាប់ម៉ឺនចៃចុងរ៉ាក់?

៤. តើរឿងនេះមានតួអង្គប៉ុន្មាននាក់? អ្នកណាខ្លះ? តើអ្នកណាជាតួអង្គឯក និងអ្នកណាជាតួអង្គរង? តើតួអង្គនីមួយៗមានតួនាទីជាអ្វី?

៥. តើតេជោយ៉តជាមនុស្សដូចម្តេច? ហើយអ្នកយល់យ៉ាងណាចំពោះទង្វើរបស់តេជោយ៉ត?

៦. តើអ្នកសង្កេតឃើញថាអត្ថបទដកស្រង់នេះមានប៉ុន្មានឆាក?

៧. ចូរបង្ហាញពីកាលអាកាសនៃរឿង ។

ចម្លើយ

១. តេជោយ៉តមានតួនាទីជាតេជោត្រួតខេត្តកំពង់ស្វាយ ។ ហើយបានធ្វើសកម្មភាពបោសសំអាតខ្មាំងរនុកក្នុង ។ ដឹកនាំទ័ពកំចាត់ពួកសៀមបះបោរ ។

២. ម៉ឺនចៃចុងរ៉ាក់មានតួនាទីជាកងទ័ព ហើយត្រូវជាប្អូនបង្កើតរបស់អ្នកម្នាងនូ និងជាប្អូនថ្លៃរបស់ព្រះចៅជ័យចេស្តា ។ ហើយបានធ្វើសកម្មភាពបបួលបក្សពួករត់ចោលជួរប្រឆាំងនឹងតេជោយ៉ត ជា

រនុកក្នុងរបស់ខ្លាំង។
៣. បានជាតេជោយ៉តសម្លាប់ម៉ឺនចៃចុងរ៉ាក់ ព្រោះតេជោយ៉តរកឃើញថាម៉ឺនចៃចុងរ៉ាក់ជារនុកក្នុងក្រោយខ្នង។
៤. រឿងនេះមានតួអង្គច្រើននាក់ ដូចជាតេជោយ៉ត ឧកញ៉ាព្រហ្មស្រី នាយទិន នាយតយ ម៉ឺនចៃចុងរ៉ាក់ និងបក្សពួក។ តួអង្គឯកគឺតេជោយ៉ត និងតួអង្គរងគឺម៉ឺនចៃចុងរ៉ាក់។ តួអង្គនីមួយៗមានតួនាទីជា :

-តេជោយ៉ត : មេទ័ព

-ម៉ឺនចៃចុងរ៉ាក់ · កងទ័ព

-ឧកញ៉ាព្រហ្មស្រី : អ្នកបម្រើការជាមួយតេជោយ៉ត

៥. តេជោយ៉តជាមនុស្សមាន៖

-ឧត្តមគតិជាតិខ្ពស់

-អង់អាចក្លាហាន ម៉ឺងម៉ាត់ក្នុងសង្គ្រាម

-មានយុទ្ធសាស្ត្រខ្ពស់ក្នុងការបោសសំអាតខ្មាំងផ្ទៃក្នុង

-យកច្បាប់ជាធំ

-មិនអនុគ្រោះចំពោះអ្នកល្មើសនឹងអាជ្ញា

-មានទំនួលខុសត្រូវចំពោះទង្វើរបស់ខ្លួន

ចំពោះទង្វើរបស់តេជោយ៉តខ្ញុំយល់ថា ជាទង្វើប្រកបដោយគតិយុត្តិ ព្រោះក្នុងនាមជាមេទ័ពត្រូវមានភាពម៉ឺងម៉ាត់ចំពោះអ្នកក្រោមបញ្ជា។
៦. អត្ថបទដកស្រង់នេះមាន១ឆាក។

៧. កាលអាកាសនៃរឿង :

+កាល : ប្រព្រឹត្តទៅនៅក្នុងរជ្ជកាលស្ដេចជ័យចេស្ដា។

+អាកាស : ក្រុងលង្វែក ខេត្តកំពង់ស្ពឺ បន្ទាយទាហាន...។

មេរៀនទី ៥

# អតីតកាល

## វិធីផ្ទួនពាក្យ និង វិធីរណ្តំ

*១– វិធីផ្ទួនពាក្យ គឺជាវិធីដែលកវីតាក់តែងដោយប្រើពាក្យ (ព្យាង្គ) តែមួយច្រើនដងក្នុងឃ្លា ឬវគ្គ ដើម្បីបង្ហាញ និងសង្កត់ន័យ ព្រមទាំងបង្កើតសំឡេងគួរឲ្យចាប់អារម្មណ៍ ក្នុងវគ្គសំណេរបស់ខ្លួន ។*

លំហាត់

ចូរបង្ហាញវិធីផ្ទួនពាក្យនៅក្នុងវគ្គខាងក្រោម ៖

ត្រីត្រីត្រីត្រី     ពេញទឹកពេញដី     ត្រីហូបមិនអស់
ត្រីច្រើនមុខណាស់     ផតខ្នះខាតសោះ     ហូបងៀតឬស្រស់
តាមចិត្តហុកចុក ។

ត្រីឆ្អើរត្រីងៀត     ត្រីប្រឡាក់ទៀត     ត្រីផ្អកប្រហុក
ត្រីម៉ាទិកត្រី     ប្រុសស្រីសំរុក     បានច្រើនស្រណុក
ប្រមូលធនធាន ។

ចម្លើយ : ក្នុងវគ្គដកស្រង់ខាងលើនេះគឺវិធីផ្ទួនពាក្យ "ត្រី" ។

*២– វិធីរណ្តំ គឺជាវិធីដែលកវីប្រើព្យញ្ជនៈដដែលៗ ឬស្រៈដដែលៗ ក្នុងឃ្លា ឬវគ្គ ដើម្បីបង្កើតឲ្យសំឡេងពីរោះ និងបង្កើតរូបារម្មណ៍មួយ*

គឺសោកព្យាបារម្មណ៍ ។

លំហាត់

ចូរអ្នករកវិធីរណ្តំក្នុងវគ្គកាព្យខាងក្រោម ៖

[...]លីលាលយលង់ដានដងផ្លូវ ត្រង់ត្រូវមាគ៌ាឃ្លាតខ្វលខ្វាញ់
ខំស្រូតរូតរះកាត់គ្រោកគ្រាញ់ អរញ្ញវាលព្រៃរំពៃយល់ ។
ក្រឡេកក្រលៀងឆ្មៀងពីអាយ ច្បាស់ជានាងម្តាយទាវនិមល
នេះគឺមិនអ្នកដទៃទាល់ ទៅជិតទៀតស្គាល់ដល់ជាម្តង ។
នាងនោះស្ទុះឡើងលើគ្រឹះស្ពាន ប្រមាណត្រូវមាត់ជាដន្លង
ថាអញ្ជូអញ្ជើញមកប៉ុនប៉ង បំណងបំណាច់គ្រាច់ទៅឆ្ងាយ ។
ឬមួយនាងមករកយើងខ្ញុំ សូមសុំប្រសាសន៍សង់រ៉ាប់រ៉ាយ
ឱ្យដឹងកិច្ចកលអធិប្បាយ ចែកចាយកុំលាក់ឱ្យឡើយមក ។
អ្នកទាំងប៉ុន្មានបានដល់ផ្ទះ ម្តាយទាវអរណាស់ទើបរៀបស្លក
នំដាក់តុស្ពានរន្ទាន់យក ឡើងមកលើផ្ទះសំពះសួរ ។
ថាយើងខ្ញុំមកដោយចិត្តស្ម័គ្រ ទទួលធុរៈគួរមិនគួរ
ទោះបីមោះហ្មងសូមលន់តួ ឆ្លើងជួជួចម្តេចសូមមេត្តា ។[...]

ចម្លើយ

ព្យាង្គរណ្តំក្នុងវគ្គកាព្យខាងលើ ៖

-លី ├──┤ លា ├──┤ លយ ├──┤ លង់

-ដាន ├──┤ ដង. ត្រូវ ├──┤ ត្រង់

-ខ្វល ├──┤ ខ្វាញ់. រូត ├──┤ រះ

-ត្រោក ├──┤ ត្រាញ់, ទៅ ├──┤ ទៀត

-នាង ├──┤ នោ, ប៉ុន ├──┤ ប៉ង

-បំណង ├──┤ បំណាច, ស្ងួម ├──┤ សុំ

-រ៉ាប់ ├──┤ រ៉ាយ, កិច្ច ├──┤ កល

-ចែក ├──┤ ចាយ, មោះ ├──┤ ហ្មង



## អត្ថបទដកស្រង់រឿង ទុំទាវ

**សំណួរ**

១. ចូរបង្ហាញប្រភព និងប្រភេទអត្ថបទដកស្រង់ខាងលើ។

២. តើអត្ថបទនេះបានបង្ហាញពីទំនៀមទម្លាប់ខ្មែរយ៉ាងណាខ្លះ?

៣. តើកវីបានប្រើវិធីនិពន្ធបែបណាខ្លះ?

៤. ចូរអ្នកបង្ហាញវិធីបង្កើតកាព្យរូបារម្មណ៍ដោយវិធីផ្ទួន និងរណ្តំក្នុងអត្ថបទដកស្រង់នេះ។

៥. ចូរលើកលក្ខណៈសម្បត្តិ (រូប សំឡេង) របស់តួអង្គនៃទុំ និងពេជ្រមកបង្ហាញដោយភ្ជាប់អំណះអំណាងផង។

៦. តើអ្នកយល់យ៉ាងណាចំពោះសកម្មភាពនៃទុំនិងពេជ្រចាកចេញពីវត្តវិហារធំទៅជួញដូរ "តោក" ផង ស្នូត្រ(ទេសនា) ផង នៅតាម

ភូមិស្រុក?

៧. ចូរអ្នកធ្វើការសិក្សា "ថាដើរមានបួនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ បើដើរទៅក្តីបាសកសោះ កេរកោះថ្លោះធ្លោយឱ្យមានប្រាំ" :

-បង្ហាញពីខ្លឹមសារ

-តើវិធីតែងកាព្យ (ជួន ផ្ទួន រណ្តំ) មានភាពសមស្របឬទេ? ចូរបញ្ជាក់ពីមូលហេតុនៃចម្លើយនោះ ។

៨. តាមរយៈអត្ថបទខាងលើនេះ តើស្ថានភាពជីវភាពប្រជាជនខ្មែរយើងសម័យនោះមានលក្ខណៈដូចម្តេចដែរ?

ចម្លើយ

១. អត្ថបទដកស្រង់ខាងលើ៖

-មានប្រភពមកពីរឿងទុំទាវ របស់ភិក្ខុសោម ១៩១៥

-ប្រភេទអក្សរសិល្ប៍ទំនើប បែបប្រលោមលោកពាក្យកាព្យ ។

២. អត្ថបទនេះបានបង្ហាញពីទំនៀមទម្លាប់ខ្មែរដូចជា : កូនប្រុសត្រូវបួសរៀនក្នុងសំណាក់ពុទ្ធសាសនា ដើម្បីបានសិក្សារៀនសូត្រទាំងផ្លូវលោកនិងផ្លូវធម៌ ។ ឯកូនស្រីដល់ពេលពេញវ័យ ត្រូវចូលម្លប់ ដើម្បីអប់រំចរិយាមារយាទ និងវិជ្ជាមេផ្ទះ ។ ក្រៅពីនេះនៅមានទំនៀមទម្លាប់ដើរលក់ដូរទំនិញតាមភូមិស្រុកនានាផងដែរ ។

៣. វិធីនិពន្ធក្នុងអត្ថបទ :

**+ពណ៌នាវិធី** : កវីរៀបរាប់ "ចូរថ្លែងសំដែងដើមឈ្មោះទុំ នៅខេត្តត្បូងឃ្មុំដែនដីស្រែ......"

+**រចនាវិធី** : កវីតែងជាពាក្យកាព្យបទពាក្យ៧ យ៉ាងពិរោះរណ្ដំ

+**វចនវិធី** : កវីប្រើពាក្យពេចន៍លាយចម្រុះគ្នា៖

-ពាក្យសាមញ្ញ : ម៉ែ ឪ វា ស៊ី ដើរ.......

-ពាក្យសង្ឃសព្ទ : ឆាន់ ពុទ្ធដីកា.....

-ពាក្យកំចីបាលីសំស្ក្រឹត : ប្រាជ្ញា កេរ្តិ៍ .......

+**និទានវិធី** : អ្នកនិពន្ធប្រើវិធីនិទានបែបបុរសទី៣

+**សំវាទវិធី** : ការសន្ទនារវាងទាវនិងនោ. ទាវនិងម្ដាយ ។

+**ឧបមានវិធី** : ...សំឡេងស្រួយស្រាប់ស្ដាប់ភាសា ដូចសត្វសារិកាពិសារចេក... ។

៤. កាព្យរូបារម្មណ៍ដោយវិធីផ្ទួន និងរណ្ដំក្នុងអត្ថបទដកស្រង់នេះ៖

+វិធីផ្ទួនគឺជាវិធីដែលកវីប្រើព្យាង្គដដែលៗក្នុងឃ្លា ឬវគ្គ ។ ក្នុងអត្ថបទនេះកវីផ្ទួនពាក្យ : ជា(វគ្គទី១៤), និមន្ត(វគ្គទី៣៨), ថា(វគ្គទី១៦) .... ។

+វិធីរណ្ដំគឺវិធីដែលកវីប្រើព្យាង្គដដែលៗ ឬស្រៈដដែលៗ។ ព្យាង្គរណ្ដំក្នុងអត្ថបទមាន : ថ្លា ⊢⊣ ថ្លែង, សា ⊢⊣ សង, វ៉ាយ ⊢⊣ វ៉ាប់, ងឿង ⊢⊣ ងំ....... ។

៥. លក្ខណៈសម្បត្តិ (រូប សំឡេង) របស់តួអង្គនេនទុំ និងពេជ្រ៖

-ទុំ : មានរូបស្អាត សំឡេងពិរោះ (ចេះទេសនា សូត្រ) "...ទុំមានវោហារប្រាជ្ញាផង មានទាំងសំឡេងរូបខ្ចីល្អក់..." ។

-ពេជ្រ : មានរូបសម្បត្តិស្អាត ចេះផ្លុំប៉ីយ៉ាងពិរោះ "នេនពេជ្រចេះស្រេចខាងផ្លុំប៉ី ឈ្លាសវៃប្រសប់ភ្លេងមាំមួន..." ។

៦. *(ចម្លើយលើសិស្ស)*

៧. សិក្សាឃ្លា "ថាដើរមានបួនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥត មានមោះ បើដើរទៅក្តីបាសកនោះ កេរកោះថ្លោះធ្លោយឱ្យ មានប្រាំ" :

**+មានន័យថា**

-បើខ្លួនជាសង្ឃត្រូវប្រតិបត្តិសីល៤យ៉ាងហៅថា ចតុប្បា-វិសុទ្ធសីល គឺ៖

- បាតិមោក្ខសំវរសីល សង្រួមតាមសិក្ខាបទ២២៧
- ឥន្ទ្រីសំវរសីល សង្រួមឥន្ទ្រិយ៦
- អាជីវបារិសុទ្ធ ចិញ្ចឹមជីវិតតាមគន្លងសេចក្តីបរិ-សុទ្ធ
- បច្ចយសន្និស្សិត ពិចារណាសិន សឹមបរិភោគបច្ច័យ៤

-បើខ្លួនជាឧបាសក ឬគ្រហស្ថត្រូវប្រតិបត្តិសីល៥យ៉ាង ឬហៅថានិច្ចសីល គឺ៖

- បាណាតិបាតាវេរមណី : វៀរចាកការសម្លាប់
- អទិន្នាទានាវេរមណី : វៀរចាកការលួចទ្រព្យ
- មុសាវាទាវេរមណី : វៀរចាកការភូតកុហក
- កាមេសុមិច្ឆាចារាវេរមណី : វៀរចាកការលួចប្តី ប្រពន្ធ កូនគេ
- សុរាមេរយមជ្ជប្បមាទដ្ឋានាវេរមណី : វៀរ

ចាកការសេពគ្រឿងញៀន គ្រឿងស្រវឹង ។

+វិធីតែងកាព្យ

-ព្យាង្គចួន : មិនសមស្របទេព្រោះ៖

- មិនគោរពច្បាប់ចំណាច់ចួន (ម្តងចួននឹងព្យាង្គទី៤ ម្តងចួននឹងព្យាង្គទី២)

  ឧ. សង្ឃ (ព្យ.៧) ចួននឹង ត្រង់ (ព្យ.៤)

  នោះ (ព្យ.៧) ចួននឹង កោះ (ព្យ.២)

*សំគាល់ : ក្នុងក្បួនចំណាប់ចួន បើយកចួននឹងព្យាង្គទី២ត្រូវទី២រហូត តែបើយកចួននឹងព្យាង្គទី៤ត្រូវទី៤រហូត ។*

-ព្យាង្គថ្នួន : ដើរ . មាន ។

-ព្យាង្គរណ្តំ

- រណ្តំព្យញ្ជនៈ ត្រូវ ⟷ ត្រង់. មាន ⟷ មោះ. ថ្លោះ ⟷ ផ្លោយ
- រណ្តំស្រៈ ប្អូន ⟷ ខ្លួន. សោះ ⟷ កោះ ⟷ ថ្លោះ

៨. តាមរយៈអត្ថបទខាងលើនេះ យើងឃើញថាស្ថានភាពជីវភាពប្រជាជនខ្មែរយើងសម័យនោះមានលក្ខណៈអន់ថយ ពុំទាន់រីកចម្រើន គ្មានសាលារៀន កូនប្រុសត្រូវទៅបួសនៅវត្តដើម្បីបានសិក្សារៀនសូត្រ ។ កូនស្រីពុំបានរៀនសូត្រនឹងគេទេ ត្រូវចូលម្លប់ហាត់រៀនវិជ្ជាមេផ្ទះនិងចរិយាមារយាទពីសំណាក់ម្តាយ ។ ចំពោះ

ជីវភាពអ្នកស្រុកដែលជាកសិករមានការខ្វះខាតធ្វើឱ្យព្រះសង្ឃ ចេញធ្វើដំនួញដើម្បីរកស្បៀងដោយអង្គឯង។ ចំណែកមធ្យោបាយធ្វើដំណើរ គឺដោយថ្មើរជើង ទូក រទេះគោ...។

## សញ្ញាស្រះ

**លំហាត់**

១. ចូរពិនិត្យពាក្យខាងក្រោម រួចបង្ហាញថាព្យាង្គណាខ្លះមានស្រះកប់គ្នានៅជាមួយៈ "ក ភូមិ ខត្រី ដើមគ ទូកង ដើមញ ឆ្នាំច"។

២. ចូរប្រាប់ទីតាំងសញ្ញាស្រះភ្ជាប់គ្នាទាំងអស់ដែលភ្ជាប់ជាមួយនឹងព្យញ្ជនៈដោយបង្ហាញឧទាហរណ៍ផង។

៣. ចូររកនាមអ្នកកវីដែលមាននៅក្នុងកំណាព្យដកស្រង់នេះ ៖

យើងនឹងថ្លែងនាមតាមបញ្ញា ដើមថាតាមឈ្មោះចំពោះងាយ
តួ "ស" រាប់រៀបធៀបនិយាយ ទើបខាយប្រកបរាប់រៀបទៅ។
ទាញយារ "ស" សព្ទប្រកប "ម" បាំងឈើលើ "ស" ទើប បានត្រូវ
ឈ្មោះដើមដូចនឹងពីម៉ែឪ ឥឡូវនាមបែកចែកដោយគុណ។

៤. ចូរសរសេរសួរនៃស្រះពេញតួចំពោះពាក្យ "ល្បសាន ឥន្ទ ឧក្រិដ្ឋ រឮក ឯវ ឥច្ឆា ឪម៉ាល់ ឮរាវីណា"។

**ចម្លើយ**

១. ព្យាង្គដែលមានស្រះកប់គ្នានៅជាមួយគឺ : "ក ខ គ ង ញ ច"។

២. ទីតាំងសញ្ញាស្រៈភ្ជាប់តួទាំងអស់ដែលភ្ជាប់ជាមួយនឹងព្យញ្ជនៈ ៖

-នៅខាងឆ្វេងព្យញ្ជនៈ ។ ក. េ + ក > កេ

-នៅខាងស្ដាំព្យញ្ជនៈ ។ ខ. ស + ា > សា

-នៅខាងលើព្យញ្ជនៈ ។ គ. ល + ី > លី

-នៅខាងក្រោមព្យញ្ជនៈ ។ ឃ. ក + ូ > កូ

៣. នាមអ្នកកវីដែលមាននៅក្នុងកំណាព្យដកស្រង់នេះគឺ "សោម" ។

៤. សរសេរសូរនៃស្រៈពេញតួ :

-ឦសាន [អី-សាន]

-ឥន្ទ [អិន]

-ឧក្រិដ្ឋ [អ៊ុ-ក្រឹត]

-រឭក [រ-លឹក]

-ឯវ [អេ-វ៉ាំង]

-ឥច្ឆា [អិច-ឆា]

-ឪម៉ាល់ [អឺវ-ម៉ាល់]

-ឰរាវ៍ណ [អៃ-រ៉ា-វ៉ាន់]

# បដិវិធី

១— *បដិវិធី ជាល្បិចមួយបែបដែលកវីលើកយកគុណភាពពីរ អំពើចលនា ឬសកម្មភាពពីរ សំនួនសេចក្ដីពីរ មតិពីរផ្ទុយគ្នា ដែលមានភាពផ្ទុយមកដាក់ប្រឈមគ្នាដើម្បីជាមធ្យោបាយពន្លេចឱ្យឃើញតំលៃអ្វីមួយដែលកវីចង់បង្ហាញ ។*

បដិវិធីចែកជាពីរបែប៖

១-កវីលើកយកអង្គពីរដែលមានគុណភាពអំពើ មតិ ទស្សនៈផ្ទុយគ្នាមកបង្ហាញ ។

២-ប្រឈមស្ថិតនៅត្រង់កវីយកអង្គតែមួយដែលមាន គុណភាពអំពើ មតិ ទស្សនៈប្រឈមគ្នាមកបង្ហាញ ( បដិវិធីបែបនេះច្រើនស្ថិតនៅក្នុងឃ្លាតែមួយ ) ។

**លំហាត់**

ចូរបង្ហាញពីវិធីប្រឈមក្នុងវគ្គនីមួយៗរបស់កំណាព្យខាងក្រោមៈ

១. ខ្លួនស៊ីតាមឃ្លាន ប្រើគេបំពាន គ្មានក្ដីរាណិត
ខ្លួនធាត់ថ្លាថ្លោស គ្នាចុះស្គមស្គិត សិរុកពតគិត
ខ្លួនស្រែកតែមាត់ ។

២. វាយតែជាតិខ្លួន ហើយស្រែកផ្ទួនៗ ថាខ្លួនវាយខ្លាំង
ឃើញសុទ្ធខ្មោចខ្មែរ នៅតែស្រវាំង ងងើលភាន់ភាំង
ថាខ្មែរអប្រិយ ។

៣. អ្នកស្រែធ្វើស្រូវ  ក្រោមភ្លៀងផ្គរត្រូវ  សូរ្យសែងចំហាយ
ផលហូបបបរ  ត្រដរខ្វះបាយ  អ្នកនៅសុខកាយ
បាយដូចសំឡី ។

៤. សក់ចេះតែស  ចិត្តចង់តែល្អ  មិនព្រមបណ្ដោយ
ឱ្យសាច់ឈាមផ្លាស់  ឱ្យចាស់ទន់ខ្សោយ  រត់តែតាមក្រោយ
ចាស់រត់លឿនជាង ។

ចម្លើយ

វិធីប្រឈមក្នុងវគ្គនីមួយៗរបស់កំណាព្យខាងលើ :

១. ប្រឈមគុណភាពមនុស្សពីរនាក់ ។

អ្នកប្រើ (ពួកកម្មាភិបាល) ⟷ អ្នកធ្វើ (ប្រជាជន)
↓ ↓
ធាត់ថ្លាថ្លោស ⟷ ស្គមស្វិត

២. ប្រឈមអំពើ និងវាចាក្នុងមនុស្សតែម្នាក់ ។

អំពើ ⟷ វាចា
↓ ↓
វាយជាតិខ្លួន ⟷ ថាវាយខ្មាំង

៣. ប្រឈមហេតុ និងផល :

| | | |
|---|---|---|
| (ហេតុ) | ⟷ | (ផល) |
| ↓ | | ↓ |
| អ្នកធ្វើស្រែ | ⟷ | ហូបបបរ |
| ↓ | | ↓ |
| អ្នកនៅសុខកាយ | ⟷ | បាយដូចសំឡី |

៤. ប្រឈមអត្ថៈខាងក្រៅ និងអត្ថៈខាងក្នុង៖

| | | |
|---|---|---|
| អត្ថៈខាងក្រៅ | ⟷ | អត្ថៈខាងក្នុង |
| ↓ | | ↓ |
| សក់ចេះតែស | ⟷ | ចិត្តចង់តែល្អ |
| ↓ | | ↓ |
| (វាចា) | ⟷ | (អារម្មណ៍) |

# ការពិតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

សំណួរ

១. ចូរនិយាយពីប្រវត្តិនៃការតាក់តែងនិពន្ធ និងបោះពុម្ពផ្សាយអត្ថបទនេះ ។

២. តើវគ្គណាមួយដែលទ្រទ្រង់ចំណងជើងកំណាព្យនេះ?

៣. តាមរយៈកំណាព្យនេះ តើសង្គមខ្មែរមានបរិយាកាសដូចម្តេចខ្លះ?

៤. ចូរបង្ហាញពីឧបមានវិធី និងបំរៀបន័យវិធីក្នុងអត្ថបទកាព្យខាងលើ ។

៥. ដើម្បីបង្កើតកាព្យរូបារម្មណ៍ក្នុងអត្ថបទកាព្យនេះ តើកវីបានប្រើវិធីផ្ទុន វិធីរណ្តំ និងវិធីបញ្ច្រាសដូចម្តេចខ្លះ?

៦. តើអ្នកយល់ដូចម្តេចចំពោះរបបកម្ពុជាប្រជាធិបតេយ្យ?

៧. តើលោកជួនម៉េនរស់នៅខេត្តណា? ស្រុកណា?

ចម្លើយ

១. ប្រវត្តិនៃការតាក់តែងនិពន្ធ និងបោះពុម្ពផ្សាយអត្ថបទនេះគឺ :

លោកជួនម៉េន និពន្ធស្នាដៃនេះឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦-៧៧ ។ លោកប្រើពេលមួយឆ្នាំ ដើម្បីនិពន្ធស្នាដៃកំណាព្យនេះ ព្រោះក្នុងមួយថ្ងៃលោកសរសេរតែមួយ ឬពីរល្បះតែប៉ុណ្ណោះ ។ ដោយមានបំណងចង់ប្រាប់ដល់

កូនខ្មែរជំនាន់ក្រោយ លោកជួនម៉ែនក៏លួចសរសេរអត្ថបទនេះដោយការប្រុងប្រយ័ត្នបំផុតព្រោះខ្លាចអង្គការដឹង។ លោកសរសេរក្រដាសស៊ីម៉ង់ត៍ សរសេរដីសម្ដងបន្តិចៗ។ ពេលសរសេរចប់ លោកទន្ទេញរហូតចាំមាត់ទើបលុបចោល ហើយព្យាយាមសូត្រជានិច្ចដូចសូត្រធម៌រៀងរាល់ថ្ងៃ។

ក្រោយថ្ងៃរំដោះ ៧មករា ១៩៧៩ លោកជួនម៉ែនបានរៀបចំសរសេរស្នាដៃនេះឡើងវិញ ដោយចងក្រងជាឯកសារចប់សព្វគ្រប់ចំនួន១៨២វគ្គ ហើយបោះពុម្ពនៅឆ្នាំ១៩៨០ មានចំនួន៥៩ទំព័រ។

២. វគ្គដែលទ្រទ្រង់ចំណងជើងកំណាព្យគឺវគ្គទី១ និងទី២ ។

៣. តាមរយៈកំណាព្យនេះ សង្គមខ្មែរសម័យនោះមានបរិយាកាសអាប់អួរ ប្រជារាស្ត្រខ្មែររស់នៅរងទុក្ខវេទនា ខ្លោចផ្សា ព្រាត់ប្រាសឪពុកម្ដាយបងប្អូន គ្មានសិទ្ធិសេរីភាព ប្រៀបដូចគុកឥតជញ្ជាំង ធ្វើការបាក់កម្លាំង បរិភោគមិនឆ្អែត។ ចំណែកវិស័យវប្បធម៌ធ្លាក់ដល់កម្រិតសូន្យ។

៤. ឧបមានវិធី និងបំរៀបន័យវិធីក្នុងអត្ថបទកាព្យខាងលើ៖

**+ឧបមានវិធី : គឺប្រើពាក្យ ដូច**

-វគ្គទី៥ : ...គាត់មានខ្លឹមសារ តែដូចស្រមោល...។

-វគ្គទី៨ : ក្ដៅដូចអស់គល់.....

-វគ្គទី១០ : ....ដូចអាទិទេព....

-វគ្គទី១២ : ...ដូចត្រីរលំភក់...

-វគ្គទី១៣ : ...ឡេះឡុញដូចស្វា...

-វគ្គទី២១ : ...ដូចខ្មោចបិសាច គេឱ្យអំណាច ដូចសត្វកង្កែប

-វគ្គទី២៤ : លាក់ខ្លួនដូចខ្លា....ទីសទាសដូចមាន់...

-វគ្គទី២៧ : ...មនុស្សដូចតិរច្ឆាន...

-វគ្គទី២៩ : ...ដូចអណ្តើកចូលភ្លើង...

-វគ្គទី៣១ : ...ទុក្ខគ្នាសែនធ្ងន់ ដូចទូលបព្វតា...

-វគ្គទី៣៣ : រំលែងគិតរស់ស្លាប់ ដូចមមាចនិងភ្លើង...

-វគ្គទី៣៤ : ជាតិខ្ជួចខ្ចេចខ្ចី ដូចផេះចំបើង... ។

+បំរៀបន័យ : កវីប្រើពាក្យ ស្មើ វាយចោល ដកដាក់ ដកចេញ

-វគ្គទី៤ ; សម្តីថាស្មើ តែឃើញអំពើ......

ជាន់កវាយចោល ។

-វគ្គទី៥ : ដកដាក់អង្គការ គាត់មានខ្លឹមសារ....

-វគ្គទី៣២ : ស្លោកគេប្រមាថ ដកចេញមិនខាត....

៥. ដើម្បីបង្កើតកាព្យរូបារម្មណ៍ក្នុងអត្ថបទកាព្យនេះ កវីបានប្រើវិធីផ្ទួន វិធីរណ្តំ និងវិធីបញ្ច្រាសដូចតទៅ ៖

-វិធីផ្ទួន : កវីផ្ទួនព្យាង្គតែមួយ ។ ឧទា- ខំស្រែកក្តែងៗ. ឱ្យយំឱ្យពេប ឱ្យអត់អាហារ.... ម្ចាស់ស្រែចំការ ម្ចាស់ដី ម្ចាស់ទឹក ម្ចាស់ព្រៃព្រឹក្សា ម្ចាស់រដ្ឋអំណាច ។...

-វិធីរណ្តំ : កវីប្រើព្យញ្ជនៈ ឬស្រៈដូចគ្នា ។

ឧទា.- រណ្តំព្យញ្ជនៈ៖ ចងចាប់ ដកដាក់...

-វណ្ណស្រះ៖ ទន់ភ្លន់ , សាលា,

**-វិធីបញ្ច្រាស** : កវីប្រើគុណបទបញ្ច្រាសមកវិញ ។

ឧទា. នីឡុងចំណាង...

៦. ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំយល់ថាជារបបមួយដែលសាហាវឃោរឃៅជាទីបំផុត ព្រោះវាបានសម្លាប់ពូជសាសន៍ឯងអស់រាប់ហោននាក់ដោយឥតអាណិតអាសូរ ។

៧. លោកជួនម៉ែនរស់នៅស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។



## ទំនុកច្រៀង និងរបាំស្នែងទន្សោង

**សំណួរ**

១. ចូរនិយាយពីប្រវត្តិរបាំស្នែងទន្សោង ។

២. ហេតុអ្វីបានជាគេដាក់ឈ្មោះថា "របាំស្នែងទន្សោង"?

៣. តើរបាំស្នែងទន្សោងនេះស្ថិតក្នុងទម្រង់សិល្បៈទីប៉ុន្មាន?

៤. តើទំនុកច្រៀងនៃរបាំស្នែងទន្សោងមានប៉ុន្មានផ្នែក? ចូរសង្ខេបផ្នែកនីមួយៗ ។

៥. ចូររកអត្ថន័យនៃចម្រៀងរបាំស្នែងទន្សោង ។

៦. តើអ្នកយល់ដូចម្ដេចចំពោះទំនុកច្រៀងនិងរបាំស្នែងទន្សោងនេះ?
៧. ក្នុងនាមជាកូនកុលបុត្រកុលធីតាខ្មែរដ៏ឆ្នើម តើអ្នកមានគំនិតយ៉ាងដូចម្ដេចក្នុងការអភិរក្សសិល្បៈខ្មែរ?

**ចម្លើយ**

១. ប្រវត្តិរបាំស្នែងទន្សោង

មានព្រានព្រៃម្នាក់ឈ្មោះ "ពរ" ទទួលព្រះរាជបញ្ជាពីព្រះរាជា ហើយចេញទៅរកបាញ់ទន្សោង។ ព្រានទៅបាត់យូរទើបត្រឡប់ចូលមកគាល់ព្រះរាជាវិញដោយដៃទទេ គ្មានបានអ្វីឡើយ។ ព្រះអង្គក៏ត្រាស់សួរថា ហេតុអ្វីក៏ពុំបានមួយសោះ។ ព្រានពរក្រាបបង្គំទូលថា ខ្លួនបានដើរទៅដល់ព្រៃដែលសំបូរទៅដោយសត្វទន្សោង និងម្រឹគដទៃៗ។ ប៉ុន្តែដោយទូលព្រះបង្គំរវល់តែមើលទស្សនីយភាពមួយយ៉ាងចម្លែកអស្ចារ្យណាស់ គឺសត្វទន្សោងមួយគូញីឈ្មោល វាចេះរាំយ៉ាងល្អ នាំឱ្យជក់ចិត្តមិនអាចបាញ់វាកើតឡើយ។ ទូលព្រះបង្គំផ្ទង់ស្មាលើស្នាលប១ចូលទៅប្រុងតែបាញ់វាដែរ តែដោយល្អមើលក្បាច់ចង្វាក់រាំរបស់សត្វនេះពេកក៏ខកខានរកតែដម្លោះព្រួញឱ្យរត់ទៅមិនកើត។ មិនតែប៉ុណ្ណោះមានខ្លាធំមួយដែលលបមកប្រុងនឹងចាប់ទន្សោងនោះដែរ ក៏ចាប់មិនកើត បែរជាជួយគោះជើងជាចង្វាក់ឱ្យសត្វនោះទៅវិញ។ ជាមួយក្បាច់រាំរបស់ទន្សោងមានកន្ទង់មួយហ្វូងហើរស្រែកប្រទក្សិណជុំវិញទន្សោងទាំងពីរដួយធ្វើជាសូរសំនៀងពិរោះល្វេងល្វើយ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ព្រះអង្គត្រាស់ប្រើឱ្យព្រានពរធ្វើតាមទស្សនិយភាពនោះថ្វាយព្រះអង្គ។ ព្រានពរក៏ខំធ្វើត្រាប់ឱ្យ

បានគ្រប់កាយវិការ និងសូរសំនៀងសត្វថ្វាយព្រះរាជាទ្រង់ទត និងទ្រង់ព្រះសណ្ដាប់គ្មានសល់ចន្លោះអ្វី ។

ការសំដែងកាយវិការរបស់ព្រានពរនោះហើយ ដែលកើតបានទៅជារាំរបាំនេះឡើង គឺ :

-អ្នកពាក់ស្នែងពីរនាក់ជាតំណាងទន្សោងញីឈ្មោល

-សំឡេងស្គរតំណាងសន្ទឹកខ្លាធំ

-សំលេងពួយជាតំណាងសូរសព្ទសត្វកន្លង់ ។

២. បានជាគេដាក់ឈ្មោះថា "របាំស្នែងទន្សោង" ព្រោះរបៀបរាំរបាំនេះអាស្រ័យដោយអ្នករាំពាក់ស្នែងទន្សោងនិងមានក្បាច់រាំត្រាប់តាមកាយវិការសត្វ ។

៣. របាំស្នែងទន្សោងនេះស្ថិតក្នុងទម្រង់សិល្បៈទី៧ ។

៤. ទំនុកច្រៀងនៃរបាំស្នែងទន្សោងមានបីផ្នែក ។

✱ ទន្សោងស្នែងនប់ រកស៊ីតែយប់
ទន្សោងស្នែងនប់ ថ្ងៃឡើងពួនព្រៃ ។
ទន្សោងស្នែងកែក ស៊ីបែកពីហ្វូង
ទន្សោងស្នែងច្រោង វិធហ្វូងបែកខ្ចាយ ។
ទន្សោងគោបា ស៊ីបន្លាបង្គំ
ទន្សោងព្រៃភ្នំ លេបក្រមុំទាំងមូល ។

*(តាមឯកសារលោក រ. បារាជាតិ)*

✱ សូរិយាល្ងាចថ្ងៃ សូរិយាល្ងាចថ្ងៃ
ទន្សោងគោព្រៃ រកស៊ីជើងភ្នំ

តូចស៊ីដោយតូច ធំស៊ីដោយធំ
ស៊ីតាមជើងភ្នំ ល្បះព្រិចខ្ចីល្អ ។
ស៊ីហើយវាផល់ ផល់គ្នាវីវរ
សុទ្ធតែឡើងក អួតមានកម្លាំង ។

*( តាមការចាំរបស់លោក កោត រឿន គ្រូនៅសាលាវិចិត្រ-សិល្បៈខេមរៈ )*

* បងដើរព្រៃ បងរុកព្រៃស្បាត
ដើរកាត់ព្រៃញោត លេចវាលចូលព្រៃ ។
ឡើងភ្នំចុះភ្នំ ថ្មជាភ្នំក្រៃ
ទាំងបន្លាឃ្លៃ ល្បាស់ព្រៃចលាស់ល្អ ។
ទន្សោងគោបា ក្បៀងញីវីវរ
ល្បះព្រៃចលាស់ល្អ ស្រណោះខែពិសាខ ។
កន្ទ្រែត១អើយ ទន្សោងគោបា
លេបបន្លាជើងភ្នំ លេបក្រមុំទាំងមូល ។
ជំនោរខ្យល់បក់ ត្រជាក់ខ្យល់ជូន
កាប់ឫស្សីចងក្បូន ជូនប្អូនទៅស្រុក ។
កន្សែងបងបាត់ បងកាត់មិនស្តាយ
បំណាច់ឃ្លាតឆ្ងាយ បងស្តាយតែប្អូនស្រី ។

*( តាមឯកសារលោក ខ្ញង់ អ៊ុច )*

៥. អត្ថន័យនៃចម្រៀងរបាំស្នេងទន្សោង គឺការច្រៀងរៀបរាប់ពីការរស់នៅចិញ្ចឹមជីវិតដែលអាស្រ័យរុក្ខជាតិ ធម្មជាតិ ព្រៃភ្នំ ជ្រលង

ដងអូរទៅតាមរដូវកាល ពេលវេលា ជាក្រុម ជាហ្វូង មានតូច មានធំ។ ជួនកាល គេឃើញមានទំនាស់រវាងគ្នានិងគ្នាផងដែរ ដោយការអួតអាងកម្លាំង អួតអាងឫទ្ធិអំណាច...។ ទន្ទឹមនឹងនេះ កវីគាត់តែងទំនុកនេះឡើងដើម្បីប្រៀបធៀបនឹងការរស់នៅរបស់មនុស្សក្នុងសង្គម ដែលជួនកាលរួមរស់សុខសាន្តនឹងគ្នា ជួនកាលមានទំនាស់ទាស់ទែងគ្នាដោយភាពអួតរវាងអំណាងទ្រព្យសម្បត្តិ បុណ្យសក្តិ ដោយការរំលោភសិទ្ធិគ្នាទៅវិញទៅមក ដោយការដណ្តើមផលប្រយោជន៍...។

៦. ចំពោះទំនុកច្រៀងនិងរបាំស្នែងទន្សោងនេះ ខ្ញុំយល់ថាថ្វីត្បិតតែរបាំនេះបានកើតឡើងច្រើនតំណមកហើយក៏ដោយ ក៏របាំនេះនៅតែមានតម្លៃរហូតដល់បច្ចុប្បន្ន។ នេះជាការឆ្លុះបញ្ចាំងឱ្យឃើញនូវតម្លៃអមតៈសិល្បៈវប្បធម៌ខ្មែរ បង្ហាញឱ្យឃើញនូវស្នាដៃ ទេពកោសល្យ ទស្សនៈ និងផ្ទត់គំនិតសង្គមអតីតកាលដ៏សម្បូរបែប និងប្រកបដោយភាពឈ្លាសវៃរបស់បុព្វបុរសខ្មែរយើងដែលចេះច្នៃប្រឌិតបង្កើតសិល្បៈរបាំ ដោយភ្ជាប់ទៅនឹងធម្មជាតិ។

៧. ក្នុងនាមជាកូនកុលបុត្រកុលធីតាខ្មែរដ៏ឆ្នើម ខ្ញុំត្រូវនាំគ្នាជួយថែរក្សាការពារ និងអភិរក្សមរតកដ៏មានតម្លៃនេះឱ្យនៅគង់វង្សជារៀងរហូត សមដូចពាក្យពំនោលថា "វប្បធម៌រលាយ ជាតិថ្លើងថ្លាន"។

# សង្ខេបអត្ថបទកាព្យជាពាក្យរាយ

**លំហាត់**

ចូរប្អូនសង្ខេបអត្ថបទពាក្យកាព្យដូចខាងក្រោមឱ្យទៅជាពាក្យរាយមានលក្ខណៈរៀបរយល្អ :

-អំណានទី១ "រឿងទុំទាវ"

ទុំជាកូនប្រុសរបស់កសិករខេត្តបាភ្នំ។ លុះធំដឹងក្តី ម្តាយបានយកទៅផ្ញើឱ្យបួសរៀនជាមួយលោកគ្រូសង្ឃរាជនៅវត្តវិហារធំ។ លោកគ្រូអធិការបានបង្ហាត់បង្រៀនទុំ ហើយបំបួសទុំជាសាមណេរ។ នៅឯវត្តនោះមាននេនម្នាក់ទៀតឈ្មោះពេជ្រ ជាសម្លាញ់នឹងទុំ ដែលមានប្រាជ្ញាប្រហាក់ប្រហែលទុំដែរ។ អ្នកទាំងពីរនាំគ្នាធ្វើគោកលក់។ ទុំមានរូបស្អាត មានសំឡេងពិរោះ ឯពេជ្រចេះផ្លុំប៉ីឈ្លាសវៃដូចគ្នា។ ថ្ងៃមួយអ្នកទាំងពីរបានគិតគ្នាចង់សុំលាលោកគ្រូសង្ឃរាជទៅលក់គោកនៅឯស្រុកឆ្ងាយ។ លោកគ្រូសង្ឃរាជបានយល់ព្រមឱ្យអ្នកទាំងពីរទៅ ប៉ុន្តែផ្តាំផ្ញើឱ្យប្រយ័ត្នប្រយែងកុំឱ្យធ្វើអ្វីខុសវិន័យសង្ឃ។

ទុំ និងពេជ្របាននាំគ្នាទៅលក់គោកនៅស្រុកឆ្ងាយរហូតដល់ស្រុកត្បូងឃ្មុំ។ ដោយសារនេនទាំងពីរបានវោហា និងសំដីពិរោះ ធ្វើឱ្យអ្នកស្រុកស្រឡាញ់ចូលចិត្ត ហើយនាំគ្នាជួយទិញគោកនេនទាំងពីរ ព្រមទាំងសរសើរមិនដាច់ពីមាត់។ ដំណឹងនេះក៏លេចឮដល់នាងទាវ។ ទាវក៏បានសុំអង្វរម្តាយឱ្យជូនទៅមើលនេនទាំងពីរ។ លុះពេលឃើញហើយ

ម្តាយទាវក៏ពេញចិត្ត ហើយបាននិមន្តនេនទាំងពីរទៅស្ងូត្រ និងឆាន់នៅផ្ទះខ្លួន។ នេនទាំងពីរក៏យល់ព្រម។

-វត្តដកស្រង់ (ក្នុងស.ស.ទំ.១២៤)

នៅខែមេសា ១៩៧៥ ប្រទេសខ្មែរធ្លាក់ចូលក្នុងរបបប្រល័យពូជសាសន៍ ប្រជាជនគ្មានសិទ្ធិសេរីភាព ត្រូវពួកវាវាយធ្វើបាប បង្អត់អាហារគ្មានត្រាប្រណី ពួកគេចង់បានអ្វីស្រេចតែអំពើចិត្តដោយយកលេសថាអង្គការស្នើសុំ តែតាមការពិតគឺជាការបំភាន់ភ្នែកប្រជាជនតែប៉ុណ្ណោះ។ បើយើងហ៊ានប្រឆាំង ឬសើរើ ត្រូវគេយកទៅសម្លាប់ចោល។

# លក្ខណៈអក្សរសិល្ប៍

លំហាត់

១. ចូរបង្ហាញលក្ខណៈមនុស្ស និងលក្ខណៈសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍ :

ក. រឿងរាមកេរ្តិ៍

ខ. រឿងព្រះវេស្សន្តរ

២. ចូរបង្ហាញលក្ខណៈសង្គមតាមរយៈស្នាដៃរឿងខាងក្រោមនេះ។ (អត្ថបទដកស្រង់ស.ស.ទំព័រ១៣១)

ចម្លើយ

១. លក្ខណៈមនុស្ស និងលក្ខណៈសង្គមតាមរយៈស្នាដៃអក្សរសិល្ប៍ :

ក. រឿងរាមកេរ្តិ៍

+លក្ខណៈមនុស្ស

-ការយំសោក ប្រច័ណ្ឌ ឈ្នានីសគ្នា

-ការគោរពពាក្យសច្ចៈ

-ការដណ្តើមរាជបល្ល័ង្គ

-ការច្បាំងគ្នា

-ការសងសឹក....... ។ល។

+លក្ខណៈសង្គម

-មានរបបរាជានិយមដែលដឹកនាំដោយព្រះមហាក្សត្រ

-មានមនុស្សច្រើនប្រភេទដែលតំណាងឱ្យសភាវៈល្អ (ព្រះរាម) និងសភាវៈអាក្រក់ (ក្រុងរាពណ៍)

-បញ្ហាដណ្ដើមអំណាចគ្នាក្នុងរាជវង្ស (នគរឣយុធ្យា នគរខាស់ខិនបុរី)

-បញ្ហាគ្រួសារ (ស្រឡាញ់ ប្រច័ណ្ឌ ច្រណែន...)

-ដោះស្រាយទំនាស់វិបត្តិដោយការធ្វើសង្គ្រាម (ព្រះរាមនិងនគរលង្កា)...

-យុទ្ធសាស្ត្រក្នុងការប្រមូលកងទ័ពដើម្បីធ្វើសង្គ្រាម (ព្រះរាមកេណ្ឌទ័ពស្វា ចំណែកក្រុងរាពណ៍បញ្ជាមេទ័ពរបស់ខ្លួនឱ្យចេញច្បាំង...)..............។

**ខ. រឿងព្រះវេស្សន្តរ**

+លក្ខណៈមនុស្ស

-ព្រះវេស្សន្តរចេះខឹង ចេះដាក់ទាន

-នាងមទ្រីចេះទួញសោក

-ប្រជារាស្ត្រខឹងព្រះវេស្សន្ត ដេញព្រះវេស្សន្តរចេញពីនគរ

-ជូជកជាស្ទូមឥតរើសមុខ, ជាមនុស្សលោភលន់ ...

+លក្ខណៈសង្គម

-មានរបបរាជានិយម ដែលព្រះមហាក្សត្រជាអ្នកដឹកនាំប្រទេស

-គោរពលទ្ធិប្រជាធិបតេយ្យ (ព្រះបាទស្រីសញ្ជ័យគោរពមតិភាគច្រើន និរទេសព្រះវេស្សន្តរចេញពីនគរ)

-បញ្ហាគ្រោះទុរភិក្សក្នុងនគរ សំបូរអ្នកសុំទាន...

២. លក្ខណៈសង្គមតាមរយៈស្នាដៃរឿងខាងលើគឺអ្នកនិពន្ធបានបង្ហាញពីសង្គមមួយដែលពោរពេញទៅដោយភាពអយុត្តិធម៌ ស៊ីសំណូកកេងប្រវ័ញ្ច បោកប្រាស់ពីសំណាក់អ្នកមានអំណាច មានទ្រព្យទៅលើអ្នកក្រ ទន់ខ្សោយ ។ ហើយរឿងនេះក៏បង្ហាញពីសង្គមមួយដែលមានសាមគ្គីភាពរវាងវណ្ណៈទាបដូចគ្នា ដើម្បីទាមទារកយុត្តិធម៌ ស្រឡាញ់យុត្តិធម៌ មិនលក់ខ្លួនឱ្យស្ថិតនៅក្រោមអំណាចនៃទឹកប្រាក់ផងដែរ ។



# លទ្ធិផ្សេងៗក្នុងសាសនាព្រាហ្មណ៍

សំណួរ

១. តើអត្ថបទខាងលើនេះមានប្រភពដកស្រង់ចេញពីរឿងណា? បទអ្វីខ្លះ?

២. ចូរប្រាប់តួអង្គក្នុងអត្ថបទនេះ។

៣. តើអត្ថបទនេះតែក្នុងសម័យកាលណា?

៤. ចូរប្រាប់មូលន័យនៅក្នុងអត្ថបទនេះ។

៥. ចូរកំណត់គំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ។

៦. ចូរបង្ហាញលក្ខណៈមនុស្សតាមរយៈអត្ថបទនេះ។

៧. ចូរបង្ហាញពីតម្លៃអប់រំនៅក្នុងអត្ថបទនេះ។

ចម្លើយ

១. អត្ថបទខាងលើនេះមានប្រភពដកស្រង់ចេញពីរឿងរាមកេរ្តិ៍ខ្មែរ ទី១។ អត្ថបទនេះមានបទសំរេប ដើតហើយច្រះ សំណា សំណាខរ សម្មេចភាណ ច្រះដុក ពិលាប បទដើត សំណារខម។

២. តួអង្គក្នុងអត្ថបទនេះមាន ព្រះរាម ព្រះលក្ស្មណ៍ កាកនាសូរ ឥសីពិស្វាមិត្រ សីតា ទសរថ ព្រះបាទមិថិលា(ជនក)...។

៣. អត្ថបទនេះតាក់តែងឡើងសម័យអង្គរ។ (ខ្មែរ១-១០, កំណាព្យ-ខ្មែរ, លីសុមុនី)

៤. មូលន័យនៅក្នុងអត្ថបទនេះគឺការប្រកួតប្រជែងលើកធ្នូសរដើម្បី

យកនាងសីតាធ្វើជាមហេសី ។

៥. គំនិតសំខាន់ៗនៅក្នុងអត្ថបទនេះ :

+ចាប់ពី "ដងនោះព្រះមកុដដ៏ភិរម្យ...........លលោតលេងលើសាខា ។" និយាយពីឥសីពិស្វាមិត្រធ្វើហោមពិធីថ្វាយព្រះរាមព្រះលក្ស្មណ៍ ។

+ចាប់ពី "ដងនោះមានអសុរា ............ឫក្សពេលាទៀងទាត់" ។ និយាយពីយក្សប្រែកាឡាជាក្អែកឈ្មោះកាកនាសូរមកបំផ្លាញហោមពិធី ។

+ចាប់ពី " ស្ដេចលេលាដងនោះ...............ក៏សុះនូវក្សៃយជន្មា" ។ និយាយពីឥសីពិស្វាមិត្រប្រើព្រះរាមឱ្យសម្លាប់កាកនាសូរ ។

+ចាប់ពី "ដងនោះព្រះបាទមិថិលា.............អរក្រៃនឹងរាជបុត្រីកញ្ញា" ។ និយាយពីព្រះបាទមិថិលា (ជនក) ធ្វើពិធីច្រត់ព្រះនង្គ័លហើយរើសបាននាងសីតាយកមកចិញ្ចឹម ។

+ចាប់ពី "ដងនោះឥសូរមិថិលា..........ក៏ស្ដេចនូវរឹងស្ថានស្ថិត" ។ និយាយពីព្រះបាទជនករៀបចំពិធីល្បងឫទ្ធិលើកធ្នូសរ ដើម្បីជ្រើសរើសស្វាមីឱ្យនាងសីតា ។

+ចាប់ពី "សម្ដេចលេលា ដងនោះ

បុរីអយុធ្យា ។ និយាយពីព្រះរាមចូលរួមប្រកួត ហើយទទួលបានជោគជ័យ ។

៦. លក្ខណៈមនុស្សតាមរយៈអត្ថបទនេះគឺ ៖

-ឥសីពិស្វាមិត្រចេះខឹង (ខឹងនឹងកាកនាសូរ)

-កាកនាសួរតំណាងឱ្យមនុស្សអាក្រក់

-ព្រះរាមសិក្សារៀនសូត្រ

-ព្រះរាមចូលរួមប្រឡងវាស់សមត្ថភាព

៧. តម្លៃអប់រំនៅក្នុងអត្ថបទនេះ គឺ៖

- ជឿលើហោមពិធី
- ជឿលើពិធីច្រត់ព្រះនង្គ័ល
- ឱ្យខិតខំរៀនសូត្រ ឱ្យមានចំណេះដឹងខ្ពស់ មានសមត្ថភាពពិតប្រាកដ ដើម្បីទទួលបានជោគជ័យនៅពេលប្រឡងប្រជែងនានា។
- ធ្វើល្អបានល្អ ធ្វើអាក្រក់តែវិនាស...។

# អំពីព្យញ្ជនៈទោល

លំហាត់

១. ចូរអ្នកជ្រើសរើសពាក្យតែមួយព្យាង្គទៅតាមលក្ខណៈបន្លឺ (លក្ខណៈទោល) ដែលមាននៅក្នុងអត្ថបទដកស្រង់ខាងក្រោមនេះ ដើម្បីបញ្ជាក់ថា :

ក. ព្យញ្ជនៈបបូរមាត់

ខ. ព្យញ្ជនៈធ្មេញ

គ. ព្យញ្ជនៈក្រអូមមុខ

ឃ. ព្យញ្ជនៈគន្លាក់ក្រអូម

ង. ព្យញ្ជនៈក្រអូមកណ្ដាល

ច. ព្យញ្ជនៈក្រអូមក្រោយ

ឆ. ព្យញ្ជនៈដើមមាត់

ជ. ព្យញ្ជនៈចន្លោះខ្សែសំឡេង។

[...]**សំណាខ្មែរ** ព្រះបាទទសរថភូធរ ស្ដេចសោកគក់គរ ឱរាប្រមៀលអាត្មា។ .............ក៏ស្ដេចន្ទវចរយាត្រា។ [...]

(ស.ស.ទំ.១៤០)

២. ចូរអ្នកជ្រើសរើសពាក្យខាងក្រោមនេះ ដែលជាតួព្យញ្ជនៈទោលៈ ដើរ ទាន រៀន សិស្ស ថ្នាក់ លេង សើច បិដក ព្រះ សិរៈ មន្ត។

៣. ចូរអ្នកជ្រើសរើសព្យញ្ជនៈខាងក្រោមនេះ ដែលជាព្យញ្ជនៈបប្ដូរមាត់ : បាញ់ វែង វ៉ារ មើល ផើង មេ ម៉ៃ ពាង រីង រែង រុំ រុក្ខា។

៤. ចូរអ្នកជ្រើសរើសព្យញ្ជនៈដើមមាត់ ដែលមានដូចខាងក្រោម :
ហ៊ឺហា ហ៊ោ លេង ការងារ ខកចិត្ត គោង តែងតែ ខំរៀន។

ចម្លើយ

១. ជ្រើសរើសពាក្យតែមួយព្យាង្គទៅតាមលក្ខណៈបន្ទី

ក. ព្យញ្ជនៈបប្ដូរមាត់ : បាទ

ខ. ព្យញ្ជនៈធ្មេញ : វរ

គ. ព្យញ្ជនៈក្រអូមមុខ : រថ

ឃ. ព្យញ្ជនៈគន្លាក់ក្រអូម : ដល់

ង. ព្យញ្ជនៈក្រអូមកណ្ដាល : ចូរ

ច. ព្យញ្ជនៈក្រអូមក្រោយ : ខ័ន

ឆ. ព្យញ្ជនៈដើមមាត់ : ហៃ

ជ. ព្យញ្ជនៈចន្លោះខ្សែសំឡេងៈ អា

២ ពាក្យដែលជាព្យញ្ជនៈ [illegible] ដើរ មាន រៀន សិស្ស លេង សើច បិដក សិរៈ មន្ត។

៣. ព្យញ្ជនៈដែលជាព្យញ្ជនៈបប្ដូរមាត់ : បាញ់ មើល ផើង មេ ម៉ៃ ពាង ។

៤. ព្យញ្ជនៈដើមមាត់ : ហ៊ឺហា ហ៊ោ ។

# គោលគំនិតសំខាន់នៃសាសនាព្រាហ្មណ៍
# និងព្រះពុទ្ធសាសនា

សំណួរ

១. តាមរយៈអត្ថបទនេះ ៖

-តើសាសនាព្រាហ្មណ៍មានកំណើតនៅឯណា?

-តាំងពីពេលណាមក?

-ហើយបានហូរចូលក្នុងដែនដីសុវណ្ណភូមិដូចម្តេចដែរ?

២. តើគេបែងចែកសាសនាព្រាហ្មណ៍ជាប៉ុន្មានដំណាក់កាលធំៗ? អ្វីខ្លះ?

៣. តើគម្ពីរវេទចែកចេញជាប៉ុន្មាន? ហើយគម្ពីរនីមួយៗខុសគ្នាដូចម្តេចខ្លះ?

៤. តើព្រះពុទ្ធសាសនាគេគោរពគម្ពីរអ្វី? ហើយមានអ្វីខ្លះ?

៥. តើភាពខុសគ្នានៃការគោរពគម្ពីរក្នុងព្រះពុទ្ធសាសនាមានលក្ខណៈដូចម្តេច?

៦. ចូរបង្ហាញពីតម្លៃអប់រំតាមរយៈ ៖

-ការគោរពសាសនាព្រាហ្មណ៍

-ការគោរពសាសនាព្រះពុទ្ធ ។

៧. ចូរអ្នកបង្ហាញបន្ថែមទៀតពីឥទ្ធិពលសាសនាព្រាហ្មណ៍ និង

សាសនាព្រះពុទ្ធដែលមាននៅក្នុងមង្គលការ ។

ចម្លើយ

១. តាមរយៈអត្ថបទនេះ ៖

-សាសនាព្រាហ្មណ៍មានកំណើតនៅប្រទេសឥណ្ឌា

-តាំងពី១៥០០ឆ្នាំមុនគ.ស. នាំចូលដោយពួកអារ្យ៉ន

-ហើយបានហូរចូលក្នុងដែនដីសុវណ្ណភូមិចំនួនពីរលើកមកធំៗ គឺនៅដើមស.វ.ទី១ តាមរយៈព្រះបាទហ៊ុនទៀន និងនាងលីវយី ចំណែកលើកទី២នៅដើមស.វ.ទី៥ ។

២. គេបែងចែកសាសនាព្រាហ្មណ៍ជាបីដំណាក់កាលធំៗ គឺ :

**-សម័យវេទនិយម** : ១៥០០-៥៥០ឆ្នាំមុនគ.ស

**-សម័យព្រាហ្មណ៍និយម** : ៥៥០មុនគ.ស. ដល់ ស.វ.ទី១០ នៃ គ.ស.

**-សម័យហិណ្ឌូនិយម** : ស.វ.ទី១០ នៃគ.ស. រហូតដល់សព្វថ្ងៃ

៣. គម្ពីរវេទចែកចេញជាបី ហៅថាត្រៃវេទ ហើយគម្ពីរនីមួយៗ ខុសគ្នាដូចទៅ :

**-គម្ពីរឫគវេទ** : ជាគម្ពីរដែលនិយាយសរសើរ បួងសួង អង្វរករទេវតាផ្សេងៗ និងអាទិទេពដែលស្ថិតនៅក្នុងធម្មជាតិ យើងនេះ ដូចជាព្រះអាទិត្យ ព្រះចន្ទ ព្រះពាយ ព្រះធរណី ព្រះអគ្គី ព្រះភិរុណ ។

-គម្ពីរយជុរវេទ : គឺជាគម្ពីរនិយាយពីការបន់ស្រន់អង្វរ ករទេវតានៅឋានលើចុះមកជួយ ដើម្បីមានឫទ្ធីតេជៈបារមី

ផ្នែកខ្លះទៀតនិយាយដូចគម្ពីរឫគវេទដែរ ។

**-គម្ពីរសាមវេទ :** ជាគម្ពីរដែលមានលក្ខណៈជាពាក្យកាព្យ សម្រាប់សូត្របន្ទន់ចិត្តទេវៈ អាទិទេព ស្តីអំពីពិធីបូជាយញ្ញ និង មន្តអាគមផ្សេងៗ ។

**-គម្ពីរអថវវេទ :** ជាគម្ពីរបន្ថែមពេលក្រោយ ដែលបង្រៀន អំពីមន្តអាគម ដើម្បីសម្រេចបំណង ដែលជាសេចក្តីត្រូវការ របស់អ្នកស្រុក ។

៤. ព្រះពុទ្ធសាសនាគេគោរពគម្ពីរព្រះត្រៃបិដក ។ គម្ពីរនេះមាន ៨៤០០០ព្រះធម្មក្ខន្ធ ហើយចែកជា :

-វិន័យបិដក ( ១៣ភាគ មាន ២១ ០០០ ព្រះធម្មក្ខន្ធ)

-សុត្តន្តបិដក ( ១៤ភាគ មាន ២១ ០០០ ព្រះធម្មក្ខន្ធ)

-អភិធម្មបិដក ( ៣៣ភាគ មាន ៤២ ០០០ ព្រះធម្មក្ខន្ធ)

៥. ភាពខុសគ្នានៃការគោរពគម្ពីរក្នុងព្រះពុទ្ធសាសនាមាន :

**-វិន័យបិដក :** ជាគម្ពីរស្តីពីច្បាប់ក្រឹត្យក្រម ដែលព្រះអង្គទ្រង់ បញ្ញត្តិអនុញ្ញាតទុកសម្រាប់ជាផ្លូវប្រតិបត្តិរបស់ព្រះភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ។

**-សុត្តន្តបិដក :** ជាគម្ពីរស្តីពីព្រះសូត្រ ដែលព្រះអង្គទ្រង់ត្រាស់ ទេសនាក្នុងសម័យផ្សេងៗ ។

**-អភិធម្មបិដក :** ជាគម្ពីរស្តីពីធម៌អាថ៌ជ្រាលជ្រៅជាល្អិតសុខុម បំផុតបានដល់ទស្សនវិជ្ជាព្រះពុទ្ធដែលមានអាថ៌គម្ពីរភាព ( ជ្រាល-ជ្រៅ) ជាអត្ថបទផុយពីសុត្តន្តបិដក ។

| ព្រះពុទ្ធសាសនា | ព្រាហ្មណ៍សាសនា |
|---|---|
| +គម្ពីរព្រះត្រៃបិដក មានបីៈ វិន័យបិដក សុត្តន្តបិដក និង អភិធម្មបិដក។<br>+ជឿលើកម្មផល លើទង្វើរបស់មនុស្ស ជឿលើការទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធ។ | +គម្ពីរវេទ (ហៅថាត្រៃវេទ) មានបីៈ ឫគវេទ យជុរវេទ សាមវេទ)<br>+ជឿលើអាទិទេពជាច្រើន ខុសៗគ្នា ក្រៅពីព្រះព្រហ្ម ព្រះសិវៈ ព្រះវិស្ណុ និងអាទិទេពវាយរងជាច្រើនទៀត។ |

៦. តម្លៃអប់រំតាមរយៈ ៖

**+ការគោរពសាសនាព្រាហ្មណ៍**

-ឱ្យមនុស្សជឿលើអាទិទេព ជឿលើព្រហ្មលិខិត ពោលគឺឱ្យជឿលើកម្លាំងក្រៅខ្លួន។ ភាវៈទាំងអស់គឺលោកលោកៈធម្មជាតិជាដើមសុទ្ធតែកើតឡើងដោយសារអាទិទេព។ មនុស្សគ្រប់រូបមានភ័ព្វសំណាង ឬគ្មាន គឺស្រេចតែ "ព្រហ្មលិខិត" ដែលអាទិទេព បានគូសដៅមុកមក។

-ឱ្យមានសេចក្ដីក្លាហាន

-ឱ្យគោរពពាក្យសច្ចៈ

-ឱ្យចេះតាំងអារម្មណ៍ឱ្យស្ងប់ បរិសុទ្ធ ដោយការធ្វើតបៈ និងយោគៈ។

**+ការគោរពសាសនាព្រះពុទ្ធ**

-ឱ្យប្រព្រឹត្តតែអំពើល្អគ្រប់បែបយ៉ាង (កុសលកម្មបថ១០)

ទាំងកាយ វាចា ចិត្ត ។

-ឱ្យវៀរចាកអំពើអាក្រក់សព្វបែបយ៉ាង ( អកុសលកម្មបថ១០) ទាំងកាយ វាចា ចិត្ត ។

-ឱ្យជឿលើកម្មផល ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់

-ឱ្យស្គាល់សេចក្តីពិត៤យ៉ាងហៅថាចតុរារិយសច្ចៈ ដើម្បីរំដោះខ្លួនស្វែងរកសេចក្តីសុខ ។

-ឱ្យមានព្រហ្មវិហារធម៌ និងកតញ្ញូកតវេទីតាធម៌ចំពោះគ្នាទៅវិញទៅមក

-ឱ្យចេះទីពឹងខ្លួនឯង ( អត្តាហិ អត្តនោ នាថោ) ។

៧. ឥទ្ធិពលសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធដែលមាននៅក្នុងមង្គលការ :

+ព្រាហ្មណ៍សាសនា

-ពិធីរើសពេលា

-ពិធីសែនព្រេន

-ពិធីសែនក្រុងពាលី

-ពិធីបង្វិលពពិល

-ពិធីសំពះផ្ទឹម

+ព្រះពុទ្ធសាសនា

-ពិធីសូត្រមន្ត



# រឿងសុវណ្ណសាម

សំណួរ

១. ចូរអ្នកធ្វើការបង្ហាញពីប្រភេទរបស់រឿងនេះ ដោយបញ្ជាក់ឧទាហរណ៍។

២. តើសុវណ្ណសាមត្រូវព្រះបាទបិលយក្ខបាញ់នៅពេលណា? ទីកន្លែងណា?

៣. ហេតុអ្វីបានជាព្រះបាទបិលយក្ខបាញ់សុវណ្ណសាម?

៤. តើរឿងនេះបានបង្ហាញពីលក្ខណៈតថៈយ៉ាងណាខ្លះ?

៥. តើសុវណ្ណសាមត្រូវបំពេញកាតព្វកិច្ចយ៉ាងណាខ្លះក្នុងការគោរពប្រណិប័តន៍ចំពោះអ្នកមានគុណ។

៦. តើការគោរពប្រណិប័តន៍ចំពោះអ្នកមានគុណអាចចាត់ទុកជាផ្នត់គំនិតជាតិខ្មែរបានដែរឬទេ?

៧. ចូរអ្នកបង្ហាញពីគុណសម្បត្តិនៃតួអង្គសុវណ្ណសាម និងតួអង្គព្រះបាទបិលយក្ខ។

៨. ចំពោះអ្នកវិញ អ្នកគប្បីត្រងត្រាប់តាមកិច្ចគោរពប្រណិប័តន៍ចំពោះអ្នកមានគុណដូចជាសុវណ្ណសាមដែរឬទេ?

ចម្លើយ

១. រឿងនេះជាប្រភេទអក្សរសិល្ប៍ពុទ្ធនិយម ព្រោះនិយាយពីការសន្សំបារមី (មេត្តាបារមី) របស់តួអង្គពោធិសត្វសុវណ្ណសាម

ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ ។

២. សុវណ្ណសាមត្រូវព្រះបាទបិលយក្ខបាញ់នៅពេលកណ្ដៀតក្អមទៅដងទឹក នៅក្នុងព្រៃហេមពាន្ត ជិតស្ទឹងមិគស ។

៣. បានជាព្រះបាទបិលយក្ខបាញ់សុវណ្ណសាម ព្រោះមានចិត្តច្រណែន ដោយឃើញម្រឹគទាំងឡាយនៅចោមរោមសុវណ្ណសាម ធ្វើឱ្យបិលយក្ខបាញ់សត្វម្រឹគមិនបាន ។

៤. រឿងនេះបានបង្ហាញពីលក្ខណៈតថៈត្រង់ៈ

- ឆ្លុះបញ្ចាំងពីការរស់នៅរបស់គ្រួសារមួយ ដែលមានឪពុកម្ដាយ និងកូន គឺម្ដាយឪពុករមែងមានព្រហ្មវិហារធម៌ចំពោះកូន ឯកូនត្រូវមានភារកិច្ចចិញ្ចឹមបីបាច់ថែរក្សាឪពុកម្ដាយ ជាពិសេសនៅពេលគាត់ចាស់ជរា ។
- បញ្ហាជំនឿបុណ្យ បាបក្នុងពុទ្ធសាសនា "ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់" ។

៥. ក្នុងការគោរពប្រណិប័តន៍ចំពោះអ្នកមានគុណ សុវណ្ណសាមត្រូវបំពេញកាតព្វកិច្ចជាច្រើនដូចជាបោសសំអាតអាស្រម ទៅបេះផ្លែឈើ ទៅដងទឹកសម្រាប់ផ្គត់ផ្គង់មាតាបិតា។ សុវណ្ណសាមបម្រើមាតាបិតាហុចទឹកខ្ពុរព្រះឱស្ឋនិងឈើស្ទន់ ហើយប្រគេនមធុរផលានុផល ។

៦. ការគោរពប្រណិប័តន៍ចំពោះអ្នកមានគុណអាចចាត់ទុកជា ផ្នត់គំនិតជាតិខ្មែរបាន ព្រោះខ្មែរមានប្រពៃណីនេះតាំងពីយូរយារណាស់មកហើយ ដូចមានពាក្យចាស់មួយឃ្លាថា "ម៉ែឪមាន

គុណ គុណមានទម្ងន់ ធ្ងន់ដូចប្រថពី គ្មានអ្វីនឹងសង គុណលោកទាំងទ្វី មាសប៉ុនគីរី ថ្លៃពុំស្មើហោង" ។

៧. **+គុណសម្បត្តិនៃតួអង្គសុវណ្ណសាម**

-ជាកូនកតញ្ញូចំពោះអ្នកមានគុណ ចេះបម្រើអ្នកមានគុណគ្រប់បែបយ៉ាងមិនឱ្យមាតាបិតាទាស់ចិត្តឡើយ ។

-ពេលទៅណាមកណាតែងមានសត្វម្រឹគហែហមជាបរិវារ ។

-មិនខឹងនឹងបិលយក្ខដែលបាញ់សម្លាប់ខ្លួន

**+គុណសម្បត្តិនៃតួអង្គព្រះបាទកបិលយក្ខ**

-ចេះស្តាយកំហុសរបស់ខ្លួនដែលបានបាញ់សុវណ្ណសាម

-មានទំនួលខុសត្រូវចំពោះកំហុសរបស់ខ្លួន សុខចិត្តទៅបម្រើមាតាបិតាជំនួសសុវណ្ណសាម ។

៨. ចំពោះខ្ញុំវិញ ខ្ញុំក៏គប្បីត្រងត្រាប់តាមកិច្ចគោរពប្រណិប័តន៍ចំពោះអ្នកមានគុណដូចជាសុវណ្ណសាមដែរព្រោះពួកគាត់ជាអ្នកមានគុណចំពោះកូនគ្រប់គ្នា ។

មេរៀនទី ៧

# អក្សរសាស្ត្រនិងអក្សរសិល្ប៍ខ្មែរ



## អក្សរសិល្ប៍ខ្មែរ

សំណួរ

១. ដូចម្ដេចដែលហៅថាអក្សរសិល្ប៍?

២. តើអ្វីជាវត្ថុបំណងរបស់អក្សរសិល្ប៍?

៣. តើមានទស្សនៈដូចម្ដេចខ្លះចំពោះសុខៈ? ហើយសុខៈនៅក្នុងអក្សរសិល្ប៍មានទំនាក់ទំនងយ៉ាងណាខ្លះចំពោះសង្គម? ចូររកឧទាហរណ៍មកបញ្ជាក់ ។

៤. តើអក្សរសិល្ប៍មានប៉ុន្មានប្រភេទ? អ្វីខ្លះ? ចូរបកស្រាយទស្សនៈនីមួយៗដោយលើកឧទាហរណ៍មកបញ្ជាក់ ។

៥. តើប្រភេទអក្សរសិល្ប៍ និងចលនាអក្សរសិល្ប៍មានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ? ចូររកអំណះអំណាងមកបញ្ជាក់ផង ។

៦. ហេតុដូចម្ដេចបានជាអ្នកនិពន្ធពោលថា "អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះមើលការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ តែវាជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់អប់រំ ផ្សព្វផ្សាយអរិយធម៌ វប្បធម៌ជាតិ"? ចូរពន្យល់ ។

៧. ចូរធ្វើការពណ៌នាអំពីលក្ខណៈអក្សរសិល្ប៍ដោយផ្សារភ្ជាប់ជាមួយ

ឧទាហរណ៍ផង ។
៨. ក្រោយពីអ្នកបានសិក្សាអំណាននេះហើយ តើអ្នកមានគំនិតយ៉ាងណាខ្លះក្នុងការរួមចំណែកថែរក្សា និងការពារវប្បធម៌ជាតិរបស់អ្នកឱ្យស័ក្តិសមជាទំពាំងស្នងឫស្សី?
៩. តាមការសិក្សាអក្សរសិល្ប៍ គឺការសិក្សាពីមនុស្ស និងដើម្បីមនុស្ស។ ចូរពន្យល់ ។

ចម្លើយ

១. ដែលហៅថាអក្សរសិល្ប៍គឺជាប្រភេទរឿងដែលតុបតែងឡើងប្រកបដោយសិល្ប៍ ពោលគឺបំណិនប្រសប់ក្នុងការតែងរបស់អ្នកនិពន្ធដែលឱ្យអ្នកអាន ឬអ្នកស្តាប់ចូលចិត្តចាប់អារម្មណ៍ រំភើបញាប់ញ័រទៅតាមបញ្ហារបស់រឿង ។
២. វត្ថុបំណងរបស់អក្សរសិល្ប៍គឺស្វែងរកសោភ័ណ សច្ចៈ និងសុខៈ ។
៣. ចំពោះ "សុខៈ" មានទស្សនៈប្លែកៗគ្នាដូចជា៖

-មតិទី១ យល់ថា ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវគោរពបន់ស្រន់អាទិទេព ធ្វើសមាធិបំពេញមោក្សៈ (ការរំដោះ) ដើម្បីផ្តាច់អាត្មនចេញពីវដ្តសង្សារ ឱ្យវិលទៅជួបព្រហ្មន ។

-មតិទី២ បានបញ្ជាក់ថា ដើម្បីសម្រេចសុខៈបាន មនុស្សត្រូវប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើនដោយគ្រប់វិធី ទោះបីសង្គមជាតិត្រូវធ្លាក់ដល់ណាក៏ដោយ ។

-មតិទី៣ បង្ហាញថា សុខៈពុំស្ថិតនៅលើការបន់ស្រន់ គោរពអាទិទេព ឬការប្រមូលទ្រព្យសម្បត្តិឱ្យបានច្រើននោះទេ គឺ

សុខៈសំដៅលើការអភិវឌ្ឍនៃសង្គមនោះឯង។

**ទំនាក់ទំនងនៃសុខៈនៅក្នុងអក្សរសិល្ប៍ និងសង្គម**

យើងដឹងថាអក្សរសិល្ប៍មានគោលបំណងស្វែងរកសេចក្តីសុខជូនប្រជាជន នោះមានន័យថាអក្សរសិល្ប៍បានធ្វើឱ្យប្រជាជនរស់នៅដោយភាពសប្បាយរីករាយ ធូរស្បើយខាងផ្លូវអារម្មណ៍។ លើសពីនេះអក្សរសិល្ប៍ក៏បានផ្តល់នូវពុទ្ធិ និងការអប់រំជាច្រើនដើម្បីទុកជាបទពិសោធក្នុងជីវភាពរស់នៅរបស់មនុស្ស។ អក្សរសិល្ប៍តែងលើកយកបញ្ហាមនុស្សមកចោទនិងដោះស្រាយ។

សុខៈនៅក្នុងអក្សរសិល្ប៍មានទំនាក់ទំនងនឹងសង្គមស្ទើរគ្រប់វិស័យដូចជា ប្រវត្តិសាស្ត្រ សាសនា សិល្បៈ បច្ចេកទេស សីលធម៌ នយោបាយ សង្គ្រាម ច្បាប់ជាដើម។

ឧទាហរណ៍

- រឿងព្រះវេស្សន្តរ និយាយពីការធ្វើទានដើម្បីបំពេញបារមីស្វែងរកសុខៈតាមផ្លូវពុទ្ធសាសនា។
- រឿងកុលាបប៉ៃលិន និយាយពីការតស៊ូក្នុងជីវិតដើម្បីស្វែងរកសុខៈសម្រាប់ខ្លួន។

៤. អក្សរសិល្ប៍មាន៥ប្រភេទ គឺ ៖

-សទ្ទស្សន៍អក្សរសិល្ប៍ : គឺជាប្រភេទនៃពពួកអត្ថបទអ.សិ. ដែលមានមុខងារ គោលបំណងក្នុងការលើកយកបញ្ហា ឬវត្ថុណាមួយមកអធិប្បាយរៀបរាប់ឡើងវិញ។ សទ្ទស្សន៍អ.សិ.មាន ៖

-ពណ៌នាកថា

-វណ្ណនាកថា

-បដិពិម្ពកថា

-និទានកថា

-វុត្តន្តកថា

-សារកថា

-ប្រលោមអក្សរសិល្ប៍ : ស្នាដៃដែលតែងអំពីវិបត្តិទំនាស់របស់មនុស្សដោយប្រើវិធីប្រលោមធ្វើឱ្យអណ្តែតអណ្តូងអារម្មណ៍ ភ័យ ស្លុត ញាប់ញ័រ រំភើបខុសធម្មតា។ ប្រលោមអក្សរសិល្ប៍មាន :

ក-ព្រេងកថា

ខ-ប្រឌិតកថា

គ-វីរកថា

ឃ-នរកថា

ង-ប្រលោមកថា

-នាដកអក្សរសិល្ប៍ : ស្នាដៃដែលតែងឡើងមានឆាកឈុតសម្រាប់យកទៅសម្តែងសិល្បនាដកម្មមានល្ខោនជាដើម។ នាដក អ.សិ. មាន :

ក-នាដ្យកថា

ខ-ហាសមានកថា(ហាសកថា)

គ-ទារុណកថា

-ឧបទេសអក្សរសិល្ប៍ ៖ ស្នាដៃបែបច្បាប់ទូន្មានសម្រាប់អប់រំប្រដៅណែនាំ។ ឧបទេសមាន ៖

ក-សុភាសិតកថា

ខ-ទូន្មានកថា

គ-ល្បើកកថា

ឃ-ឧបាស្កកថា

ង-សុន្ទរកថា

-ទិដ្ឋិអក្សរសិល្ប៍ ៖ ស្នាដៃបែបអត្ថាធិប្បាយ ឬការបញ្ចេញទស្សនៈ និងមតិផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ អ្នកសិក្សារិះគន់អក្សរសិល្ប៍ខ្មែរ ។ ទិដ្ឋិអ.សិ.មានដូចជា ៖

ក-អត្ថាធិប្បាយកថា

ខ-ឧស្សាហកថា

គ-វិវេចនាកថា

ឃ-សិក្សាកថា

ង-អក្សរសិល្ប៍កថា

៩. ប្រភេទអក្សរសិល្ប៍ និងចលនាអក្សរសិល្ប៍មានលក្ខណៈខុសគ្នាត្រង់៖

- **ប្រភេទអក្សរសិល្ប៍** គឺជាការបែងចែកស្នាដៃអក្សរសិល្ប៍ទៅតាមរចនាបថ។ អក្សរសិល្ប៍មាន៥ប្រភេទគឺ សន្ទស្សន៍អក្សរសិល្ប៍ ប្រលោមអក្សរសិល្ប៍ នាដកអក្សរសិល្ប៍ ឧបទេសអក្សរ-

សិល្ប៍ និងទិដ្ឋិអក្សរសិល្ប៍ ។

-ចំណែកចលនាអក្សរសិល្ប៍វិញ សំដៅយកដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមថ្នាក់លើ ទ្រឹស្តី ទស្សនៈ គោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិ-សាស្ត្រ។ គេចែកចលនាអក្សរសិល្ប៍ជា៤គឺ អក្សរសិល្ប៍ព្រាហ្មណ៍និយម អក្សរសិល្ប៍ពុទ្ធនិយម អក្សរសិល្ប៍ខេមរនិយម និងអក្សរសិល្ប៍បរទេសនិយម ។

ឧទាហរណ៍រឿងកុលាបប៉ៃលិន តាមអត្ថរូបនៃការតាក់តែងរឿង គេចាត់ទុករឿងនេះជាប្រភេទអក្សរសិល្ប៍ទំនើប បែបប្រលោមលោក ។ ប៉ុន្តែវាស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ខេមរ-និយម ព្រោះអត្ថន័យនៃរឿងឆ្លុះបញ្ចាំងពីជីវភាពរស់នៅរបស់ប្រជាជនខ្មែរ ។

៦. បានជាអ្នកនិពន្ធពោលថា "អក្សរសិល្ប៍មិនគ្រាន់តែជាកញ្ចក់សម្រាប់ឆ្លុះមើលការរស់នៅរបស់សង្គមមនុស្សក្នុងសម័យកាលនីមួយៗប៉ុណ្ណោះទេ តែវាជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់អប់រំផ្សព្វផ្សាយអរិយធម៌ វប្បធម៌ជាតិ" ព្រោះអក្សរសិល្ប៍វាជាផ្នែកធាងមួយនៃសិល្បៈ ដែលបានលើកយកបញ្ហាវប្បធម៌ អរិយធម៌ ពោលគឺបញ្ហាទំនៀមទម្លាប់ ប្រពៃណី ការអប់រំ របៀបរបបរស់នៅ ការដឹកនាំ... របស់មនុស្សក្នុងសង្គមមួយមកបង្ហាញដល់អ្នកអាន អ្នកស្តាប់ អ្នកទស្សនា សម្រាប់ទុកជាបទពិសោធដល់មនុស្សទូទៅ ។

៧. លក្ខណៈអក្សរសិល្ប៍មាន៨យ៉ាង គឺ ៖

+លក្ខណៈមនុស្ស : បានដល់ស្នាដៃអ.សិ.ទាំងឡាយណាដែលលើកយកបញ្ហាមនុស្សមកចោទ និងដោះស្រាយតាមសភាពធម្មតារបស់មនុស្សហើយបង្កើតបញ្ហាមួយហៅថាបញ្ហាមនុស្ស។ ទោះបីអ្នកនិពន្ធលើកយកតួអង្គអច្ឆរិយក្ដី សត្វក្ដី ក៏តួអង្គទាំងនោះតំណាងឱ្យមនុស្សក្នុងប្រភេទណាមួយជាដរាប។

ឧ-ទន្សាយតំណាងឱ្យចៅក្រមសុចរិតយុត្តិធម៌។

ក្រពើតំណាងឱ្យមនុស្សរមិលគុណ។

+លក្ខណៈប្រវត្តិ : បានដល់ស្នាដៃអ.សិ.ទាំងឡាយដែលជាប់ទាក់ទងទៅនឹងព្រឹត្តិការណ៍ខ្លះជាប្រវត្តិសាស្ត្រ។ អ.សិ.មានលក្ខណៈប្រវត្តិដូចជារឿងក្រឡាហោមគង់ ទុំទាវ ភូមិតិរច្ឆាន..........។

+លក្ខណៈជាតិ : បានដល់ស្នាដៃអ.សិ.ទាំងឡាយដែលទ្រទ្រង់វប្បធម៌ សង្គមធម៌ជាតិទាំងមូល។ អ.សិ.ប្រភេទនេះមានតម្លៃពិសេសរបស់ជាតិមួយដែលខុសស្រលះពីជាតិដទៃតាំងពីជំនឿទំនៀមទម្លាប់ ប្រពៃណី សាសនា អាកប្បកិរិយាជាដើម។ អ.សិ. មានលក្ខណៈជាតិដូចជារឿងរាមកេរ្តិ៍ ទុំទាវ ភូមិតិរច្ឆាន....។

+លក្ខណៈអន្តរជាតិ : ជាស្នាដៃដែលមានលក្ខណៈជាតិរួចស្រេចទៅហើយ នៅពេលដែលសង្គមជាតិបានទទួលស្គាល់ថាជាឧត្តមបទមានតម្លៃទ្រទ្រង់វប្បធម៌ អរិយធម៌របស់ជាតិ។ បន្ទាប់មកបរទេសយកទៅសិក្សាផ្សព្វផ្សាយនៅក្នុងសង្គមជាតិរបស់គេ

គឺនៅពេលនោះ ហើយដែលអក្សរសិល្ប៍មានលក្ខណៈសកល គឺលក្ខណៈអន្តរជាតិ។ ឧ. រឿងកិត្តិយស ឬស្នេហា រឿងជនកំណាញ់...

+លក្ខណៈសង្គម : អ.សិ.មានលក្ខណៈសង្គមបានដល់អ.សិ. លើកយកបញ្ហាសង្គមមនុស្ស ទោះសង្គមនោះចម្រើនក្តី ធម្មតាក្តី អន់ថយក្តី មកលាតត្រដាង។

+លក្ខណៈវណ្ណៈ ជាក្រិត្យក្រម "សង្គមបែបណាអ.សិ.បែបនោះ"។ នៅគ្រប់សម័យកាលសង្គម ស្នាដៃអ.សិ.ណាមួយក៏ដោយសុទ្ធតែតំណាងឱ្យតម្រូវការផលប្រយោជន៍របស់វណ្ណៈមួយជានិច្ច។

+លក្ខណៈប្រជាជន : អ.សិ.មានលក្ខណៈប្រជាជនទាល់តែ អ.សិ.នោះ

-ទាក់ទងទៅនឹងជីវភាពប្រជាជន

-តួអង្គជាប្រជាជន កសិករ កម្មករ ទាំងលក្ខណៈ សកម្មភាព ទាំងអាកប្បកិរិយា

-ពាក្យសម្តីនៅក្នុងអត្ថបទសាមញ្ញងាយស្តាប់ ងាយយល់

+លក្ខណៈជឿនលឿនៈ លក្ខណៈសំខាន់នៃអ.សិ.ជឿនលឿនគឺៈ

-បម្រើ គាំទ្រ ផ្សព្វផ្សាយមាគ៌ារបស់រដ្ឋ

-ប្រឆាំងជំនឿមិនសមហេតុផល

-បណ្តុះចំណេះដឹងពីបញ្ហាជីវភាព បញ្ហាធម្មជាតិរបស់ប្រជាជន

-អប់រំប្រជាជនឱ្យពឹងផ្អែកលើកម្លាំងខ្លួនឯង និងឱ្យមានទឹកចិត្តស្នេហាជាតិមាតុភូមិ ។

៨. (ចម្លើយលើសិស្ស)

៩. តាមការសិក្សាអក្សរសិល្ប៍ គឺ "ការសិក្សាពីមនុស្ស និងដើម្បីមនុស្ស" មានន័យថា កម្មវត្ថុនៃអក្សរសិល្ប៍គឺមនុស្ស ព្រោះអក្សរសិល្ប៍លើកយកបញ្ហាមនុស្ស និងសង្គមមនុស្សមកចោទ និងដោះស្រាយតាមសិល្បវិធីរបស់អ្នកនិពន្ធ ។អក្សរសិល្ប៍បានលាតត្រដាងពីជីវភាពរបស់មនុស្សនៅគ្រប់សម័យកាល ដើម្បីទុកជាបទពិសោធដល់មនុស្សទូទៅក្នុងការកែប្រែជីវិតរស់នៅឱ្យកាន់តែប្រសើរឡើង ។ ម្យ៉ាងទៀត អក្សរសិល្ប៍ជួយធ្វើឱ្យមនុស្សចេះគិតពិចារណាទៅលើបញ្ហាដែលកើតមានឡើងនៅគ្រប់សម័យកាល និងជួយឱ្យមនុស្សមានភាពរំភើប សប្បាយរីករាយ អាចបំបាត់ទុក្ខកង្វល់បាន ។



# សិលាចារឹកបណ្ឌិតជ័យនន្ទ

សំណួរ

១. តើអត្ថបទសិលាចារឹកនេះជាស្នាដៃរបស់អ្នកនិពន្ធណា?

២. តើអត្ថបទនេះនិយាយអំពីអ្វី?

៣. តើបណ្ឌិតជ័យនន្ទ :

-មានគោលបំណងអ្វីខ្លះទៅអនាគត?

-ចូរលើកអំណះអំណាងមកបញ្ជាក់អំពីគោលបំណងនីមួយៗ ។

-ចូរអ្នកវិភាគចរិតលក្ខណៈរបស់តួអង្គក្នុងកំណាព្យខាងលើនេះ ។

៤. តើអត្ថបទនេះតាក់តែងនៅពេលណា?

៥. ចូរធ្វើការសិក្សាសង្គមបរិយាកាសតាមរយៈអត្ថបទនេះ ។

៦. តើអត្ថបទនេះមានខ្លឹមសារដូចម្ដេច?

៧. តើអត្ថបទនេះផ្ដល់បទពិសោធដូចម្ដេចខ្លះដល់អ្នក?

៨. ចូរអ្នកបង្ហាញពីវប្បធម៌ជាតិដែលឆ្លុះបញ្ចាំងតាមរយៈសិលាចារឹកខាងលើនេះ ។

៩. ដោយអ្នកធ្លាប់បានស្គាល់សិលាចារឹកខ្មែររួចមកហើយ ចូរអ្នក :

-ប្រាប់ឈ្មោះសិលាចារឹកឱ្យបានចំនួនប្រាំ ។

-បញ្ជាក់ខ្លឹមសារចម្បងនៃសិលាចារឹកនីមួយៗនោះផង ។

-ប្រាប់ពីការបរិច្ឆេទនៃការនិពន្ធសិលាចារឹកនោះ ។

១០. ចូរអ្នកជ្រើសរើសអត្ថបទណាមួយដែលបញ្ជាក់ថាតួអង្គណាមួយ

បានទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា ។

ចម្លើយ

១. អត្ថបទសិលាចារឹកនេះជាស្នាដៃនិពន្ធរបស់បណ្ឌិតជ័យនន្ទ ។

២. អត្ថបទនេះនិយាយអំពីៈ

- ការពណ៌នាពីការលាចាកអំពើបាប លាទុក្ខសោក ភាពឆ្គាំឆ្គង ភាពល្ងង់ខ្លៅ រោគា ភាពក្រខ្សត់...
- ពាក្យស្តុតី (ពាក្យសរសើរ) ការបួងសួង ប្រាថ្នាសុំនូវសេចក្តីសុខចម្រើន សម្រេចមគ្គផលក្នុងការធ្វើកុសលផ្សេងៗ ។

៣. នៅពេលអនាគត បណ្ឌិតជ័យនន្ទមានគោលបំណង :

-ចង់ត្រាស់ជាព្រះសម្មាសម្ពុទ្ធ (...សូមបានត្រាស់ស្រេច...)

-ចង់មានសទ្ធាជ្រះថ្លាដូចព្រះជធរ (ខ្ញុំសូមប្រាថ្នា គ្រោកអរសទ្ធា ...ដូចព្រះជធរ...)

-ចង់មានប្រាជ្ញាដូចព្រះនាគសេន (...ចេះឆ្លើយប្រស្នា....ដូចព្រះនាគសេន....)

-ចង់ឱ្យទេវតាជួយថែរក្សា (...ទេវតាជួយយល់....)

-ចង់ឱ្យមានអំណាចដូចព្រះនារាយណ៍ (...ខ្ញុំសូមមានម្ចាស....)

-ចង់មានទ្រព្យបរិបូរណ៍ (...ខ្ញុំសូមទ្រព្យធន...)

-ចង់មានបរិពារហែហម (...ខ្ញុំសូមបរិពារ...)

**+ចរិតលក្ខណៈរបស់បណ្ឌិតជ័យនន្ទ**

-ស្រឡាញ់ការសិក្សា : ខ្ញុំលាត្រង់ឥតប្រាជ្ញា...

-ស្រឡាញ់អំណាច : ខ្ញុំសូមមានម្នាច...

-ស្រឡាញ់ទ្រព្យ : ខ្ញុំសូមទ្រព្យធន...

-ស្អប់ការព្រាត់ប្រាស : ខ្ញុំសូមលាពិសភោគា ព្រាត់ប្រាសភរិយា...

-ស្អប់កំណើតអន់ថយ : ខ្ញុំលាត្រង់កំណើតថោក...

-ស្អប់អំពើពាល : ខ្ញុំលាត្រង់ចិត្តសាហាវ...

៤. អត្ថបទនេះតាក់តែងនៅគ.ស.១៧០១។

៥. សង្គមបរិយាកាសតាមរយៈអត្ថបទនេះគឺសង្គមខ្មែរសម័យនោះប្រកាន់យករបបរាជានិយម ដែលព្រះរាជាជាមនុស្សដែលប្រសើរលើសគេ។ សង្គមមានការបែងចែកវណ្ណៈ គឺស្តេច មន្ត្រី សេដ្ឋីរាស្ត្រ។ រាស្ត្រមានជីវភាពខ្សត់ខ្សោយ ឯស្តេច មន្ត្រី សេដ្ឋី ជាត្រកូលមានជីវភាពធូរធារ។ ប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនាហើយមានជំនឿយ៉ាងខ្លាំងទៅលើបញ្ហាកម្មផល។ ខាងផ្នែកសង្គមកិច្ចប្រទេសខ្មែរពុំទាន់មានឱសថ អាចព្យាបាលជំងឺ ពិស ស្រែងឃ្លង់ទេ។

៦. អត្ថបទនេះមានខ្លឹមសារដូចតទៅ :

-ការប្តេជ្ញាចិត្តរបស់បណ្ឌិតជ័យនន្ទ ចំពោះមុខវត្ថុសក្តិសិទ្ធិអំពីការវៀរចាកអំពើអាក្រក់ផងទាំងពួង៖ លាលោភ ទោស ភ័យ-ន្តរាយ ព្រាត់ប្រាស ទុក្ខសោក កំណើតថោក ពៀរស្ពាន ក្តីអាស្រូវល្ងង់ខ្លៅ មោហា ឥតប្រាជ្ញា ពុំចេះភាសា ខ្សត់ ចិត្តប្រត្យក្ស ឆ្គួតពាក្យឆ្គង ....(សូមមើលក្នុងអត្ថបទបន្ថែម)។

-សេចក្តីប្រាថ្នារបស់បណ្ឌិតជ័យនន្ទទៅអនាគតៈ សូមចិត្តសទ្ធា អំណោយទាន ត្រាស់ជាសារពេជ្ញតាញ្ញាណ និព្វាន ឱ្យទានសាច់ បញ្ចឥន្ទ្រិយ ទេវតាជួយយល់ មានម្ចាស ឫទ្ធិអំណាច អានុភាព សិល្ប៍ជប់..... (សូមមើលក្នុងអត្ថបទបន្ថែម) ។

៧. អត្ថបទនេះផ្តល់បទពិសោធដូចតទៅៈ

-ចៀសវាងអកុសល ដូចកវីបានស្នាលា

-កសាងខ្លួនជាមនុស្សមានចំណេះដឹងនិងឧត្តមគតិ

-ខិតខំតស៊ូដើម្បីសម្រេចបំណងប្រាថ្នាក្នុងជាតិនេះ ទោះជាកើតក្នុងត្រកូលណាក៏ដោយ ។

-គោរព និងអនុវត្តតាមទ្រឹស្តីនៃព្រះពុទ្ធសាសនា ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្ន និងអនាគត ។

-ចេះកត់ត្រាទុកនូវរាល់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ...

៨. វប្បធម៌ជាតិដែលឆ្លុះបញ្ចាំងតាមរយៈសិលាចារឹកខាងលើនេះគឺៈ

-ការគោរពប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា

-ការជឿលើវត្ថុសក្តិសិទ្ធិ

-មានការសិក្សាអប់រំ

-មានសិលាចារឹកជាច្រើន

-មានអ្នកប្រាជ្ញអក្សរសាស្ត្រ

-មានតួអក្សរសម្រាប់កត់ត្រាភាសារបស់ខ្លួន

-មានការរីកចម្រើនខាងវិស័យអក្សរសាស្ត្រ អក្សរសិល្ប៍ កំណាព្យ...

៩. រាប់ឈ្មោះសិលាចារឹកខ្មែរឱ្យបាន៥៖

-សិលាចារឹកនៅសម្បូណិព្រៃគុហ៍ (ក្នុងដែនឥសានបុរៈ) ខេត្តកំពង់ធំសរសេរក្នុងព.ស. ១១៦៩ (គ.ស.៦២៦) ក្នុងរជ្ជ-កាលព្រះបាទឥសានវរ្ម័នទី១។

អត្ថន័យនៃសិលាចារឹកនេះបង្ហាញថា ក្នុងសម័យសតវត្សរ៍ទី៧នៃគ.ស ជំនឿខេមរជន គឺមានចំពោះព្រះសិវៈ (ឥសូរ ព្រះវិស្ណុ ព្រះព្រហ្មជាដើម)។ ឯព្រះពុទ្ធសាសនាក្នុងសម័យនោះក៏មានឥទ្ធិពលខ្លាំងណាស់ដែរ។ គេគោរពនាគរាជមុច្ចលិន្ទ ដែលគ្របដណ្តប់ជាម្លប់ចំពោះព្រះពុទ្ធ។ គេនិយាយពីព្រាហ្មណ៍រាជបុរោហិតឈ្មោះបសុបតិ (ភាសុផាតិ) មានងារជាវិទ្យាវិសេសៈ ជាអ្នកប្រាជ្ញចេះដឹងវិជ្ជាជ្រៅជ្រះ ចេះអធ្វ័ន គឺវិជ្ជាសាស្ត្រខាងក្បួនវេយ្យាករណ៍ ចេះវិជ្ជាខាងវៃសេសិកៈន្យាយៈ សមីក្ស ឬសំខ្យាក្នុងព្រហ្មញ្ញទ្រឹស្តី ព្រមទាំងវិជ្ជាក្នុងពុទ្ធសាសនាថែមទៀត។

ក្រៅពីការបញ្ជាក់នូវជំនឿ សិលាចារឹកបានរំលឹកអំពីរូបសម្ផស្សសោភណភាពខាងរាងកាយរបស់ព្រះរាជា ព្រមទាំងតេជៈបារមី និងព្រះជំនឿរបស់ព្រះបាទភវវរ្ម័ន ឥសានវរ្ម័ន មហេន្ទ្រវរ្ម័ន ដែលបានឱ្យកសាងរាជនិវេសស្ថាន សក្ការស្ថាន មានរូបសំណាកទេវៈ ពុទ្ធរូបសម្រាប់គោរពបូជាជាដើម។

ក្នុងសម័យនោះមនុស្សមានចំណេះដឹងខាងវិជ្ជាផ្លូវលោក និងផ្លូវធម៌ច្បាស់លាស់ណាស់។ ការរស់នៅប្រកបដោយរបៀបរបប មានសម្ភារៈប្រើប្រាស់បរិបូណ៌ ដោយសារមានឃើញការរៀបរាប់អំពី

តង្វាយផ្សេងៗរបស់ព្រះមហាក្សត្រចំពោះទេវរូប ឬពុទ្ធរូប មានទាំងសត្វពាហនៈផងដូចជាគោ ក្របី ជាដើម ។

-សិលាចារឹកនៅភូមិខាវរាំង ជិតអរញ្ញប្រទេស ដីខ្មែរពីដើម (ប្រទេសសៀមឥឡូវ) ក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី២ ព.ស. ១១៨២ (គ.ស.៦៣៩) ។ សិលាចារឹកនេះនិយាយពីឧបាសកម្នាក់ងារជាសិនាហ្វ បានសាងព្រះវិហារមួយឧទ្ទិសថ្វាយព្រះពុទ្ធសាសនា ព្រមទាំងថ្វាយទ្រព្យសម្រាប់ព្រះវិហារ មានទាសាក្មេងចាស់ចំនួន៣២ នាក់ រាប់ទាំងឆ្នាំចំការដូងស្លាផង ។ តាមរយៈសិលាចារឹកនេះដែរ យើងដឹងនូវអរិយធម៌ខ្មែរ ព្រមទាំងនយោបាយកសិកម្មក្នុងសម័យសតវត្សរ៍ទី៧ នៃគ្រិស្តសករាជ ។

-សិលាចារឹកនៅវត្តព្រៃវៀរ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង (ពីដើមហៅថាខេត្តបាភ្នំ) ក្នុងព.ស.១២០៦ (គ.ស.៦៦៤) ក្នុងរជ្ជកាលជ័យវរ្ម័នទី១(គ.ស.៦៥៥-៦៨១) ។ អត្ថន័យនៃសិលាចារឹកនេះបង្ហាញថានៅក្នុងគ្រិស្តសតវត្សរ៍ទី៧ មានភិក្ខុពីរអង្គជាបងប្អូនបង្កើត ជាជាតិក្សត្រដែលបានសាងបព្វជា ហើយទ្រង់គង់នៅក្នុងវត្តព្រៃវៀរនេះ ។ រីឯពុទ្ធសាសនាសម័យនោះរីកចម្រើន មានភិក្ខុសង្ឃកាន់ក្រិត្យវិន័យ មានសមត្ថភាពបរិបូណ៌ ។ ទាំងបុត្រព្រះមហាក្សត្រក៏ចូលបួសក្នុងសាសនា ហើយព្រះរាជាមានព្រះសទ្ធាណាស់ក្នុងកិច្ចទំនុកបម្រុងវត្តអារាមសមណព្រាហ្មណ៍ ។ ភោគផលខាងសម្បត្តិទ្រព្យនគរក៏បរិបូណ៌ឥតខ្ចោះ មានតាំងពីគ្រឿងប្រើប្រាស់ផលដំណាំដាំដុះ និងសត្វពាហនៈផង ។

-សិលាចារឹកនៅវត្តប្រាសាទ ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ លោក Aymonier បញ្ជាក់ថាសិលាចារឹកនេះសរសេរក្នុងគ្រិស្តសតវត្សរ៍ទី៦ ឬទី៧ ហើយសរសេរជាភាសាខ្មែរ ក្នុងរជ្ជកាលជ័យវរ្ម័នទី១(គ.ស.៦៥៥-៦៨១)។

សិលាចារឹកនេះបង្ហាញនូវជំនឿរបស់ព្រះមហាក្សត្រចំពោះព្រហ្មញ្ញសាសនាម្យ៉ាង ហើយម្យ៉ាងទៀតនូវចំណេះវិជ្ជាខាងហោរាសាស្ត្រ តារាសាស្ត្រដ៏ជំនាញរបស់រាជបណ្ឌិតរបស់ព្រះរាជាសម័យកាលសតវត្សរ៍ទី៧នោះ។

-សិលាចារឹកនៅប្រាសាទតាកៀម ឬតាតាំ ក្នុងខេត្តសៀមរាប ព.ស.១៣៣៤(គ.ស.៧៩១)។

សិលាចារឹកនេះនិយាយពីការកសាងរូបពោធិសត្វអវលោកេស្វរៈទុកដើម្បីគោរពបូជា (តាមបែបពុទ្ធសាសនាមហាយាន) ព្រមទាំងអំពីតង្វាយ និងជំនឿតាមពុទ្ធនិយម)។

១០. អត្ថបទដែលបញ្ជាក់ថាតួអង្គដែលបានទទួលឥទ្ធិពលពីព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា គឺព្រះវេស្សន្តរ ដែលមានខ្លឹមសារបញ្ជាក់នៅត្រង់៖

- ទទួលឥទ្ធិពលពីព្រះពុទ្ធសាសនា គឺដំណើររឿងទាក់ទងនឹងការបំពេញទានបារមី ជាទស្សនៈរបស់ពុទ្ធសាសនា
- ទទួលឥទ្ធិពលពីព្រហ្មញ្ញសាសនា គឺពេលតួអង្គព្រះវេស្សន្តរទ្រាំមិនបាននឹងជូជកធ្វើបាបជាលី ក្រិស្នា ក៏លើកធ្នូបម្រុងបាញ់ជូជក ទង្វើនេះជាដំណោះស្រាយបញ្ហាបែបសាសនា

ព្រាហ្មណ៍ ។

## សូរព្យញ្ជនៈ

*១- ព្យញ្ជនៈ គឺជាសូរសំឡេងដែលកើតមកពីដំណើរខ្យល់តាមបំពង់សំឡេង បន្លឺឡើងដោយមានទំនប់ប្រកបដោយភាពពុំច្បាស់លាស់ ។ ព្យញ្ជនៈអាចចែកតាមលក្ខណៈបន្លឺ តាមលក្ខណៈខ្យល់ និងតាមលក្ខណៈធ្នូ ។*

ចម្លើយលំហាត់

ក. ស្រង់ពាក្យខាងក្រោមទៅដាក់ឱ្យត្រូវតាមខ្ទង់ព្យញ្ជនៈខ្យល់ស្ទុះមានខ្យល់ និងស្ទុះគ្មានខ្យល់ ។

"អ៊ូអែ ភ្លឺភ្លើ កោងកាច ខកខាន អាំង ឃោរឃៅ ពព្រិច ឆ្កាង ប៉ប្រះ ចូល ឈ្មាន់ បាយ ជាង ឋិត ប៊ិច ណោមរា ទទឹក ថាំង តឹង ធ្នូ ដឹង ឧប ភ្នាល់ តុបតែង ចចេស ទំ ផង ឆាឆៅ ។"

| ព្យញ្ជនៈខ្យល់ស្ទុះមានខ្យល់ | ព្យញ្ជនៈខ្យល់ស្ទុះគ្មានខ្យល់ |
|---|---|
| ខកខាន ឃោរឃៅ ឆាឆៅ ថាំង ឈ្មាន់ ឆ្កាង ផង ភ្នាល់ ធ្នូ ឋិត ភ្លឺភ្លើ ណោមរា | កោងកាច ដឹង ជាង ទទឹក តឹង ចចេស ចូល តុបតែង ប៊ិច បាយ ឧប ពព្រិច ប៉ប្រះ អ៊ូអែ អាំង |

ខ. រកពាក្យដែលត្រូវនឹងព្យញ្ជនៈខ្យល់ច្រមុះខាងក្រោម ក្នុងមួយតួឱ្យបានយ៉ាងតិចពីរពាក្យ ។

| ព្យញ្ជនៈខ្យល់ច្រមុះ | ពាក្យ | ពាក្យ |
|---|---|---|
| ង៉ | ង៉េមង៉ាម | ង៉ា |
| ង | ងឿង | ងោក |
| ញ | ញញួរ | ញញឹម |
| ញ៉ | ញ៉ែងញ៉ង | ញ៉ែ |
| ន៊ | សេនា | វាសនា |
| ណ | ណា | ណោងណោង |
| ម៉ | ម៉ែ | ម៉ោង |
| ម | មាន | មុន |

គ. រកពាក្យដែលត្រូវនឹងព្យញ្ជនៈខ្យល់បង្ហូរត្រដុសខាងក្រោម ក្នុងមួយតួឱ្យបានយ៉ាងតិចពីរពាក្យ ។

| ព្យញ្ជនៈខ្យល់បង្ហូរត្រដុស | ពាក្យ | ពាក្យ |
|---|---|---|
| យ៉ | យ៉ាង | ឆៃយ៉ាំ |
| យ | យាង | យើង |
| រ៉ | រ៉ាំរ៉ៃ | រ៉ង |
| រ | រៀន | រុយ |
| ឡ | ឡើង | ឡៀវ |
| ល | លាង | លុយ |

| | | |
|---|---|---|
| ល៉ | ចំលើយ | សាលា |
| វ៉ | វ៉ៃ | វ៉ែនតា |
| វ | វាយ | វៀង |
| ស | សើច | សូម |
| ស៊ | ស៊ី | ស៊យ |
| ហ | ហាង | ហោង |
| ហ៊ | ហ៊ា | ហ៊ោ |

ឃ. ស្រង់ពាក្យខាងក្រោមទៅដាក់ឱ្យត្រូវតាមខ្ទង់ព្យញ្ជនៈព្ទ និង ព្យញ្ជនៈថ្លង់ : មម៉ៃ កកាយ ប៉ើង បោយ ប៊ូល គាស់ ម៉ឺន ដ៊ុ ឱន ខូច ឃ្នាង ង៉ាវ តតេះ ទូក ងាប់ ដួល ញាំ ឋិត ថ្នាក់ ញញូរ ណាស់ នាំ ឈាល ធាង សយនា វវល់ ឡាន សាលា ហ៊ីង ហួល សក ស៊ុប អន់ វ៉ៗ វីកវវ យាន យ៉ាប់យ៉ឺន ផ្សារ ភ្ញី ទាល់ មីនា ធីងធោង តែង ជញ្ជីង ពពុះ ។

| ព្យញ្ជនៈព្ទ | ព្យញ្ជនៈថ្លង់ |
|---|---|
| ដ៊ុ ឱន បោយ ប៊ូល យ៉ាប់យ៉ឺន យាន វ៉ៗ វវល់ វីកវវ ញាំ ញញូរ ណាស់ នាំ មីនា មម៉ៃ ងាប់ ង៉ាវ ឡាន ម៉ឺន | កកាយ គាស់ ខូច ឃ្នាង តតេះ ទូក ដួល ឋិត ថ្នាក់ ឈាល ធាង ប៉ើង ពពុះ ផ្សារ ភ្ញី ទាល់ ធីងធោង តែង ហួល សក ស៊ុប អន់ ជញ្ជីង ហ៊ីង |

មេរៀនទី ៨

# គប់ភាព

## លក្ខណៈគថៈនៅអក្សរសិល្ប៍

១- *លក្ខណៈគថៈក្នុងអក្សរសិល្ប៍ គឺជាសច្ចភាពរបស់សម័យកាលណាមួយដែលអ្នកនិពន្ធបានលើកយកមកថ្លៃជាមួយជំនិតផ្ទាល់ខ្លួនដើម្បីបង្កើតជាស្នាដៃនិម្មិតកម្មឡើង ។*

ចម្លើយលំហាត់

រករកលក្ខណៈគថៈអក្សរសិល្ប៍ក្នុងវគ្គខាងក្រោម :

១. ....សេចក្តីស្រេកឃ្លានបានបង្ខំចិត្ត.................................
យកចេញពីដៃនៃស្ត្រីនោះ ។... (ស.ស.ទំ.១៧៦)

*លក្ខណៈគថៈនៃអត្ថបទដកស្រង់ខាងលើគឺ ការប្រឈមមុខនឹងគ្រោះទុរភិក្សរបស់ប្រជាជនក្រីក្រនៅក្នុងសង្គម ។ ដរាបណាក្រពះមិនទាន់ឆ្អែតមនុស្សមិនទាន់គិតដល់កិត្តិយសឡើយ ។*

២. ....លីមនិងថនបានដើរកាត់ភូមិ..................ទិញអីវ៉ាន់
ជូនលោកប្រុសលោកស្រីខ្លះ....។ (ស.ស.ទំ.១៧៧)

*លក្ខណៈគថៈនៃអត្ថបទដកស្រង់ខាងលើគឺ ការកេណ្ឌប្រជាជនឱ្យទៅធ្វើកំណែននៅពោធិចិនតុងពីសំណាក់ពួកជាស៊ីសជប៉ុន ។ និងការជិះជាន់របស់អ្នកមានអំណាចទៅលើអ្នកតូចតាច ។*



# ប្រមូលកំណែន

**សំណួរ**

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងណា ? វគ្គទីប៉ុន្មាន ?

២. តើអត្ថបទនេះចែកជាប៉ុន្មានវគ្គ ? ហើយវគ្គនីមួយៗបានបង្ហាញពីព្រឹត្តិការណ៍អ្វីខ្លះ ?

៣. ចូរអ្នកបង្ហាញពីទំនាស់នៅក្នុងអត្ថបទនេះ ។

៤. ចូរវិភាគតួអង្គលឹម មេឃុំផាន់ តាមុយ និងលោកបាល័ដ្ឋ ។

៥. តើអត្ថបទនេះឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាសម័យកាលណា?

៦. ហេតុអ្វីបានជាមានវត្តមានពួកជប៉ុននៅលើទឹកដីនៃប្រទេសកម្ពុជា ហើយផ្តល់បាននូវគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះដល់ប្រជាជនកម្ពុជា ?

**ចម្លើយ**

១. អត្ថបទនេះដកស្រង់ចេញពីរឿងគូលីកំណែន វគ្គទី៣ ។

២. អត្ថបទនេះចែកជា៤វគ្គ ៖

-វគ្គទី១ : ចាប់ពី "មាន់រងាវលើកទី២.......ប្រយ័ត្នកុំមាត់ផ្តេសផ្តាស" ។ ព្រឹត្តិការណ៍វគ្គនេះគឺ៖

+ យាយម៉ុករៀបចំស្បៀងអាហារទុកឱ្យលឹមចេញទៅធ្វើការ ។

+ តាង៉ែតយាយម៉ុកនិយាយគ្នាពីអារម្មណ៍អាណិតកូនក្នុង

ការជាប់កំណែន ។

+ ការផ្តាំផ្ញើរបស់យាយម៉ុកពីស្បៀងដែលនាងហោងយកមកឱ្យលីម ។

-វគ្គទី២ : ចាប់ពី "លីមនិងថនបានដើរកាត់ភូមិទៅត្បូង.........
...មានមិនដល់មួយផង" ។ ព្រឹត្តិការណ៍វគ្គនេះគឺ៖

+ លីម ថន តាមុយ បណ្តើរគ្នាដើម្បីទៅជួបជុំក្រុមកំណែននៅផ្ទះមេឃុំផាន់ ។

+ តាមុយនិយាយពីល្បិចកេងប្រវ័ញ្ចលើក្រុមកំណែនរបស់មេឃុំផាន់

+ សគុណដែលបានមកពីល្បិចកេងប្រវ័ញ្ចរបស់មេឃុំផាន់និងការបែងចែកផលទៅឱ្យបក្សពួកមេឃុំផាន់ ។

-វគ្គទី៣ : ចាប់ពី "លីមនិងតាមុយបានដដែក.........ប្រយ័ត្ន" ។ ព្រឹត្តិការណ៍វគ្គនេះគឺ៖

+ មេឃុំផាន់បញ្ជូនគូលី១០០នាក់ ដោយមានប៉ូលីស២នាក់ដើម្បីបណ្តើរក្រុមកំណែនទៅសាលាស្រុក ។

+ ក្រុមកំណែនមកដល់ក្នុងវាលរបងមុខសាលាស្រុក និងក្រុមកំណែនដទៃទៀតដែលអង្គុយតាមមេឃុំប្រកបដោយភាពតោកយ៉ាក ។

+ លោកបាល័ដ្ឋស្រុក និងចៅដោយទទួលភារៈខាងគ្រប់គ្រងកំណែននិងត្រួតពិនិត្យតាមរយៈបញ្ជីរបស់មេឃុំនីមួយៗ ។

+ បាល័ដ្ឋស្រុកបានសរសើរមេឃុំផាន់ប្រមូលកំណែនបាន

ច្រើន និងស្តីបន្ទោសនិងព្រមានចំពោះមេឃុំដែលប្រមូលកំណែនបានតិច ។

+ ការរិះគន់របស់លឹមចំពោះមេឃុំដែលមានឥរិយាបថឱនលំទោននៅមុខបាល័ដ្ឋស្រុក និងការគាំទ្រឥរិយាបថនេះរបស់តាមុយ ។

+ តាមុយរំលឹកដល់លឹមឱ្យចេះប្រយ័ត្នពាក្យសំដីរិះគន់ចំពោះមន្ត្រីអាណានិគម ។

-វគ្គទី៤ : ចាប់ពី "លុះទទួលបញ្ជី............ផាសុំសមបារអាសុំ" ព្រឹត្តិការណ៍វគ្គនេះគឺ៖

+ លោកបាល័ដ្ឋ ចីដោយ និងប៉ូលីស៥នាក់បញ្ជូនក្រុមកំណែនប្រមាណ២០០នាក់ទៅពោធិ៍ចិនតុង ។

+សក្តិ២ជប៉ុនទទួលស្វាគមន៍ចំពោះវត្តមានលោកបាល័ដ្ឋដែលបានប្រមូលកំណែនបានច្រើន ដោយសន្យាឱ្យប្រឡង់ដៃសរសេរជាអក្សរជប៉ុនឱ្យចេញចូលមើលយន្តហោះឡើងចុះតាមចិត្ត ។

+ លោកបាល័ដ្ឋរីករាយ និងសន្យាថានឹងកេណ្ឌឱ្យច្រើនជាងនេះ នៅថ្ងៃក្រោយ និងជួយផ្តល់ស្លឹកត្នោតទៀត បើជប៉ុនត្រូវការ ។

+ ក្រុមគូលីត្រូវទាហានជប៉ុនឃុំនៅក្នុងបន្ទាយព័ទ្ធដោយរបងលួសបន្លា ឱ្យជីកដីធ្វើផ្លូវយន្តហោះ ។

៣. បញ្ហាទំនាស់នៅក្នុងអត្ថបទនេះ៖

**ក. ទំនាស់ក្នុងខ្លួន**

- តាង៉ែតយាយម៉ុក : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមាន ដោយការឈឺចាប់ចំពោះគាបសង្កត់របស់ពួកផាស៊ីសជប៉ុន ក្នុងការកេណ្ឌកូនគាត់ទៅធ្វើជាគូលីកំណែន ។
- លឹម ថន តាមុយ : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមាន ដោយការឈឺចាប់ចំពោះអំពើកេងប្រវ័ញ្ចរបស់មេឃុំផាន់ មកលើក្រុមកំណែន ។
- មេឃុំផាន់ មេឃុំស្វាយ : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមាន ដោយការភ័យខ្លាចនឹងអំណាចលោកបាល័ដ្ឋដែលសម្លុតគំរាមកំហែងចំពោះការប្រមូលកំណែនមិនបានតាមការកំណត់ ។
- ក្រុមកំណែន : ប្រឈមមុខនឹងអារម្មណ៍អវិជ្ជមាន ដោយការនឹករលឹកដល់ក្រុមគ្រួសារ ព្រោះខ្លួនត្រូវពួកអាណានិគមកេណ្ឌទៅធ្វើគូលីរបស់ជប៉ុន ។

**ខ. ទំនាស់ក្រៅខ្លួន**

- លឹម ថន តាមុយ ក្រុមកំណែន : ប្រឈមមុខនឹងមេឃុំផាន់ដោយការប្រើអំណាចគាបសង្កត់មកលើប្រជារាស្ត្រគោកចំបក់ ។
- តាង៉ែត យាយម៉ុក ប្រជារាស្ត្រនៅគោកចំបក់ : ប្រឈមមុខនឹងពួកផាស៊ីសជប៉ុនដោយគាបសង្កត់ទាំងផ្លូវកាយនិងផ្លូវចិត្តតាមរយៈមហិច្ឆតាវាតទីនិយមដើម្បីសេដ្ឋកិច្ច ។

៤. វិភាគតួអង្គ

- **ឈើម**

+គុណសម្បត្តិ

-មានចរិតស្លូតបូតត្រឹមត្រូវចេះគោរពចាស់ទុំ

-បានបួសរៀន មានបញ្ញាវាងវៃ ចេះដឹងជ្រៅជ្រះខាងផ្លូវធម៌ និងផ្លូវលោក ជាពិសេសអក្សរសាស្ត្រជាតិ។

-គោរពកោតខ្លាចមាតាបិតា មានចិត្តស្មោះត្រង់នឹងគូដណ្ដឹង និងត្រូវបានញាតិមិត្តគោរពស្រឡាញ់។

-ជាជនជឿនលឿន មានមនសិការភ្ញាក់រលឹកចំពោះជីវភាពរស់នៅក្នុងគ្រួសារនិងចំពោះជាតិ មិនផ្ដេកផ្ដួលលើទស្សនៈកម្មផលហួសហេតុ។

-ចេះបំភ្លឺការរាក់ជ្រៅរបស់បុព្វហេតុសង្គម

-អប់រំប្រជាជនឱ្យតស៊ូទាមទារសិទ្ធិសេរីភាព ប្រជាធិបតេយ្យ។

-មានសាមគ្គីភាពទូលំទូលាយជាមួយកម្មករ ចេះស្រឡាញ់រាប់អាន ចេះជួយបំភ្លឺផ្លូវគ្នា។

-គោរពប្រពៃណីត្រឹមត្រូវក្នុងការកសាងគ្រួសារ ដោយឪពុកម្ដាយចូលដណ្ដឹងនាងហេងតាមប្រពៃណី។

+គុណវិបត្តិ

-ពុំមានលទ្ធភាពការពារក្រុមគ្រួសារ ពិសេសគូដណ្ដឹងរបស់ខ្លួន។

- **តានុយ**

+គុណសម្បត្តិ

-ជាមនុស្សស្លូតត្រង់

-ចេះសង្កេតបញ្ហាសង្គមដែលគ្រប់គ្រងដោយពួកផាស៊ីសជប៉ុននិងមន្ត្រីអាណានិគម និងល្បិចកេងប្រវ័ញ្ចរបស់ពួកមន្ត្រីអាណានិគមក្នុងនាមជាមនុស្សចាស់ច្រើនជំនាន់។

+គុណវិបត្តិ

-មិនមានគំនិតជឿនលឿន ផ្ដេកផ្ដួលលើព្រេងវាសនា

-មិនយល់ពីស្រុកប្រជាធិបតេយ្យ

-ជាមនុស្សល្ងង់ខ្លៅ ខ្លាចគេ

- **មេឃុំផាន់-លោកបាល័ដ្ឋ**

+គុណសម្បត្តិ (ពុំមាននិយាយទេ)

+គុណវិបត្តិ

-ជាគំរូមិនល្អជាមួយរដ្ឋអំណាច បម្រើដាច់ថ្លៃឱ្យពួកអាណានិគមបារាំង-ជប៉ុន

-មានគំនិតផ្ដាច់ការនិយម ជិះជាន់រាស្ត្រឯង

-ស្រឡាញ់បុណ្យសក្តិ ប្រព្រឹត្តអំពើពុករលួយ គំរាមកំហែងប្រជាជន

-ជាមនុស្សពាលានឹងស្រី

-ប្រើពាក្យអសុរោះ (អា មី ....)

៥. អត្ថបទនេះឆ្លុះបញ្ចាំងពីតថភាពសង្គមខ្មែរនាសម័យអាណានិគម បារាំង-ជប៉ុន ។

៦. បានជាមានវត្តមានពួកជប៉ុននៅលើទឹកដីនៃប្រទេសកម្ពុជា ព្រោះពួកវាមកដើម្បីពង្រីកសង្គ្រាមមហាអាស៊ី ដើម្បីពង្រីកទីផ្សារសម្រាប់លក់ផលិតផលខ្លួនដែលមានកំណើនខ្ពស់ គឺធ្វើយ៉ាងណាឱ្យវិស័យសេដ្ឋកិច្ចខ្លួនមានការរីកចម្រើន ។

ចំពោះវត្តមានពួកជប៉ុននៅលើទឹកដីកម្ពុជា បានបន្សល់នូវគុណសម្បត្តិ និងគុណវិបត្តិដូចជា៖

+គុណសម្បត្តិ

-ជួយដេញបារាំងចេញពីស្រុកយើង

-កសាងព្រះលានយន្តហោះ ដែលសព្វថ្ងៃក្លាយជាព្រលានយន្តហោះអន្តរជាតិ

+គុណវិបត្តិ

-បង្កឱ្យមានសង្គ្រាមរ៉ាំរ៉ៃ

-ធ្វើបាបរាស្ត្រខ្មែរគ្មានប្រណីដើម្បីបម្រើប្រយោជន៍ផ្ទាល់ខ្លួន ។

-ធ្វើឱ្យប្រជារាស្ត្រខ្មែរព្រាត់ប្រាសឪពុកម្តាយ បង ប្អូន កូនចៅ ប្តីប្រពន្ធ... ។

-ពុំបានធ្វើឱ្យសេដ្ឋកិច្ចជាតិរីកចម្រើនទេ ភាពក្រីក្រកាន់តែរីកធំទៅៗ ។

# ព្យញ្ជនៈផ្សំ

*១– ព្យញ្ជនៈផ្សំគឺជាសូររួមនៃព្យញ្ជនៈពីរ ឬបី ដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ។*

**លំហាត់**

១. ចូរអ្នកជ្រើសរើសព្យញ្ជនៈផ្សំដែលមានលក្ខណៈ (ស្មះ+ស្មះ) ដូចខាងក្រោមនេះ :

ក. ខ្ពស់ ខ្ពង់ ត្បូង ថ្កាម ជ្រេ ឃ្វាល ខ្សែ ខ្យល់ ឆ្មោះ ច្បារ ឆ្កោ ថ្នូរ ឆ្នា ឆ្នាំ ក្មេង ក្នុង។

ខ. [...] រឿងកំណែន។ ឆ្នាំនេះរាជការ........ម្នាក់៥០រៀល។ (ស.ស.ទំ.១៨៣)

២. ចូរអ្នកប្រៀបធៀបនិយមន័យព្យញ្ជនៈផ្សំ និងព្យញ្ជនៈទោលដូចខាងក្រោម:

-ព្យញ្ជនៈទោល គឺជាសូរសំឡេងដែលកើតឡើងមកពីដំណើរខ្យល់តាមបំពង់សំឡេងបន្លឺឡើងដោយមានទំនប់ប្រកបដោយភាពពុំច្បាស់លាស់។

-ព្យញ្ជនៈផ្សំគឺជាសូររួមនៃព្យញ្ជនៈពីរ ឬបី ដែលគ្មានស្រៈនៅចន្លោះសូរទាំងនោះទេ។

**ចម្លើយ**

១. ព្យញ្ជនៈផ្សំដែលមានលក្ខណៈ (ស្មះ+ស្មះ)

ក. ខ្ពស់ ខ្ពង់ ត្បូង ថ្កាម ឃ្វាល ឆ្កោះ ច្បារ ឆ្កោ ។

ខ. ផ្ទះ

២. ប្រៀបធៀបនិយមន័យព្យញ្ជនៈផ្សំ និងព្យញ្ជនៈទោល ៖

-ព្យញ្ជនៈទោល គឺមានព្យញ្ជនៈតែមួយ ហើយផ្សំជាមួយនឹងស្រៈតែម្តង ពុំមានត្រួតជើងព្យញ្ជនៈទេ ។

ឧ. តា > ត + ◌ា...

-ចំណែកព្យញ្ជនៈផ្សំគឺព្យញ្ជនៈដែលមានត្រួតជើង ឬមានព្យញ្ជនៈពីរ ឬបីនៅជាប់គ្នារួចទើបផ្សំនឹងស្រៈ ។

ឧ. ល្អី > ល + អ + ◌ី

ស្ត្រី > ស + ត + រ + ◌ី

## ជីវិតអន្តរាររបស់ប្រជាជនខ្មែរ

សំណួរ

១. តើអត្ថបទនេះដកស្រង់ចេញពីណា? ជាបទអ្វី? ក្នុងសម័យកាលណា? ឆ្នាំណា?

២. តើអត្ថបទនេះចែកជាប៉ុន្មានគំនិតសំខាន់?

៣. ចូរអ្នក :

ក. ពន្យល់ខ្លឹមសារនៃវគ្គដកស្រង់នីមួយៗនេះ ។

ខ. រកបដិវិធីក្នុងវគ្គដកស្រង់នេះ ។

គ. បង្ហាញវិធីចួន ផួន រណ្ដំ ។

ផ្គរភរអ្នកស្រែ មេឃមីរខ្មៅអែ ហាក់រំលំប្រេះ
សង្ឃឹមថាភ្លៀង មិនទៀងជាផេះ ក្លាយជាភ្លើងឆេះ
ខ្លោចអស់ព្រឹក្សព្រៃ ។

ពាក្យដូចទឹកឃ្មុំ តែចិត្តក្ដៅងំ ឆេះទាំងយប់ថ្ងៃ
ខ្លួនពេញកិលេស ស្មើរប្រេះបែកផ្ទៃ ហ៊ានឱ្យតម្លៃ
លោកអស់តណ្ហា ។

បំបាត់ព្រះធម៌ ថាធាតុមិនល្អ ប្រតិកិរិយា
ខ្លួនពុលអំណាច អង់អាចមហិច្ឆតា កាន់ច្បាប់យក្សមារ
លែងស្គាល់សុចរិត ។

ប្រើតែអំណាច សំឡុតកំឡាច គ្មានមេត្តាចិត្ត

បែងចែកសង្គម តូចធំគ្មានក្រិត្យ ឆ្ងាយគ្នាហួសពិត
ជាងមេឃនិងដី។

៤. តើអត្ថបទបានឆ្លុះបញ្ចាំងពីវិស័យអ្វីខ្លះនាសម័យកាលនោះ?

៥. តាមរយៈការសិក្សាអត្ថបទនេះ តើអ្នកឃើញពីស្ថានភាពសង្គមខ្មែរនាសម័យនោះដូចម្ដេចខ្លះ?

៦. ចំពោះអំពើនៃបុគ្គលក្នុងអត្ថបទខាងលើនេះ តើសក្ដិសមជាបុគ្គលដែលមានមនុស្សធម៌ចំពោះប្រជារាស្ត្រដែរឬទេ? ហេតុអ្វី?

ចម្លើយ

១. អត្ថបទនេះដកស្រង់ចេញពី៖

-"មើលផែនដីខ្មែរ" របស់លោក ជួនម៉ែន។

-តែងជាបទកាកគតិ

-ស្ថិតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)

-បោះពុម្ពឆ្នាំ១៩៨០

២. អត្ថបទនេះចែកជាបីគំនិតសំខាន់ :

+ផ្នែកទី១ "ផ្ដរភអ្នកស្រែ..............មានភាពដូចគ្នា" (វ.១-៧) គំនិតសំខាន់ : ការនិយាយផ្សេង ប៉ុន្តែធ្វើផ្សេងរបស់ពួកអ្នកកាន់អំណាច (ភាពខុសគ្នារវាងទ្រឹស្ដីនិងការអនុវត្ត)។

+ផ្នែកទី២ "ដំឡូងមួយដុំ.............បោកប្រាស់សម្លាប់" (វ.៨-១៩) គំនិតសំខាន់ : ភាពផ្ដាច់ការដោយការរំលោភសិទ្ធិក្នុងការរស់នៅរបស់ប្រជារាស្ត្រ។

•ផ្នែកទី៣ "រៀនសូត្រមានន័យ...........ដាលទៅជាធ្ងន់" (វ.២០-២៥) គំនិតសំខាន់ : អត្ថន័យនៃពាក្យរៀនសូត្រ៤យ៉ាង នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៣. ក. ខ្លឹមសារនៃវគ្គដកស្រង់៖

-វគ្គទី១ : ការខកបំណងរបស់ប្រជារាស្ត្រចំពោះធម្មជាតិ ។

-វគ្គទី២ : ភាពផ្ទុយគ្នារវាងពាក្យសំដីនិងចិត្ត ។

-វគ្គទី៣ : លុបបំបាត់ព្រះពុទ្ធសាសនា លែងប្រកាន់ពាក្យសច្ចៈ ។

-វគ្គទី៤ : បែងចែកវណ្ណៈសង្គមមនុស្សពុំសមហេតុផល ។

ខ. បដិវិធីក្នុងវគ្គដកស្រង់

- វគ្គទី១ : ខ្មៅ (ភ្លៀង) ⟷ ភ្លើង (រាំងភ្លៅហួតហែង)
- វគ្គទី២ : ពាក្យផ្អែមដូចឃ្មុំ ⟷ ចិត្តក្តៅងំ
- វគ្គទី៣ : សីលធម៌ (កុសល) ⟷ យកអំពើបាប
- វគ្គទី៤ : ការពិត ⟷ ការមិនពិត

គ. ព្យាង្គចួន

•ចួនក្នុងវគ្គ

ព.៤ ឃ.១ ⟷ ព.៤ ឃ.២ (ស្រែ ⟷ អែ)

ព.៤ ឃ.៣ ⟷ ព.៤ ឃ.៥ ⟷ ព.៤ ឃ.៦

(ប្រេះ ⟷ ផេះ ⟷ ឆេះ)

ព.៤ ឃ.៤ ⟷ ព.២ ឃ.៥ (ភ្លៀង ⟷ ខៀង)

•ចួនឆ្លងវគ្គ : ព.៤ ឃ.៧ វ.១ ⟷ ព.៤ ឃ.៣ វ.២

(ព្រៃ ⟷ ថ្ងៃ)

ព្យាង្គផ្ទួន ៖ មេឃ ឆេះ អំណាច

ព្យាង្គរណ្ដំ ៖ មេឃមីរ, អង់អាច.

៤. អត្ថបទនេះបានឆ្លុះបញ្ចាំងពីវិស័យមួយចំនួននៅសម័យនោះដូចជា ៖ វិស័យកសិកម្ម វិស័យវប្បធម៌ វិស័យអប់រំ វិស័យសុខាភិបាល នយោបាយ...។

៥. តាមរយៈការសិក្សាអត្ថបទនេះ ខ្ញុំឃើញថាស្ថានភាពសង្គមខ្មែរនាសម័យនោះបានធ្លាក់ចុះដល់កម្រិតសូន្យលើគ្រប់វិស័យ ។

៦. ចំពោះអំពើនៃបុគ្គលក្នុងអត្ថបទខាងលើនេះ មិនសក្តិសមជាបុគ្គលដែលមានមនុស្សធម៌ចំពោះប្រជារាស្ត្រទេ ព្រោះពួកវាធ្វើបាបនិងកាប់សម្លាប់ជាតិសាសន៍ឯង ព្រមទាំងប្រើឱ្យធ្វើការដូចសត្វធាតុ ។ ទង្វើនេះយើងចាត់ទុកជាទង្វើសាហាវយង់ឃ្នង អមនុស្សធម៌ និងព្រៃផ្សៃជាទីបំផុត ដែលខុសនឹងផ្លូវសាសនាផង ផ្លូវច្បាប់ផង និងផ្លូវសីលធម៌ផង ។

# ៧ រឿង ជីវិតទុគ៌តជន

សំណួរ

១. តើរឿងនេះចាត់ទុកជាអក្សរសិល្ប៍ប្រភេទអ្វី? ចូរបញ្ជាក់។

២. ហេតុអ្វីបានជាសមសំរេចចិត្តឆក់កាបូបពីស្ត្រីរូបនោះ?

៣. តើអំពើរបស់សមនៅពេលនោះជាអំពើដែលកើតចេញពីឆន្ទៈផ្ទាល់ខ្លួនតែម្តង ឬយ៉ាងណា? ហេតុអ្វី?

៤. ដោយផ្អែកទៅលើតថភាពនៃរឿង តើសង្គមនាសម័យកាលនោះមានលក្ខណៈដូចម្តេចខ្លះ?

៥. ហេតុដូចម្តេចបានជាអ្នកនិពន្ធពោលថា "អ្នករត់ទាំងឡាយ គេរត់ប្រណាំងប្រជែងគ្នាយករង្វាន់ តែសមរត់ប្រណាំងនឹងការដាច់ពោះស្លាប់" មានន័យដូចម្តេច?

៦. ចូរបង្ហាញគំនិតអ្នកនិពន្ធតាមរយៈខ្លឹមសារនៃរឿងនេះ។

ចម្លើយ

១. រឿងនេះចាត់ទុកជាអក្សរសិល្ប៍ទំនើប បែបប្រលោមលោកខេមរនិយម ព្រោះវាបានឆ្លុះបញ្ចាំងពីជីវភាពរបស់ប្រជាជនខ្មែរនាសម័យនោះ។

២. បានជាសមសំរេចចិត្តឆក់កាបូបពីស្ត្រីរូបនោះ ព្រោះសមឃ្លានខ្លាំងពេក គ្មានប្រាក់សម្រាប់ទិញបាយចំអែតក្រពះ។

៣. អំពើរបស់សមនោពេលនោះមិនមែនជាអំពើដែលកើតចេញពីឆន្ទៈផ្ទាល់ខ្លួនទេ ព្រោះតាំងពីដើមមកសមមិនដែលមានគំនិតបែបនេះឡើយ សមធ្វើនេះដោយសារតែទាល់ច្រកតែប៉ុណ្ណោះ ។
៤. ដោយផ្អែកទៅលើតថភាពនៃរឿង សង្គមនាសម័យកាលនោះមានលក្ខណៈរើសអើង បែងចែកវណ្ណៈអ្នកមានអ្នកក្រ អ្នកធំ អ្នកតូច គ្មានការគោរពសិទ្ធិមនុស្សទេ ។ អ្នកមាន មានកប់ពពកចំណែកអ្នកក្រ ក្ររហាមរកបាយស៊ីស្ទើរពុំបាន ។ អ្នកមានមើលមិនឃើញពីគុណសម្បត្តិរបស់អ្នកក្រឡើយ ។
៥. បានជាអ្នកនិពន្ធពោល "អ្នករត់ទាំងឡាយ គេរត់ប្រណាំងប្រជែងគ្នាយករង្វាន់ តែសមរត់ប្រណាំងនឹងការដាច់ពោះស្លាប់" មានន័យថា ពួកកីឡាករគេរត់ប្រណាំងគ្នាដើម្បីឱ្យដល់ទីមុនគេទើបទទួលបានជោគជ័យ បានពានរង្វាន់ បានកិត្តិយស ។ល ។ ប៉ុន្តែផ្ទុយទៅវិញសមរត់ឱ្យលឿនដើម្បីកុំឱ្យគេដេញចាប់បាននៅពេលឆក់កាបូកគេ ព្រោះតែសេចក្តីស្រេកឃ្លាន ។
៦. តាមរយៈខ្លឹមសារនៃរឿងនេះ អ្នកនិពន្ធមានគំនិតអប់រំមនុស្សមិនឱ្យប្រព្រឹត្តអំពើទុច្ចរិត ទោះបីជាស្ថិតក្នុងស្ថានភាពទ័លក្រ លំបាកយ៉ាងណាក៏ដោយ ព្រោះអំពើទុច្ចរិតជាអំពើដែលប្រឆាំងនឹងច្បាប់ និងឱ្យចេះគោរពសិទ្ធិគ្នាទៅវិញទៅមក ។

# បកស្រាយន័យសុភាសិត និងពាក្យស្លោក

*៙— សុភាសិត គឺជាពាក្យល្អពីរោះ មានន័យសេចក្ដីគ្រប់គ្រាន់ សម្រាប់អប់រំពូទ្ធានកូនខ្មែរគ្រប់ជំនាន់ ជាពិសេសទាក់ទងជាមួយផ្នែកស៊ីលធម៌រស់នៅប្រចាំថ្ងៃ ការដាស់តឿនក្រើនរំលឹក ការប្រុងប្រយ័ត្ន ចំពោះសត្រូវ ការទទួលយកបទពិសោធពីមនុស្សជំនាន់មុន ។*

*៙— ពាក្យស្លោកជាទស្សនៈ ឬគោលគំនិតដែលបានលើកឡើង សម្រាប់ឱ្យអ្នកដទៃយកទៅអនុវត្តក្នុងសង្គមឱ្យមានការរីកចម្រើន ។*

**លំហាត់**

១. ចូរអ្នកជ្រើសរើសនូវឃ្លាខាងក្រោមនេះដោយបញ្ជាក់ថាមួយណាជាសុភាសិត និងមួយណាជាពាក្យស្លោក ដោយភ្ជាប់ជាមួយនូវការពន្យល់ផង ។

-ត្រីកំភ្លាញស្លាប់ព្រោះមាត់ ខ្វែកងាប់ព្រោះអាចម៍

-ការអប់រំ គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

២. ចូរបកស្រាយសុភាសិតខាងក្រោម :

-ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក

-ត្រូវដំដែកក្នុងពេលដែកកំពុងក្ដៅ ។

**ចម្លើយ**

១. - "ត្រីកំភ្លាញស្លាប់ព្រោះមាត់ ខ្វែកងាប់ព្រោះអាចម៍" : ជាសុភាសិត ។

អត្ថន័យ : ត្រីកំភ្លាញងាប់ព្រោះមាត់

-ន័យចំ : ត្រីកំភ្លាញទោះនៅទីណាក៏មិនស្ងាត់ដែរ វាតែងធ្វើមាត់ចិប១ ធ្វើឱ្យមានរលកទឹកដល់ផ្ទៃខាងលើ ។ មនុស្សឃើញហើយក៏ដឹងថាមានត្រី ក៏យកសន្ទូចមកស្ទូច ឬយកឈ្នាងមកជញ្ជាក់ ឬយកសំណាញ់មកបង់ ។ ត្រីកំភ្លាញក៏ងាប់អសារបង់ ។

-ន័យធៀប : សំដៅលើមនុស្សមាត់ដាច ចេះតែនិយាយប៉ប៉ាច់ប៉ប៉ោច ឥតចេះគិតពិចារណាទៅលើកាលៈទេសៈ ក៏បណ្ដាលឱ្យមានគ្រោះអាសន្ន ឬអន្តរាយដល់ខ្លួនវិញ ។

- "ការអប់រំ គឺជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ" : ជាពាក្យស្លោក ។

អត្ថន័យ

ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ ជាបឋមគេត្រូវអភិវឌ្ឍធនធានមនុស្ស ព្រោះធនធានមនុស្សជាថាមពលដ៏សំខាន់ក្នុងកិច្ចអភិវឌ្ឍសង្គម ។ ចំណែកកត្តាធនធានមនុស្សអាចសម្បូរបែប និងមានប្រសិទ្ធភាពទៅបានអាស្រ័យដោយការយកចិត្តទុកដាក់ជាពិសេសទៅលើវិស័យអប់រំ ។ មានន័យថាបើវិស័យអប់រំរីកចម្រើន នាំឱ្យមានធនធានមនុស្សគ្រប់គ្រាន់ ហើយនាំឱ្យការអភិវឌ្ឍសេដ្ឋកិច្ចជាតិមានសន្ទុះទៅមុខជានិរន្តរ៍ ។ ផ្ទុយទៅវិញបើវិស័យអប់រំធ្លាក់ចុះ នាំឱ្យបាត់បង់ធនធានមនុស្ស ហើយធ្វើឱ្យប្រទេសជាតិអាប់ចុះទៅតាមនោះដែរ ។

២. បកស្រាយសុភាសិត

"ឈើវៀចធ្វើកង់ ឈើត្រង់ធ្វើទូក"

ចំពោះសុភាសិតខាងលើនេះយើងអាចចែកជាពីរឃ្លា គឺ :

-ឈើវៀចធ្វើកង់ : កង់នៅទីនេះសំដៅលើវត្ថុមានរាងមូល សម្រាប់ធ្វើឱ្យរទេះមានចលនាទៅមុខបាន ។ ដូច្នេះឃ្លានេះមានន័យថា ឈើដែលវៀចក៏មានប្រយោជន៍ដែរ គេមិនបោះវាចោលទេ គឺគេយកទៅច្រៀកច្នៃវាសម្រាប់ធ្វើកង់រទេះ គេមិនអាចយកឈើត្រង់ទៅធ្វើកង់បានទេ ព្រោះកង់មានរាងមូល ។

-ឈើត្រង់ធ្វើទូក : ទូកនៅទីនេះ សំដៅលើទូករទេះ គឺឈើត្រង់ពីរទ្រត្តូររទេះទៅភ្ជាប់នឹងចន្ទោល ។ ទូករទេះមានរាងត្រង់ភ្លឹង ដូចនេះគេមិនអាចយកឈើវៀចទៅធ្វើបានគេ ទាល់តែឈើត្រង់ទើបធ្វើបាន ។

ដូចនេះសុភាសិតខាងលើមានន័យសរុប ជាន័យចំ និងន័យធៀបថា :

-**ន័យចំ** : ដើម្បីធ្វើរទេះមួយគេត្រូវការឈើវៀចផង ឈើត្រង់ផង ។ បានសេចក្ដីថា ឈើវៀចក្ដី ឈើត្រង់ក្ដីសុទ្ធតែមានប្រយោជន៍ផ្សេងៗគ្នា យើងមិនត្រូវចោលមួយណាទេ គឺសំខាន់យើងត្រូវចេះច្នៃប្រឌិតប្រើការតាមចិត្តចង់ ។

-**ន័យធៀប** : មានន័យថាមនុស្សមានច្រើនប្រភេទណាស់នៅក្នុងសង្គមនីមួយៗ គឺមានមនុស្សទៀងត្រង់ សុចរិត និងមនុស្ស ច្រឡើសបើស ក្រឡិចក្រឡុច ភូតភរ របុិលរប៉ូច ។ល។ មនុស្សទាំងពួកនេះសុទ្ធតែជាកោសិកា ឬជាកម្លាំងនៃសង្គមដូចគ្នា ។ ដូចនេះក្នុងនាមយើងជាអ្នកអប់រំ ឬជាអ្នកដឹកនាំ ត្រូវចេះមើលមនុស្ស ស្គាល់ចិត្ត-

សាស្ត្រមនុស្សឱ្យច្បាស់ ដើម្បីអប់រំ និងប្រើពួកគេឱ្យចំទិសដៅ និងមានប្រសិទ្ធភាព។

(សុភាសិតនេះ ជាទ្រឹស្តីប្រើកម្លាំងសរុប)

"ត្រូវដំដែកក្នុងពេលដែកកំពុងក្តៅ"

**-ន័យចំ :** "ដែក" ជាលោហៈម្យ៉ាងដែលរឹង ហើយគេពុំអាចដំ ឬពត់វាបានងាយស្រួលឡើយ។ ដូចនេះដើម្បីដំ ឬពត់វាតាមត្រូវការ គេត្រូវដុតវាឱ្យក្តៅរហូតដល់កម្រិតដែលយើងអាចដំ ឬពត់បាន។ កាលណាដែកក្តៅអាចដំ ឬពត់បានហើយ យើងអាចច្នៃវាទៅជារបស់ប្រើប្រាស់តាមចិត្តយើងបានទាំងអស់។

**-ន័យធៀប :** លោកចង់អប់រំយើងថា បើចង់ប្រដៅ ឬណែនាំមនុស្ស ត្រូវអប់រំណែនាំពេលវានៅក្មេង ព្រោះក្មេងជាវ័យមួយដែលងាយស្តីប្រដៅ និងងាយយកគម្រូតាម។ ប៉ុន្តែបើមនុស្សធំវិញគឺពិបាកប្រដៅណែនាំណាស់ ព្រោះគេមានការគិត មានសតិចេះគិតគូរខ្លួនឯងហើយ ដូចនេះយើងពិបាកនឹងប្រដៅគេតាមចិត្តយើងណាស់។ ម្យ៉ាងទៀតមនុស្សធំ គេមិនចង់ឱ្យអ្នកណាមកបញ្ជា ឬត្រួតគេទេ។

## លក្ខណៈអន្តរជាតិនៃអក្សរសិល្ប៍

*ខ– អក្សរសិល្ប៍មានលក្ខណៈអន្តរជាតិ ជាស្នាដៃដែលមានលក្ខណៈជាតិរួចស្រេចទៅហើយ នៅពេលដែលសង្គមជាតិបានទទួលស្គាល់ថាជាអត្ថបទមានតម្លៃខ្ពង់ខ្ពស់វប្បធម៌ អរិយធម៌របស់ជាតិ ។ បន្ទាប់មកបរទេសយកទៅសិក្សាផ្សព្វផ្សាយនៅក្នុងសង្គមជាតិរបស់គេ គឺនៅពេលនោះហើយដែលអក្សរសិល្ប៍មានលក្ខណៈសកល ពីលក្ខណៈអន្តរជាតិ ។*

**លំហាត់**

១. ចូរបង្ហាញថា រឿងទុំទាវ មានលក្ខណៈអន្តរជាតិ ។

២. តើចំណុចណាខ្លះដែលបញ្ជាក់ថា រឿងអាប៉ាកុងមានលក្ខណៈជាអក្សរសិល្ប៍សកល ឬមានលក្ខណៈអន្តរជាតិ?

**ចម្លើយ**

១. ចំណុចដែលបញ្ជាក់ថា រឿងទុំទាវមានលក្ខណៈអន្តរជាតិត្រង់ចំណុចថា៖

- រឿងទុំទាវមានលក្ខណៈជាតិរួចទៅហើយ ដែលបានបង្ហាញពីការបែងចែកវណ្ណៈនៅក្នុងសង្គម ការពុះពារដើម្បីស្នេហា

ការប្រើអំណាចគាបសង្កត់ជាដើម ដែលចំណុចទាំងនេះនៅប្រទេសដទៃក៏មានដែរ ដូចជារឿងរ៉ូមេអូនិងស៊ុលីយែតរឿងហាមលែត។ល។

២. ចំណុចដែលបញ្ជាក់ថា រឿងអាប៉ាកុងមានលក្ខណៈជាអក្សរ-សិល្ប៍សកល ឬមានលក្ខណៈអន្តរជាតិត្រង់ចំណុចថា៖

- អាប៉ាកុងស្រឡាញ់លុយជាងអ្វី១ទាំងអស់។ ភាពកំណាញ់ដូចអាប៉ាកុងមានស្ទើរគ្រប់ទីកន្លែង ដូចជានៅប្រទេសកម្ពុជាយើងមានរឿងម៉ៅស្វិត ជាដើម។
- រឿងនេះជារឿងដែលល្បីល្បាញពេញនិយមនៅប្រទេសបារាំង និងនៅលើសកលលោក ហើយត្រូវក្រសួងអប់រំយើងបញ្ចូលក្នុងកម្មវិធីសិក្សា និងបោះពុម្ពផ្សាយជាខេមរភាសា។

## អាពាហ៍ពិពាហ៍ខុងជី

**សំណួរ**

១. តាមរយៈអត្ថបទនេះ តើសង្គមសម័យខុងជីជាសង្គមយ៉ាងដូចម្ដេច?

២. ហេតុអ្វីបានជាខុងជីជ្រើសរើសអ្នកទោសធ្វើជាភរិយា? តើខុងជីជាមនុស្សដូចម្ដេច?

៣. ចូរបកស្រាយវាចាខុងជី ៖

ក. ធ្វើគុណទៅហើយ បើគេតបគុណមកវិញចាត់ទុកដូចជាពុំបានធ្វើគុណ ។

ខ. ធ្វើគុណទៅហើយ ត្រឡប់បានជាផលអាក្រក់មកវិញត្រូវទទួលយកការពិសោធដោយដៃទាំងពីរ ។

គ. ធ្វើគុណទៅហើយ បើវារលាយសូន្យទៅត្រូវបន្តការធ្វើគុណទៅទៀត ប្រៀបដូចត្រីបើវាចីកនុយអស់ហើយ គេត្រូវយកសន្ទូចបិទនុយបន្ថែមទៀត ។

៤. តើសព្វថ្ងៃ ការជួញដូរមនុស្សនៅមានឬទេ? តើអ្នកយល់ថាគួរធ្វើដូចម្ដេចដើម្បីបំបាត់អំពើបែបនេះ?

**ចម្លើយ**

១. តាមរយៈអត្ថបទនេះ សង្គមសម័យខុងជីជាសង្គមសក្ដិភូមិ

ដែលពោរពេញទៅដោយការរំលោភសិទ្ធិមនុស្ស ប្រើមនុស្ស និងជួញដូរមនុស្សដូចសត្វធាតុ។ ជាទូទៅមនុស្សដែលគេចាត់ទុកជាទំនិញត្រូវគេចាប់ដាក់ច្រវាក់។ ឯតម្លៃមនុស្សម្នាក់ស្មើនឹងអំបិល១០នាឡិ (ប្រហែល៧គីឡូក្រាម) តែប៉ុណ្ណោះ។

២. បានជាខុងជឺជ្រើសរើសអ្នកទោសធ្វើជាភរិយា ព្រោះខុងជឺជាមនុស្សមានគុណធម៌។ លោកមានចិត្តអាណិតអាសូរអ្នកមានទុក្ខ លោកចង់រំដោះនាងចេញពីទុក្ខវេទនា។

ទង្វើនេះ យើងចាត់ទុកខុងជឺជាមនុស្សដែលប្រកបដោយឧត្តមគតិ មានចិត្តសន្តោសប្រណី មិនរើសអើង ឬមិនប្រកាន់អតីតភាព។

៣. បកស្រាយវាចាខុងជឺ ៖

*ក. ធ្វើគុណទៅហើយ បើគេតបគុណមកវិញចាត់ទុកដូចជាពុំបានធ្វើគុណ* ៖ មនុស្សក្នុងសង្គមមិនអាចរស់នៅឯកោដាច់ពីគ្នាបានទេ ត្រូវមានទំនាក់ទំនងគ្នាទៅវិញទៅមកតាមរយៈការជួយសង្គ្រោះគ្នាក្នុងគ្រាំបាក។ ប៉ុន្តែក្នុងករណីដែលយើងបានធ្វើអំពើល្អទៅលើជនណាម្នាក់ ដើម្បីឱ្យអ្នកនោះធ្វើអំពើល្អណាមួយទៀតមកលើរូបយើងវិញនោះ មានន័យថាយើងនិងជននោះត្រូវចាត់ទុកថាស្មើគ្នា គ្មាននរណាត្រូវគេជំពាក់គុណ ឬត្រូវសងគុណគ្នាទៅវិញទៅមកឡើយ។

*ខ. ធ្វើគុណទៅហើយ ត្រឡប់បានជាផលអាក្រក់មកវិញ ត្រូវទទួលយកការពិសោធដោយដៃទាំងពីរ* ៖ មនុស្សក្នុងសង្គម

មានច្រើនប្រភេទ ដូចជាក្នុងពេលដែលមានគ្រោះថ្នាក់ ឬផល វិបាកអ្វីមួយកើតឡើង ជននោះតែងអំពាវនាវដល់សប្បុរសជន មកជួយខ្លួន។ ប៉ុន្តែបើយើងបានជួយសង្គ្រោះគេហើយ តែត្រូវ ទទួលគុណវិបត្តិដោយសារអំពើល្អនោះ គឺយើងមិនត្រូវខឹងទេ តែត្រូវទទួលយកគុណវិបត្តិនោះមកធ្វើជាបទពិសោធសម្រាប់ ជីវិតរបស់ខ្លួនក្នុងការស្វែងយល់ពីមនុស្សដែលយើងត្រូវទាក់ ទងតទៅទៀត។

*គ. ធ្វើគុណទៅហើយ បើវារលាយសូន្យទៅ ត្រូវបន្តការ ធ្វើគុណទៅទៀត ប្រៀបដូចត្រី បើវាចឹកនុយអស់ហើយ គេ ត្រូវយកសន្ទូចបិទនុយបន្ថែមទៀត* : បើអំពើល្អរបស់ខ្លួន ត្រូវបាត់បង់ដោយប្រការណាមួយនោះ សប្បុរជនមិនត្រូវរញ្ជួយ ឬងាកចេញពីអំពើល្អនោះទេ តែត្រូវព្យាយាមធ្វើតទៅទៀត ព្រោះអំពើទាំងនោះជាអំពើត្រឹមត្រូវ។ បើគេបោះបង់ចោល អំពើដ៏ល្អនោះ មានន័យថាយើងធ្លាក់ខ្លួនទៅក្នុងរណ្តៅបាបកម្ម ហើយ។ ម្យ៉ាងទៀតការធ្វើអំពើល្អជាមួយមនុស្សអាក្រក់ គឺជា វិធីមួយបែបដើម្បីកែប្រែមនុស្សអាក្រក់។ ដូច្នេះបើចង់បន្ថយ ចំនួនមនុស្សអាក្រក់ ត្រូវតែព្យាយាមធ្វើអំពើល្អទៅលើអ្នកទាំង នោះ។

៤. សព្វថ្ងៃ ការជួញដូរមនុស្សនៅតែមាន។ ដើម្បីបំបាត់អំពើបែប នេះលុះត្រាតែមនុស្សម្នាក់ៗសហការនឹងក្រុមសមត្ថកិច្ច ដើម្បី ស្វែងរកអ្នកជួញដូរមនុស្ស និងអ្នកចាំទិញនៅតាមទីកន្លែង

កំសាន្តនានា ដូចជារង្គសាល ឬផ្ទះសំណាក់ជាដើម ។

## អំពីព្យាង្គ (សទ្ទក្នុងព្យាង្គ)

លំហាត់

១. ដូចម្ដេចដែលហៅថាព្យាង្គ? ចូររកឧទាហរណ៍បញ្ជាក់ ។

២. ចូរស្រង់ព្យាង្គពីក្នុងល្បះនេះ "កង្កែបច្រៀងលេងសប្បាយពេលភ្លៀងរលឹម" ។

៣. ចូររកពាក្យទាំងនេះ "គោ មេ មួយ នឹម ភ្ជួរ ស្រែ ស្ទូង ស្រូវ" ដែលជា៖

-សទ្ទដើមព្យាង្គ

-សទ្ទកណ្ដាលព្យាង្គ

-សទ្ទចុងព្យាង្គ

៤. ចូរជ្រើសរើសព្យាង្គណាលដែលមានសទ្ទដើមព្យាង្គ សទ្ទកណ្ដាលព្យាង្គ និងសទ្ទចុងព្យាង្គពីក្នុងល្បះខាងក្រោមឱ្យបានពីរ ក្នុងមួយទម្រង់:

....នៅក្នុងវិមានលោកម្ចាស់ល្អ.........ដំណើរតាមប្ដីមកស្រុកចាន់

តុង ។.... (ស.ស.ទំ.២០៩)

ចម្លើយ

១. ដែលហៅថាព្យាង្គ គឺជាសូរររួមនៃសទ្ទ ដែលបន្លឺឡើងតែមួយបន្ទាយសំឡេង ។

ឧ. គោ មក លោក ទា... ។

២. ព្យាង្គ នៅក្នុងល្បះខាងលើ៖

-ពសព : លេង ពេល

-ពពសព : ច្រៀង ភ្លៀង

៣. ពាក្យ " គោ មេ មួយ នឹម ភ្នួរ ស្រែ ស្នួង ស្រូវ " មាន៖

- គោ < [គ] + [អោ] →[គ] ជាសទ្ទដើមព្យាង្គ
  →[អោ] ជាសទ្ទចុងព្យាង្គ
- មេ < [ម] + [អេ] →[ម] ជាសទ្ទដើមព្យាង្គ
  →[អេ] ជាសទ្ទចុងព្យាង្គ
- មួយ < [ម]+[អួ]+[យ] →[ម] ជាសទ្ទដើមព្យាង្គ
  →[អួ] ជាសទ្ទកណ្តាលព្យាង្គ
  →[យ] ជាសទ្ទចុងព្យាង្គ
- នឹម < [ន] + [អឹ] +[ម] → [ន] ជាសទ្ទដើមព្យាង្គ
  → [អឹ] ជាសទ្ទចុងព្យាង្គ
  → [ម] ជាសទ្ទចុងព្យាង្គ
- ភ្នួរ < [ភ្ន] + [អួ] → [ភ្ន] ជាសទ្ទដើមព្យាង្គ
  → [អួ] ជាសទ្ទចុងព្យាង្គ

- ស្រែ < [ស្រ] + [អែ] → [ស្រ] ជាសទ្ទដើមព្យាង្គ
→ [អែ] ជាសទ្ទចុងព្យាង្គ
- ស្ទូង < [ស្ទ] + [អ៊ូ] + [ង] → [ស្ទ] ជាសទ្ទដើមព្យាង្គ
→ [អ៊ូ] ជាសទ្ទកណ្តាលព្យាង្គ
→ [ង] ជាសទ្ទចុងព្យាង្គ
- ស្រូវ < [ស្ទ] + [អូ] + [វ] → [ស្រ] ជាសទ្ទដើមព្យាង្គ
→ [អូ] ជាសទ្ទកណ្តាលព្យាង្គ
→ [វ] ជាសទ្ទចុងព្យាង្គ

៤. នៅក្នុងអត្ថបទ៖

-សទ្ទដើមព្យាង្គ

+ ចំ < [ច] + [អ់ ម] → [ច] ជាសទ្ទដើមព្យាង្គ
+ នោះ < [ន] + [អ៊ុហ] → [ន] ជាសទ្ទដើមព្យាង្គ

-សទ្ទកណ្តាល

+ ពេល <[ព]+[អ៊េ]+[ល] → [អ៊េ] ជាសទ្ទកណ្តាលព្យាង្គ
+ គាត់ < [គ]+[អ៊ ័]+[ត]→[អ៊ ័] ជាសទ្ទកណ្តាលព្យាង្គ

-ព្យាង្គសទ្ទចុងព្យាង្គ :

+ ចៅ < [ច] + [អៅ] → [អៅ] ជាសទ្ទចុងព្យាង្គ
+ បាន <[ប]+[អា]+[ន] → [ន] ជាសទ្ទចុងព្យាង្គ

# កិត្តិយស ឬស្នេហា

សំណួរ

១. តើអត្ថបទនេះជាអត្ថបទប្រភេទណា? ដកស្រង់ពីណា? ស្ថិតនៅឈុតទីប៉ុន្មាន? ឆាកទីប៉ុន្មាន? មានតួអង្គណាខ្លះ?

២. តើអត្ថបទដកស្រង់នេះស្ថិតក្នុងសង្គមបរិយាកាសបែបណា?

៣. ចូរវិភាគតួអង្គដុងរ៉ូឌ្រិច និងស៊ីម៉ែន ។

៤. តើចំណុចណាខ្លះដែលបញ្ជាក់ថា អត្ថបទនេះមានលក្ខណៈជាអក្សរសិល្ប៍សកល?

៥. ចូរសរសេរសង្ខេបវគ្គដកស្រង់ខាងក្រោមឱ្យទៅជាពាក្យរាយ ។ (វគ្គដកស្រង់ក្នុងស.ស.ទំ.២១៥)

ចម្លើយ

១. អត្ថបទនេះជាអត្ថបទប្រភេទល្ខោននាដ្យកថា ដកស្រង់ពីរឿង កិត្តិយស ឬស្នេហា ។ ស្ថិតនៅឈុតទី៣ ឆាកទី៤ ។ ហើយមានតួអង្គ : រ៉ូឌ្រិច ស៊ីម៉ែន និងអិលវៀរ ។

២. អត្ថបទដកស្រង់នេះស្ថិតក្នុងសង្គមបរិយាកាសដែលសង្គមពោរ-ពោញដោយការប្រកួតប្រជែង ដណ្ដើមមុខមាត់ និងការសងសឹកគ្នានៃពួកអភិជន ។

៣. វិភាគតួអង្គ

+រ៉ូឌ្រិក

ក) គុណសម្បត្តិ

-មានចិត្តក្លាហាន ជាកូនកត្តញ្ញូ ហ៊ានសងសឹកជូនឪពុក ។

-មានចិត្តស្មោះចំពោះស្នេហា ។

-មានចិត្តស្មោះត្រង់ចំពោះប្រទេសជាតិ ។

-អាចរក្សាតម្លៃខ្លួនឯងផង និងទាក់ទាញក្ដីស្រឡាញ់ពីអ្នកដទៃផង ។

-អាចគ្រប់គ្រងអារម្មណ៍របស់ខ្លួនឯងបាន ។

ខ) គុណវិបត្តិ

-ដោយចង់សងសឹក ហ៊ានធ្វើឱ្យគូដណ្ដឹងខូចចិត្ត ।

-មានចរិតឆេវឆាវ ដោះស្រាយបញ្ហាដោយហិង្សា ។

+ស៊ីម៉ែន

ក) គុណសម្បត្តិ

-ជានារីស្រស់ស្អាតទាំងកាយនិងចិត្ត ។

-ស្មោះត្រង់ចំពោះស្នេហា ។

-ជាកូនកតញ្ញូ ស្រឡាញ់កិត្តិយស ចេះបែងចែករវាងអំពើល្អនិងអាក្រក់ ។

ខ) គុណវិបត្តិ

-ស្រឡាញ់សូម្បីតែឃាតកសម្លាប់ឪពុកខ្លួន ។

-ចិត្តទន់ចំពោះមុខសត្រូវ ។

៤. ចំណុចដែលបញ្ជាក់ថា អត្ថបទនេះមានលក្ខណៈជាអក្សរសិល្ប៍សកល ព្រោះជារឿងដែលល្បីល្បាញ ដែលគេទទួលស្គាល់លើឆាក

អន្តរជាតិ ដូចត្រង់ចំណុចតួអង្គរ៉ូឌ្រិច និងស៊ីម៉ែន ទោះបីជាមានទំនាក់ទំនងរហូតដល់ស្លាប់រស់ដើម្បីរក្សាកិត្តិយសគ្រួសាររៀងៗខ្លួន តែគេទាំងពីរនៅតែមិនបំភ្លេចសេចក្តីស្នេហាដែលធ្លាប់មានចំពោះគ្នាឡើយ ។

៥. សង្ខេបវគ្គដកស្រង់(ស.ស.ទំ.២១៥) ឱ្យទៅជាពាក្យរាយ :

ក្រោយពីរ៉ូឌ្រិចចេញសងសឹកជំនួសឪពុកហើយ ក៏បានជួបនឹងស៊ីម៉ែន ប៉ុន្តែស៊ីម៉ែនមានការអន់ចិត្តនិងខឹងសម្បានឹងរ៉ូឌ្រិចយ៉ាងខ្លាំង ប៉ុន្តែរ៉ូឌ្រិចបានអង្វរករនាងស៊ីម៉ែនកុំឱ្យខឹង ដោយប្រាប់ពីហេតុផលដែលខ្លួនចេញសងសឹក ហើយក៏បានសុខចិត្តប្រគល់ជីវិតរបស់ខ្លួនឱ្យទៅស៊ីម៉ែនដើម្បីសងសឹកជួសឪពុកនាងវិញ ។ នាងស៊ីម៉ែនមិនដាច់ចិត្តសម្លាប់រ៉ូឌ្រិច ក៏ដេញរ៉ូឌ្រិចឱ្យចេញក្រៅ ។

# អាប៉ាកុងបាត់ហិបប្រាក់

## អត្ថបទ

អាប៉ាកុង (ស្រែកថា ចោរ ! ចោរ ! តាំងពីក្នុងសួនមកនៅលើក្បាលគាត់គ្មានមួកទេ)

ចោរ ! ចោរ ! ចោរប្លន់ខ្ញុំហើយ ! គេសម្លាប់ខ្ញុំហើយ ! ជួយផង ម្ចាស់ថ្លៃអើយជួយផង ! ខ្ញុំងាប់ហើយ ខ្ញុំដាច់ខ្យល់ស្លាប់ហើយ គេកាត់កខ្ញុំ គេលួចលុយខ្ញុំហើយ អ្នកណាឯចេះ? លោកអើយវាក្លាយទៅជាឯមេចទៅហើយ? វាទៅណាហើយ? វាពួនឯណា? ធ្វើម៉េចឯចេះខ្ញុំ ដើម្បីរកវាឱ្យឃើញ រត់ទៅខាងណា? ហើយខាងណាដែលមិនត្រូវរត់ទៅ? វាមាននៅឯណោះទេ? នៅឯណោះទេដឹង? នរណានេះ? ចាប់វា ! ឱ្យលុយអញមកវិញ អាមេប្លន់ (ចាប់ដៃខ្លួនឯង)។ អុំ ខ្ញុំទេតើ វិលខួរហើយខ្ញុំ ខ្ញុំលែងដឹងខ្លួនថានៅឯណាហើយលែងដឹងថាខ្ញុំនេះជាអ្នកណាកំពុងធ្វើអ្វីហើយ។ ព្រះម្ចាស់ថ្លៃអើយកំណាប់លុយដ៏កំសត់អើយ ម្នាលលុយដ៏កំសត់ ម្នាលមិត្តជាទីស្នេហា គេបំបែកខ្ញុំពីអ្នក អត់ពីអ្នកទៅ ខ្ញុំបាក់ចន្ទល់ហើយ លែងមានអ្នកលួងលោម អស់ក្ដីសប្បាយ អស់ផ្លូវហើយខ្ញុំ ជីវិតខ្ញុំអស់ន័យហើយនៅលើលោកនេះ ! ឱកំណាប់លុយ គ្មានអ្នក ខ្ញុំរស់នៅតទៅទៀតមិនកើតទេ។ ឃើញទេ ខ្ញុំហេវហើយ ខ្ញុំដាច់ខ្យល់ហើយ ខ្ញុំស្លាប់ហើយ គេកប់ខ្ញុំហើយ។ តើលោកអ្នកណាអាចប្រស់ខ្ញុំឱ្យរស់ឡើងវិញ ដោយយក

ហិបលុយមកប្រគល់ឱ្យខ្ញុំវិញបាន? ឬក៏គ្រាន់តែប្រាប់ថាអ្នកណាយកទៅក៏បានដែរ? ម៉េច! អ្នកណាថាម៉េច? អត់អ្នកណាឆ្លើយសោះច្បាស់ជាគេឆ្លក់ចំពេលដែលខ្ញុំកំពុងឈ្លោះគ្នាជាមួយអាកូនចំកួតរបស់ខ្ញុំនោះហើយមើលទៅ។ ទៅ ខ្ញុំទៅប្ដឹងតុលាការសិន ឱ្យមកកោះសួរមួយផ្ទះ ឱ្យសួរទាំងបាវស្រី បាវប្រុស កូនប្រុស កូនស្រី ហើយសួរទាំងខ្ញុំថែមទៀត។ ចុះមនុស្សមកពីណាក៏ច្រើនម្ល៉េះ ខ្ញុំមើលទៅអ្នកណាក៏សង្ស័យ ថាសុទ្ធតែជាចោរទាំងអស់។ ហ្ន៎ អ្នកណានិយាយស្អីហ្នឹង? និយាយពីចោរលួចលុយខ្ញុំមែនឬ? អ្នកណាធ្វើអីក្នុងក្ដាំងខាងលើ? អាចោរខ្ញុំនៅឯនោះឬ? ខ្ញុំសូមអង្វរ បើដឹងថាអាចោរនោះនៅឯណាសូមមេត្តាជួយប្រាប់ខ្ញុំផង។ តិចវាពួនក្នុងចំណោមលោកអ្នកទៅ? ខ្ញុំសួរ គិតតែមើលមកខ្ញុំសើចទៅវិញ ឋប់តែចូលដៃចូលជើងនឹងអាចោរទេ។ ទៅលឿនឡើង ទៅហៅពួកតិញ កងខ្មាន់ធ្នូ មេស្រុក ពួកចៅក្រម ពួកពេជ្ឈឃាតឱ្យមកជួយខ្ញុំផង។ ខ្ញុំចង់ប្ដឹងឱ្យគេព្យួរកមនុស្សទាំងអស់ ហើយបើនៅតែរកលុយខ្ញុំមិនឃើញ ខ្ញុំនឹងចងព្យួរកទាំងខ្លួនឯងថែមទៀត។

**សំណួរ**

១. តើអត្ថបទនេះដកស្រង់ចេញពីរឿងអ្វី? ឈុតទីប៉ុន្មាន?

២. តើអ្នកនិពន្ធរឿងនេះឈ្មោះអ្វី?

៣. ចូររាប់ឈ្មោះតួអង្គនិងប្រាប់មុខងាររបស់តួអង្គនីមួយៗផង។

៤. ចូរវិភាគតួអង្គអាប៉ាកុងតាមរយៈអត្ថបទដកស្រង់នេះ។

៥. តើមនុស្សកំណាញ់មានសកម្មភាព និងចរិតលក្ខណៈដូចម្ដេចខ្លះ?

វិធីណាខ្លះដែលអាចជួយកាត់បន្ថយភាពកំណាញ់របស់មនុស្ស កំណាញ់?

ចម្លើយ

១. អត្ថបទនេះដកស្រង់ចេញពីរឿងជនកំណាញ់ ឈុតទី៥ ឆាកទី៧ ។

២. អ្នកនិពន្ធរឿងនេះឈ្មោះម៉ូលីយែ ( ជនជាតិបារាំង) ។

៣. តួអង្គ ( ក្នុងរឿងទាំងមូល) មាន :

-អាប៉ាកុង : ជាឪពុករបស់ក្លេអង់ និងអេលីស

-ក្លេអង់ : កូនប្រុសអាប៉ាកុង និងជាសង្សាររបស់ម៉ារីយ៉ាន

-អេលីស : កូនស្រីអាប៉ាកុង និងជាសង្សាររបស់វ៉ាលីស

-វ៉ាលីស : ជាកូនអង់សែល និងជាសង្សារនាងអេលីស

-ម៉ារីយ៉ាន : ជាកូនស្រីអង់សែល និងជាសង្សាររបស់ក្លេអង់

-អង់សែល : ជាឪពុកវ៉ាលីស និងនាងម៉ារីយ៉ាន

-ផ្រូស៊ីន : ជាស្រីមេអណ្ដើក

-ស៊ីម៉ុង : អ្នកដើងសារ

-ឈាក់ : អ្នកចុងភៅ និងជាអ្នកបររទេះរបស់អាប៉ាកុង

-ឡាផ្លែស : បាវព្រាវរបស់អាប៉ាកុង

-នាងក្លូត : អ្នកបម្រើស្រីរបស់អាប៉ាកុង

-ប្រាំងដាវ៉ាន់ឡាមែកលុស : ជាអ្នកបម្រើអាប៉ាកុង

៤. វិភាគតួអង្គះរាប៉ាកុង

+គុណសម្បត្តិ

-បានចិញ្ចឹមបីបាច់ថែរក្សាកូនរហូតធំពេញវ័យនិងបានរៀបចំទុក

ដាក់កូនឱ្យមានគូស្រករ ។

+គុណវិបត្តិ

-ជាជនកំណាញ់

-គិតតែប្រយោជន៍ផ្ទាល់ខ្លួន ស្រឡាញ់ប្រាក់ហួសហេតុ

-គ្មានទំនុកចិត្តលើខ្លួនឯង និងអ្នកដទៃ សូម្បីកូនបង្កើត

-រលោភលន់គ្មានគិតពិចារណារកហេតុផល

៩. មនុស្សកំណាញ់មានសកម្មភាព និងចរិតលក្ខណៈរវើរវាយ គិតច្រើន បារម្ភច្រើនតែពីទ្រព្យសម្បត្តិ ខ្លាចគេសុំ ខ្លាចគេយក ខ្លាចគេលួច ខ្លាចបាត់ ធ្វើឱ្យភ័យព្រួយជាប្រចាំ គ្មានសេចក្ដីស្ងប់នៅក្នុងចិត្តទេ ។

វិធីដែលអាចជួយកាត់បន្ថយភាពកំណាញ់របស់មនុស្សកំណាញ់បានត្រូវយកព្រះធម៌ទៅអប់រំគេ ឱ្យគេយល់ពីផលអាក្រក់នៃសេចក្ដីកំណាញ់ ផលល្អនៃសប្បុរសធម៌ ។ ហើយបើយើងមានលទ្ធភាព ត្រូវធ្វើអំណោយទានដល់ជនកំណាញ់នោះថែមទៀត ដើម្បីយកឈ្នះសេចក្ដីកំណាញ់របស់គេឱ្យបាន ។

មេរៀនទី ១០

# សុចិត្តនិយម

## រឿង គ្រូបង្រៀនស្រុកស្រែ

សំណួរ

១. នៅក្នុងអត្ថបទអំណាននេះមានតួអង្គប៉ុន្មាននាក់? ឈ្មោះអ្វីខ្លះ? តើតួអង្គនីមួយៗបានធ្វើសកម្មភាពអ្វីខ្លះ?

២. តើអ្នកណាជាតួអង្គឯក និងអ្នកណាជាតួអង្គរង? ចូរផ្តល់អំណះអំណាង។

៣. តាមអក្សរសិល្ប៍នៅក្នុង "រឿងគ្រូបង្រៀនស្រុកស្រែ" ចូរអ្នកបង្ហាញពី :

-លក្ខណៈជាតិនៃអក្សរសិល្ប៍

-លក្ខណៈមនុស្សនៃអក្សរសិល្ប៍

-លក្ខណៈសង្គមនៃអក្សរសិល្ប៍

៤. តើរឿងនេះស្ថិតនៅក្នុងប្រភេទអក្សរសិល្ប៍អ្វី? ចូរផ្តល់អំណះអំណាង។

៥. ដោយផ្អែកទៅលើអត្ថបទ "រឿងគ្រូបង្រៀនស្រុកស្រែ" ចូរអ្នកសិក្សាពី :

-ប្រធានរឿង

-ចំណោទបញ្ហា

-មូលបញ្ហា

-តម្លៃអប់រំ

-កាលេអាកាស

៦. ចូរបកស្រាយអំពីសង្គមបរិយាកាសក្នុងអត្ថបទដកស្រង់។

៧. តើរឿងនេះបង្ហាញគំនិតសុទិដ្ឋិនិយមដូចម្តេចខ្លះ? ហើយគំនិតទាំងនេះបានបង្ហាញតាមរយៈតួអង្គណា?

ចម្លើយ

១. នៅក្នុងអត្ថបទអំណាននេះមានតួអង្គច្រើននាក់ដូចជា :

| តួអង្គ | សកម្មភាពតួអង្គ |
|---|---|
| ពូព្រឿង | នៅផ្ទះមើលថែទាំកូនតូចៗ |
| ហាម | ប្រជាជនក្នុងភូមិ, រត់គេចពីការតាមចាប់របស់ប៉ូលីស, លើកផែនការសំរាប់អភិវឌ្ឍភូមិរបស់គាត់។ |
| អ្នកសន | ប្រពន្ធហាម, ធ្វើការងារផ្ទះ |
| កូនពូព្រឿង | រត់ទៅប្រាប់ប្រពន្ធហាម |
| មុយ | ប៉ូលីស, ទៅរកចាប់ហាម |
| ចីដោយ | នាយប៉ូលីស, ទៅរកចាប់ហាមជាមួយមុយ |
| ហ៊ុន | ស្មៀន |

| | |
|---|---|
| អាចារ្យសម | ពិភាក្សាជាមួយហាមអំពីគ្រោងការណ៍អភិវឌ្ឍន៍ |
| គ្រូម៉េង | ជូនហាម ទៅផ្ទះអាចារ្យសម |
| អគ្គីតឡើង | ពិភាក្សាជាមួយហាមអំពីគ្រោងការណ៍អភិវឌ្ឍន៍ |
| ឡេង | តួអង្គរំលឹក |
| គ្រូម៉ៅ | តួអង្គរំលឹក |
| ក្រុមគ្រូ១ | តួអង្គរំលឹក |
| មេសែរៀនបឹង | តួអង្គរំលឹក |
| បងរីន | តួអង្គរំលឹក |

២. តួអង្គឯកគឺហាម ព្រោះជាតួអង្គសំខាន់ជាងគេ ហើយមានសកម្មភាពច្រើន និងមានផែនការល្អសម្រាប់រៀបចំអភិវឌ្ឍន៍ភូមិឃុំ។ ឯតួអង្គរងគឺអាចារ្យសម ឡើង ....ព្រោះអ្នកទាំងនេះ បានចូលរួមធ្វើសកម្មភាពបន្ទាប់បន្សំជាមួយតួអង្គឯក។

៣. "រឿងគ្រូបង្រៀនស្រុកស្រែ" បង្ហាញពី :

+លក្ខណៈជាតិនៃអក្សរសិល្ប៍ គ្រង់ ៖

-ការបង្ហាញពីប្រពៃណីទំនៀមទម្លាប់ខ្មែរមានការសួរសុខទុក្ខពេលឆ្លងទន្លេ។

-ការបង្ហាញពីទិដ្ឋភាពនៃរបបគ្រប់គ្រង នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ក្នុងសង្គមខ្មែរ...។

-ការតស៊ូដើម្បីសិទ្ធិសេរីភាព ប្រជាធិបតេយ្យ ។

-ការរៀបចំអង្គការ សមាគមដើម្បីផលប្រយោជន៍ប្រជាជន បុគ្គលិកសិក្សា ។

-ការបង្ហាញពីតួអង្គមានមនសិការចំពោះជាតិ ( ហម)

-ការរៀបរាប់ទិដ្ឋភាពធម្មជាតិស្រុកខ្មែរ ( ដើមពោធិ អំពៅ ស្លឹកគ្រៃ ដំឡូង ...)

-ការប្រើប្រាស់ភាសា ពាក្យពេន៍តាមតំបន់( គ្រាមភាសា) ប្រើពាក្យពេចន៍សាមញ្ញក្នុងការប្រាស្រ័យទាក់ទងគ្នា ។

ឱ. កុំព្រួយពីក្រហមពេក ។ ប្រហែលវានោះមិនងាយងាប់ទេ"

-ឈ្មោះតួអង្គ ការហៅឈ្មោះតួអង្គ

+នាងសុន → មីក្សុន

+ពូហម → អាក្រហម

+លក្ខណៈមនុស្សនៃអក្សរសិល្ប៍

-ឆ្លុះបញ្ចាំងពីដំណើរជីវិតរបស់មនុស្សពិតៗ គឺជីវភាពរស់នៅរបស់ក្រុមគ្រូបង្រៀន និងការចេះជួយយកអាសារគ្នារវាងមនុស្សនិងមនុស្ស ពោលគឺដំណើររឿងចោទ និងដោះស្រាយតែពីបញ្ហាមនុស្សពិតៗ ។

+លក្ខណៈសង្គមនៃអក្សរសិល្ប៍

-សង្គមពុំសូវមានស្ថិរភាព ( ចាប់ចងដាក់ខ្នោះ)

-សង្គមពុំទាន់មានលក្ខណៈប្រជាធិបតេយ្យនៅឡើយទេ ( មានការបោះឆ្នោត តែនៅតែមានការគំរាមកំហែង បំបិទសិទ្ធិ

សេរីភាព)

-គ្មានយុត្តិធម៌ (បង្កើតភ័ស្តុតាងដើម្បីដាក់ទោសគ្រូម៉ៃ)

-គោរពព្រះពុទ្ធសាសនា (ហាមបានលើកឡើងថា "បង អាចារ្យដឹងម៉េចកើត បើរវល់តែឋានទេវតាឯណោះនោះ ត្រូវគិត ការរស់នៅលើដីផង...កុំគិតតែភាវនា...")

-ភាពស្មោះត្រង់ តស៊ូ ព្យាយាមរបស់ស្ត្រី ចំពោះស្វាមី និង ការរស់នៅ

-ការជួយយកអាសារគ្នា (គ្រូៗជួយហាម... . ភរិយាគ្រូៗ ជួយថវិកាឱ្យអ្នកសនដើម្បីជួលអ្នកស្រុកធ្វើស្រែ...)

៤. រឿងនេះស្ថិតនៅក្នុងប្រភេទអក្សរសិល្ប៍ទំនើប បែបមនោគមវិជ្ជា នយោបាយ ព្រោះខ្លឹមសារនៃរឿងមានទំនាក់ទំនងទៅនឹងចលនា តស៊ូនយោបាយ ។

៥. សិក្សាពីប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា តម្លៃអប់រំ និង កាលអាកាស នៅក្នុង "រឿងគ្រូបង្រៀនស្រុកស្រែ" :

**+ប្រធានរឿង** : ការតស៊ូដើម្បីទាមទារសិទ្ធិសេរីភាព និង ប្រជាធិបតេយ្យ ។

**+ចំណោទបញ្ហា**

- ការគេចខ្លួនរបស់បងហាមពីការតាមចាប់របស់ប៉ូលីស

- ការចង់រៀបចំការគ្រប់គ្រងភូមិ ឃុំប្រកបដោយប្រជា-ធិបតេយ្យ និងការអភិវឌ្ឍ ។

**+មូលបញ្ហា**

-សកម្មភាពតស៊ូបំផុសចលនាមហាជនដើម្បីរៀបចំកែប្រែសង្គមចាស់មកជាសង្គមថ្មី ។

-និងវិធានការបង្ក្រាបចលនាមហាជនពីសំណាក់អ្នកកាន់អំណាច។

**•តម្លៃអប់រំ** : ស្នាដៃរឿងគ្រូបង្រៀនស្រុកស្រែបានផ្តល់នូវការអប់រំទូន្មានដល់ជនានុជនក្នុងទស្សនៈលោកិយជីវិត និងសង្គមនយោបាយ ៖

-ឱ្យស្អប់អំពើជិះជាន់សង្កត់សង្កិននៃរបបសង្គមចាស់

-ឱ្យងើបតស៊ូបំផុសបំផុលចលនាមហាជនឱ្យភ្ញាក់រលឹកយល់ច្បាស់ពីសារធាតុនៃរបបជិះជាន់

-ឱ្យស្គាល់សិទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពពិតប្រាកដ

-ឱ្យគិតប្រយោជន៍ប្រជាជន ប្រយោជន៍សាធារណៈធំជាងប្រយោជន៍ផ្ទាល់ខ្លួន

-ឱ្យចេះលះបង់កម្លាំងកាយ កម្លាំងបញ្ញា កម្លាំងធនធានដើម្បីបុព្វហេតុមហាជន

-ឱ្យសាមគ្គីគ្នាស្អិតរមួត ជួយឧបត្ថម្ភគ្នាទៅវិញទៅមកក្នុងគ្រាលំបាក

-ឱ្យចូលរួមក្នុងចលនាអក្ខរកម្មដើម្បីបំបាត់ភាពមិនចេះអក្សរ

-ឱ្យចេះកសាងខ្លួន កែប្រែខ្លួនទាន់ពេលវេលា ដុសខាត់ឱ្យអស់នូវកំអែលសក្តិភូមិ និងអាណានិគម

-ឱ្យមានគំនិតសុទិដ្ឋិនិយម

-ឱ្យស្រឡាញ់ពលកម្មបង្កបង្កើនផលកសិកម្ម បសុកម្មដើម្បី ឧបត្ថម្ភជីវភាពរស់នៅ។

-ឱ្យស្គាល់ពីសិទ្ធិនៃការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន ។

-ឱ្យឃើញលក្ខណៈមេដឹកនាំដែលចេះរៀបចំផែនការ ឬគ្រោងការណ៍អភិវឌ្ឍភូមិ ឃុំ ។

-ឱ្យយើងចេះវិនិច្ឆ័យ ឬអនុវត្តតាមគ្រោងការណ៍ប្រកបដោយសុទិដ្ឋិនិយម។

**-កាលអាកាស**

**+កាល** : ដំណើររឿងប្រព្រឹត្តទៅនៅខែកក្កដា សីហា កញ្ញា ក្នុងពេលដែលប្រជាជនកម្ពុជាកំពុងឃោសនាបោះឆ្នោតប្រជែងយកឈ្នះចាញ់រវាងគណៈបក្សនយោបាយ និងក្នុងពេលប្រជាជនកំពុងធ្វើស្រែចម្ការ "រដូវវស្សា"។

**+ទីកន្លែង** : ដំណើររឿងប្រព្រឹត្តទៅនៅម៉ាស៊ីនកិនស្រូវ ភូមិគរ ភូមិប្រាសាទ ភូមិពាម ភូមិឫស្សី ភូមិដកគាំ គុកកំពង់ចាម។

៦. សង្គមបរិយាកាសក្នុងអត្ថបទដកស្រង់គឺប្រទេសខ្មែរទទួលការជិះជាន់របស់ពួកកំអែលសក្តិភូមិ ទទួលចំហាយពីរបបអាណានិគមបារាំង។ ព្រឹត្តិការណ៍សំខាន់ក្នុងអត្ថបទគឺគ្រូបង្រៀនស្រុកស្រែ

និងប្រជាជនពិភាក្សាគ្នារៀបចំគម្រោងការណ៍ឱ្យប្រជាកសិករក្រោកឈរទាមទារសិទ្ធិសេរីភាព ប្រឆាំងអំពើជិះជាន់ ចេះសាមគ្គីគ្នាអភិវឌ្ឍមូលដ្ឋានខ្លួន ។ ការគ្រប់គ្រងប្រទេសនៅពេលនោះពុំទាន់ប្រជាធិបតេយ្យពេញលេញនៅឡើងទេ ។

៧. រឿងនេះបានបង្ហាញគំនិតសុទិដ្ឋិនិយម ត្រង់វគ្គដែលហាមនិយាយថា : "កង់ប្រវត្តិសាស្ត្រសង្គមមនុស្សកំពុងតែវិលសំដៅទៅរកលទ្ធិប្រជាធិបតេយ្យ ។ បើមិនឆ្នាំនេះឆ្នាំក្រោយ ។ បើយើងមិនទាន់បាន កូនយើងធ្វើបាន ។ បើកូនយើងធ្វើមិនសម្រេច ចៅយើងមុខជាសម្រេច ។ បើភូមិឃុំយើងមិនទាន់កើត ក៏ភូមិឃុំផ្សេងទៀតធ្វើបាន" ។

និងត្រង់ចំណុចដែលឡឹងនិយាយថា "សប្បាយហើយក្មេងជាន់ក្រោយ ខ្ញុំមុខតែទៅនិយាយប្រាប់អ្នកភូមិឫស្សីទាំងយប់នេះហើយ" ។



# រឿងឪពុកក្មេករើសកូនប្រសា

**សំណួរ**

១. តើរឿងនេះមានតួអង្គប៉ុន្មាននាក់? ឈ្មោះអ្វីខ្លះ? តើតួអង្គនីមួយៗបានធ្វើសកម្មភាពអ្វីខ្លះ?

២. តើរឿងឪពុកក្មេករើសកូនប្រសាមានខ្លឹមសារដូចម្ដេច?

៣. ចូរបង្ហាញពីលក្ខណៈ និងប្រភេទអក្សរសិល្ប៍ក្នុងរឿង ។ ចូរផ្ដល់អំណះអំណាង ។

៤. ចូរសិក្សាអំពីប្រធានរឿង ចំណោទបញ្ហា មូលបញ្ហា កាលអាកាស និងសង្គមបរិកាសក្នុងរឿងឪពុកក្មេករើសកូនប្រសា ។

៥. តើរឿងនេះមានតម្លៃអប់រំដូចម្ដេច?

៦. តើរឿងនេះបង្ហាញពីគំនិតសុទិដ្ឋិនិយមដូចម្ដេចខ្លះ? តើគំនិតទាំងនោះបង្ហាញតាមរយៈតួអង្គណា?

**ចម្លើយ**

១. រឿងនេះមានតួអង្គ៥នាក់ គឺ តា យាយ កូនក្រមុំ បុរសទី១ និងបុរសទី២ ។ ហើយតួអង្គទាំងនោះមានសកម្មភាពដូចជា៖

-តាយាយ ធ្វើការជ្រើសរើសកូនប្រសារ និងរកឧបាយកលក្នុងការផ្ដាច់កូនពីអ្នកកំលោះ ។

-កូនក្រមុំ រៀបបាយទឹកឱ្យបុរសទី១ និងបុរសទី២ ពេលមកបម្រើឪពុកម្ដាយក្មេក ។

-បុរសទី១ ទៅស្ដីដណ្ដឹងកូនក្រមុំតាយាយ និងធ្វើតាមលក្ខខណ្ឌតាយាយ តែពុំបានសម្រេច។

-បុរសទី២ ទៅស្ដីដណ្ដឹងកូនក្រមុំតាយាយ ហើយធ្វើតាមលក្ខខណ្ឌបានសម្រេច និងចេះរកឧបាយកលទប់ទល់យកឈ្នះតាយាយ រហូតបានកូនក្រមុំធ្វើជាប្រពន្ធ។

២. ខ្លឹមសារនៅក្នុងរឿងឪពុកក្មេករើសកូនប្រសានិយាយអំពី៖

- ប្រពៃណីរើសគូស្រករបស់គ្រួសារខ្មែរបុរាណ ដែលតម្រូវឱ្យកូនប្រុស ត្រូវទៅស្ដីដណ្ដឹងកូនស្រី ហើយទៅនៅបម្រើគ្រួសារខាងស្រីក្នុងរយៈពេលកំណត់មួយ។ ប្រសិនបើគ្រួសារខាងស្រីមិនពេញចិត្ត គេផ្ដាច់កូនវិញភ្លាម។ បើគេពេញចិត្តទើបលើកកូនឱ្យ។
- ការប្រើល្បិចកលរបស់តាយាយដើម្បីផ្ដាច់កូនពីបុរសទី២
- ការប្រើប្រាស់ប្រាជ្ញារបស់បុរសទី២ដើម្បីយកឈ្នះលើតាយាយ។

៣. លក្ខណៈនៃរឿងឪពុកក្មេករើសកូនប្រសា :

**-លក្ខណៈជាតិ** : ឆ្លុះបញ្ចាំងពីប្រពៃណីទំនៀមទម្លាប់ខ្មែរ គឺមានពិធីស្ដីដណ្ដឹង ហើយកូនប្រុសត្រូវទៅបម្រើខាងផ្ទះកូនស្រី។ បើគេពេញចិត្តទើបលើកកូនឱ្យ តែបើមិនពេញចិត្តគេនឹងផ្ដាច់ពាក្យវិញ។

-លក្ខណៈមនុស្ស : អ្នកនិពន្ធលាតត្រដាងពីបញ្ហាមនុស្សពិតៗ គឺចេះដេរ ចេះខឹង ចេះស្រឡាញ់ ចេះផ្ដាប់ផ្គន់...។

-លក្ខណៈសង្គមៈ តាមរយៈសាច់រឿងបង្ហាញថាសង្គមខ្មែរសម័យនោះពុំទាន់រីកចម្រើននៅឡើយទេ។ គេប្រើឧបករណ៍បុរាណមាននង្គ័ល រនាស់ ទឹមដោយគោដើម្បីធ្វើកសិកម្ម។

-លក្ខណៈប្រជាជន : ត្រង់ចំណុចដែលសាច់រឿងបានលើកយកបញ្ហាជីវភាពរបស់ប្រជាជនមកលាតត្រដាង។ តាយាយតំណាងប្រជាជន ប្រកបរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ក្រៅពីនេះពួកគេចូលព្រៃរកចាប់សត្វធ្វើម្ហូបអាហារ កាប់អុស ជាដើម។

រឿងឪពុកក្មេករើសកូនប្រសាស្ថិតក្នុងប្រភេទអក្សរសិល្ប៍ប្រជាប្រិយ ហើយជាប្រភេទនិទានកថាសង្គម ព្រោះវាបានលើកបញ្ហាសង្គមមកចោទ និងដោះស្រាយ ពោលគឺបញ្ហាទុកដាក់កូនចៅឱ្យមានគូស្រករតាមប្រពៃណីខ្មែរ។

៤. សិក្សាអំពី ៖

+ប្រធានរឿង : រឿងនេះនិយាយអំពីការកែប្រែគំនិតឪពុកម្ដាយក្មេកដែលយកប្រពៃណីទំនៀមទម្លាប់មកកេងចំណេញលើកម្លាំងគេ។

+ចំណោទបញ្ហា : ការប្រើឧបាយកលផ្សេងៗដើម្បីផ្ដាច់កូនពីបុរសទី២។

+មូលបញ្ហា : ការប្រើប្រាជ្ញារបស់បុរសទី២ ទប់ទល់នឹងឧបាយ-កលរបស់តាយាយ។

+កាលអាកាស :

-កាល : រឿងនេះកើតតាំងពីសម័យព្រេងនាយមកម្លេះ

ហើយប្រព្រឹត្តទៅនៅពេលព្រឹក ពេលថ្ងៃ និងពេលយប់។

-អាកាស : ដំណើររឿងប្រព្រឹត្តទៅនៅផ្ទះតាយាយ នៅស្រែ នៅក្នុងព្រៃឡើងភ្នំ នៅក្នុងព្រៃរកអណ្ដើក និងនៅតាមផ្លូវទៅផ្សារ។

+សង្គមបរិយាកាស : បរិយាកាសសង្គមខ្មែរនាសម័យនោះគឺបង្ហាញពីការគោរពប្រពៃណីទំនៀមទម្លាប់ដ៏តឹងរឹង ពិសេសគឺប្រពៃណីរើសគូស្រករ។ ដើម្បីបានកូនស្រីគេមកធ្វើជាភរិយា ត្រូវឆ្លងកាត់ពិធីស្ដីដណ្ដឹង ហើយត្រូវទៅនៅបម្រើខាងផ្ទះកូនស្រី និងត្រូវគោរពទៅតាមការបង្គាប់បញ្ជារបស់គ្រួសារខាងកូនស្រី។ បើពុំនោះទេ គេនឹងផ្ដាច់ពាក្យភ្លាម។

៥. រឿងនេះមានតម្លៃអប់រំឱ្យមនុស្ស :

-ចេះតស៊ូជំនះរាល់ឧបសគ្គ

-ចេះប្រើប្រាជ្ញាដោះស្រាយបញ្ហា

-ចេះប្រយ័ត្នប្រយែងក្នុងការនិយាយស្ដី (និយាយយប់កន្ទ្រប់ព្រៃ និយាយថ្ងៃព្រៃមានត្រចៀក)

៦. រឿងនេះបង្ហាញពីគំនិតសុទិដ្ឋិនិយមត្រង់ថាឱ្យតែមានប្រាជ្ញា និងការតស៊ូអត់ធ្មត់ ទោះជារូបអាក្រក់ក៏ដោយក៏គង់ទទួលបានជោគជ័យដែរ។ គំនិតទាំងនោះបង្ហាញតាមរយៈតួអង្គបុរសទី២។

## លក្ខណៈរបស់ព្យាង្គ

**លំហាត់**

១. ចូរស្រង់ពាក្យដែលមានព្យាង្គពួក "អ" និងពាក្យដែលមានព្យាង្គពួក "អ៊" ពីល្បះខាងក្រោម ។

ក. យុវជនគ្រប់រូប ត្រូវហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីបុព្វហេតុការពារបូរណភាពទឹកដីរបស់ខ្លួន ។

ខ. មនុស្សដែលមានសុទិដ្ឋិនិយមក្នុងការធ្វើកិច្ចការ តែងទទួលជោគជ័យក្នុងឆាកជីវិត ។

២. ចូររកពាក្យដែលមានព្យាង្គពួក "អ" ឱ្យបាន១០ និងពាក្យដែលមានព្យាង្គពួក "អ៊" ឱ្យបាន១០ ។

៣. ចូរស្រង់ពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង ព្យាង្គខ្លី ពីក្នុងកថាខណ្ឌខាងក្រោម :

ពោធិកំបោរ ជាវីរជនដ៏អង់អាចក្លាហាន ។ លោកមានទឹកចិត្តស្នេហាជាតិយ៉ាងជ្រាលជ្រៅ ។ លោកបានដឹកនាំចលនាតស៊ូប្រឆាំងនឹងអាណានិគមបារាំងដែលត្រួតត្រាលើប្រទេសកម្ពុជា ។ លោកបានបូជាជីវិតដើម្បីបុព្វហេតុរំដោះប្រទេសជាតិ ។ ប្រជាជនខ្មែរគ្រប់រូបគោរព កោតសរសើរ និងនៅចងចាំគុណវីរភាពនេះក្នុងចិត្តជាប់ជានិច្ច ។

៤. ចូររកពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លី ក្នុងមួយក្រុមឱ្យបាន១០ពាក្យ ។

ចម្លើយ

១. ពាក្យដែលមានព្យាង្គពួក "អ" និងពាក្យដែលមានព្យាង្គពួក "អ៊":

ក. -ព្យាង្គពួក "អ" : ត្រូវ បង់ បែប យ៉ាង ដើម្បី បុត្វ ហេតុ ការ ពារ បូរណ ដី របស់ ។

-ព្យាង្គពួក "អ៊" : យុវជន គ្រប់ រូប ហ៊ាន លះ គ្រប់ ភាព ទឹក ។

ខ. -ព្យាង្គពួក "អ" : ដែល ក្នុង ការ កិច្ច ការ តែង ក្នុង ឆាក។

-ព្យាង្គពួក "អ៊" : មនុស្ស មាន និយម ធ្វើ ទទួល ជោគ ជ័យ ជីវិត។

២. រកពាក្យដែលមានព្យាង្គពួក "អ" ឱ្យបាន១០ និងពាក្យដែលមានព្យាង្គពួក "អ៊" ឱ្យបាន១០ :

-ព្យាង្គពួក "អ" : កា ដើរ ប្ដី តែ កេរ បើក សាម កង់ ជីក...

-ព្យាង្គពួក "អ៊" : មាន ទា យាយ ទួល ជួយ មូល រាង យំ...

៣. ពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង ព្យាង្គខ្លី ក្នុងកថាខណ្ឌ :

-ព្យាង្គបើក : កំបោរ ជា ក្លា ស្នេ ហា អា ណា ត្រា លើ បូ ជា ត ស៊ូ បា សរ សើរ......។

-ព្យាង្គបិទ : ជន អង់ អាច ហាន លោក មាន ទឹក ចិត្ត ជាតិ យ៉ាង ជ្រាល ជ្រៅ លោក បាន ដឹក រាំង កោត ឆាំង នឹង .....។

-ព្យាង្គវែង : បាន លោក អាច ហាន ជ្រាល.....។

-ព្យាង្គខ្លី : អង់ ដឹក ឆាំង នឹង ទឹក ចិត្ត ជ្រៅ......។

៤. ពាក្យដែលមានព្យាង្គបើក ព្យាង្គបិទ ព្យាង្គវែង និងព្យាង្គខ្លី :

-ព្យាង្គបើក : ឆ្កែ តា ទា ស្រា កី ...

-ព្យាង្គបិទ : កូន យើង រៀន អូន បាប ត្រូវ ....

-ព្យាង្គវែង : វែង មាន លើក បើ ថា.....

-ព្យាង្គខ្លី : កាន់ ខ្លៅ ប៊ិច ចុងភៅ ស្រី ចៅ....

# ចប់